**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លី មានហុង**
**ឡុង ប៉ោហេង**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ប៊ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **លី មានហ្វុង**
**ឡុង ប៉ោហេង**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ម៉ុនធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២០

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

ជាដំបូងយើងខ្ញុំឈ្មោះ **លី មានហ្វុង** និង **ឡុង ប៉ោហេង** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២០ ក្នុងឆ្នាំសិក្សា២០១៦-២០២០ សូមសម្តែងនូវកតញ្ញូ និងដឹងគុណដ៏ជ្រាលជ្រៅមិនអាចកាត់ថ្លៃបានដល់លោកអ្នកមានគុណទាំងបួន គឺលោកឪពុក **លី ម៉ុនហ៊ី** និងអ្នកម្តាយ **សាំ ស៊ីវខេង** និងលោកឪពុក **ខៀវ ប៉ោស្រេង** និងអ្នកម្តាយ **ជោត សារី** ដែលបានផ្តល់នូវកំណើតដល់រូបយើងខ្ញុំ និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្នាក់នៅ និងការរៀនសូត្រតាំងពីថ្នាក់មត្តេយ្យនៅបឋមវ័យសិក្សារហូតមកដល់កម្រិតថ្នាក់បរិញ្ញាបត្រ និងបានរួមចំណែកទាំងការផ្តល់នូវកម្លាំងចិត្ត ការអប់រំ ប្រៀនប្រដៅ និងផ្តល់នូវព្រហ្មវិហារធម៌ពីសំណាក់បុព្វញាតិ និងសាខាញាតិ។ សេចក្តីដឹងគុណទាំងអស់នេះ ពិតជាធំធេងពុំអាចកាត់ថ្លៃបានឡើយសម្រាប់ជីវិតពួកយើងទាំងពីរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានផ្តល់នូវកន្លែងបណ្តុះបណ្តាលចំណេះដឹង សមត្ថភាព ក៏ដូចជាការស្រាវជ្រាវ ក្នុងផ្នែកនីតិសាស្ត្រ នេះតាំងពីឆ្នាំទីមួយរហូតមកដល់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ប្រកបដោយភាពជោគជ័យ ផ្លែផ្កា និងសមិទ្ធផលចំណេះដឹងយ៉ាងគាប់ប្រសើរ។

យើងខ្ញុំសូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ថ្នាក់ដឹកនាំ គណៈគ្រប់គ្រង និង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិស្រាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោក លោកស្រី បានធ្វើការផ្តល់នូវចំណេះដឹង ការអប់រំ និងសីលធម៌ដល់យើងខ្ញុំទាំងពីរក្នុងរយៈពេលជិត ៤ឆ្នាំនេះ។

លើសពីនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង នៃបណ្ណាល័យនីតិសាស្ត្រ ដែលរៀបចំ គ្រប់គ្រងឯកសារច្បាប់ សៀវភៅមេរៀន ឯកសារស្រាវជ្រាវ ក៏ដូចជាជួយសម្រួលក្នុងការស្រាវជ្រាវតាក់តែងសារណារបស់យើងខ្ញុំ។

ពិសេសជាងនេះទៅទៀត យើងខ្ញុំសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅដល់ លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលជាសាស្ត្រាចារ្យណែនាំ និងដឹកនាំការសរសេរសារណារបស់យើងខ្ញុំ ដោយលោកបានខិតខំទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃ ក្នុងការផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង យោបល់ ការលើកទឹកចិត្ត និងការបង្ហាញផ្លូវដល់យើងខ្ញុំ ចាប់ពីថ្ងៃចាប់ផ្តើមសរសេរ រហូតដល់ទទួលបានស្នាដៃមួយនេះជាស្ថាពរ ដែលគុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានមកលើយើងខ្ញុំ។

# អារម្ភកថា

យើងខ្ញុំឈ្មោះ **លី មានហុង** និង **ឡុង ប៉ោហេង** ជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ២០ បានឆ្លងកាត់ការសិក្សា និងការបណ្តុះបណ្តាលក្នុងថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ឆ្នាំមកហើយ។ តាមរយៈការសិក្សារយៈពេល ៤ឆ្នាំនេះ ឃើញថាការសិក្សាបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ ពិតជាផ្តល់នូវសារៈសំខាន់យ៉ាងខ្លាំងសម្រាប់យើងខ្ញុំក្នុងនាមជាយុវជនជំនាន់ក្រោយ។ ជាក់ស្តែង យើងខ្ញុំបានទទួលបាននូវចំណេះដឹង និងបទពិសោធន៍ជាច្រើនពីការសិក្សាកន្លងមកនេះ។ ទោះបីជាកាលៈទេសៈខ្លះ យើងខ្ញុំបានជួបប្រទះនូវឧបសគ្គ និងការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែព្យាយាមតស៊ូក្រេបយកចំណេះវិជ្ជា ដោយមិនព្រមបោះបង់នូវការសិក្សាដ៏គាប់ប្រសើរនេះឡើយ ក្នុងគោលបំណងមួយដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនេះឲ្យបានជោគជ័យជាស្ថាពរ។ ទន្ទឹមនឹងការបញ្ចប់បរិញ្ញាបត្រឲ្យបានជោគជ័យផងដែរ យើងខ្ញុំក៏មានគោលបំណងក្នុងការបញ្ចប់ការសិក្សាដោយការសរសេរសារណាមួយដ៏សមប្រកប ដែលជាលទ្ធផល និងជាស្នាដៃដ៏សំខាន់មួយសម្រាប់យើងខ្ញុំបន្ទាប់ពីបានសិក្សាក្រេបយកចំណេះដឹងអស់រយៈពេល ៤ឆ្នាំកន្លងមកនេះ។

ដោយឡែក ដោយសារតែមានការឆ្លងកាត់ការសិក្សាកន្លងមកនូវមុខវិជ្ជាសំខាន់ៗជាច្រើនក្នុងបរិញ្ញាបត្រនីតិសាស្ត្រ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជានីតិវិធីព្រហ្មទណ្ឌ ព្រោះថាមុខវិជ្ជានេះ គឺជាមុខវិជ្ជា ដែលសិក្សាទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ ដែលជាវិធានច្បាប់មួយដ៏សំខាន់ក្នុងចំណោមវិធានច្បាប់ផ្សេងៗទៀត សម្រាប់គ្រប់គ្រងសង្គម ដោយយើងខ្ញុំបានសិក្សាទាក់ទងនឹងនីតិវិធីដែលត្រូវអនុវត្តពិសេស គឺបញ្ញត្តិចែងអំពីនីតិវិធីនៃដំណាក់កាលទាំងបួនក្នុងរឿងព្រហ្មទណ្ឌ។ ពិសេសនោះ គឺយើងខ្ញុំបានសិក្សាអំពីដំណាក់កាលស៊ើបសួរដែលដឹកនាំនីតិវិធីដោយចៅក្រមស៊ើបសួរ ដែលជាដំណាក់កាលទី៣ នៃនីតិវិធីព្រហ្មទណ្ឌ។ អាស្រ័យហេតុនេះហើយ ទើបយើងខ្ញុំសម្រេចចិត្តជ្រើសរើសយក ប្រធានបទមួយគឺ **"ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ"** មកធ្វើការសិក្សាស្រាវជ្រាវ។

មូលហេតុ ដែលយើងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងឡើងនោះគឺ ដោយសារយើងខ្ញុំមានបំណងក្នុងការទទួលបាននូវបទពិសោធន៍ និងចំណេះដឹងកាន់តែស៊ីជម្រៅអំពីចៅក្រមស៊ើបសួរ ទោះបីជាប្រធានបទនេះត្រូវបានសិស្សច្បងជំនាន់មុនៗយកមកធ្វើការសរសេររួចក៏ដោយ។ ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាការស្រាវជ្រាវថ្មីនេះនឹងមានអ្វីដែលថ្មីខុសពីការស្រាវជ្រាវមុនៗ ដោយសារតែមានការបញ្ចូលនូវការអនុវត្តជាក់ស្តែងខ្លះៗ នៃការប្រព្រឹត្តទៅរបស់ចៅក្រមស៊ើបសួរមួយចំនួនមកបកស្រាយ។

ដោយហេតុថា ប្រធានបទ “**ចៅក្រមសើុបសួរនៅក្នុងរឿងព្រហ្មទណ្ឌ**” មានភាពធំទូលាយ ដូច្នេះយើងខ្ញុំសូមអភ័យទោសជាមុនប្រសិនបើមានភាពខ្វះខាតត្រង់ចំណុចណាមួយ ជាពិសេសរាល់ចំណុចដែលទាក់ទងនឹងការអនុវត្តជាក់ស្តែង ដោយហេតុថា យើងខ្ញុំជានិស្សិត ដែលពុំទាន់ឆ្លងកាត់ការអនុវត្តជាក់ស្តែងនៅឡើយ ដែលនាំឲ្យការស្រាវជ្រាវរបស់យើងខ្ញុំនៅមានកម្រិត។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏យើងខ្ញុំនៅតែសង្ឃឹមថាការស្រាវជ្រាវមួយនេះនឹងអាចផ្តល់នូវចំណេះដឹងបន្ថែមបន្តិចបន្តួចដល់អ្នកសិក្សា។

យើងខ្ញុំសូមទទួលការរិះគន់ដោយស្តាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យ បងៗ ប្អូនៗ មិត្តនិស្សិត ទាំងអស់ដែលបានអានស្នាដៃមួយនេះ និងរីករាយទទួលនូវរាល់កំហុសដែលកើតមានដោយអចេតនារបស់យើងខ្ញុំ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម**......១

**ជំពូកទី១**

**មូលហេតុដែលនាំឲ្យបើកការស៊ើបសួរ**

**ផ្នែកទី១៖ ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**......៥

**១.១. លក្ខខណ្ឌនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**......៦

១.១.១. ករណីបទឧក្រិដ្ឋ......៦

១.១.២. ករណីបទមជ្ឈិម......៧

**១.២. ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**......៨

**ផ្នែកទី២៖ ការបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**......៩

**២.១. បុគ្គលដែលអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**......៩

**២.២. នីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**......១០

២.២.១. ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា......១០

២.២.២. ការបង់ប្រាក់តម្កល់......១១

**ជំពូកទី២**

**សិទ្ធិអំណាចរបស់ចៅក្រមក្នុងការស៊ើបសួរ**

**ផ្នែកទី១៖ កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ**......១៤

**១.១. កិច្ចនីតិវិធីនៃការស៊ើបសួរ**......១៤

១.១.១. ការស្រាវជ្រាវទាក់ទងនឹងបុគ្គល......១៥

១.១.១.១. ការសួរចម្លើយជនត្រូវចោទ......១៥

១.១.១.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី......១៧

១.១.១.៣. ការស្តាប់ចម្លើយសាក្សី......១៨

១.១.១.៤. ការសួរតទល់......២០

១.១.២. ការស្រាវជ្រាវទាក់ទងនឹងវត្ថុ......២១

១.១.២.១. ការឆែកឆេរ និងការចាប់យកវត្ថុតាង ..................................................... ២១

១.១.២.២. ការធ្វើកោសល្យវិច័យ ..................................................... ២២

១.១.២.៣. ការស្ដាប់ទូរស័ព្ទ ..................................................... ២៤

**១.២. ការចាត់ឲ្យស៊ើបសួរជំនួស** ..................................................... ២៥

១.២.១. ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ ..................................................... ២៥

១.២.២. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ ..................................................... ២៦

១.២.២.១. ការស្ដាប់ចម្លើយសាក្សី ..................................................... ២៧

១.២.២.២. ការស្ដាប់ទូរស័ព្ទ ..................................................... ២៧

១.២.២.៣. ការធ្វើការឆែកឆេរ និងការចាប់យក ..................................................... ២៧

១.២.២.៤. ការឃាត់ខ្លួន ..................................................... ២៨

**ផ្នែកទី២៖ សិទ្ធិអំណាចក្នុងការប្រើវិធានការនិរន្តរាយ** ..................................................... ២៨

**២.១. វិធានការនិរន្តរាយ** ..................................................... ២៩

២.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន ..................................................... ២៩

២.១.១.១. លក្ខខណ្ឌ ..................................................... ២៩

២.១.១.២. ការអនុវត្តនៃដីកាបង្គាប់ឲ្យចូលខ្លួន ..................................................... ៣០

២.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន ..................................................... ៣០

២.១.២.១. លក្ខខណ្ឌ ..................................................... ៣១

២.១.២.២. ការអនុវត្តនៃដីកាបង្គាប់ឲ្យនាំខ្លួន ..................................................... ៣២

២.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន ..................................................... ៣២

២.១.៣.១. លក្ខខណ្ឌ ..................................................... ៣៣

២.១.៣.២. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន ..................................................... ៣៤

២.១.៤. ការឃុំខ្លួនបណ្ដោះអាសន្ន ..................................................... ៣៥

២.១.៤.១. លក្ខខណ្ឌ ..................................................... ៣៥

២.១.៤.២. ការអនុវត្តការឃុំខ្លួនបណ្ដោះអាសន្ន ..................................................... ៣៦

២.១.៤.៣. ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ........ ៣៧
ក. ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន ........ ៣៧
ខ. ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះអនីតិជន ........ ៣៨
**២.២. ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ........ ៣៨
២.២.១. ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៣៩
២.២.១.១. លក្ខខណ្ឌ ........ ៣៩
២.២.១.២. ការអនុវត្តដីកា ........ ៤២
២.២.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ........ ៤២
២.២.២.១. ការផ្ដួចផ្ដើមរបស់ចៅក្រមស៊ើបសួរ ........ ៤៣
២.២.២.២. បណ្ដឹងសុំកែប្រែដោយព្រះរាជអាជ្ញា ........ ៤៣
២.២.២.៣. បណ្ដឹងសុំកែប្រែដោយជនត្រូវចោទ ........ ៤៤

## ជំពូកទី៣
## ការបិទការស៊ើបសួរ

**ផ្នែកទី១៖ នីតិវិធីត្រៀមបិទការស៊ើបសួរ** ........ ៤៦
**១.១. ការបំពេញកិច្ចស៊ើបសួរបន្ថែម** ........ ៤៦
១.១.១. ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយព្រះរាជអាជ្ញា ........ ៤៧
១.១.១.១. លក្ខខណ្ឌ ........ ៤៧
១.១.១.២. ការអនុវត្ត ........ ៤៧
១.១.២. ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ........ ៤៨
១.១.២.១. លក្ខខណ្ឌ ........ ៤៨
១.១.២.២. ការអនុវត្ត ........ ៤៩
**១.២. ដីកាសន្និដ្ឋានស្ថាពរ** ........ ៥០
១.២.១. លក្ខខណ្ឌ ........ ៥០
១.២.២. នីតិវិធី ........ ៥១
**ផ្នែកទី២៖ ដីកាដំណោះស្រាយ** ........ ៥១

**២.១. ការបញ្ជូនទៅជំនុំជម្រះ** ..................................................... ៥២
២.១.១. មូលហេតុនាំឲ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ ..................................................... ៥២
២.១.២. នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ ..................................................... ៥២
២.១.៣. អានុភាពនៃបញ្ជូនទៅជំនុំជម្រះ ..................................................... ៥៣
**២.២. ការលើកលែងការចោទប្រកាន់** ..................................................... ៥៤
២.២.១. មូលហេតុនៃការលើកលែងការចោទប្រកាន់ ..................................................... ៥៤
២.២.២. នីតិវិធីនៃការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ..................................................... ៥៤
២.២.៣. អានុភាពនៃដីកាសម្រេចលើកលែងការចោទប្រកាន់ ..................................................... ៥៥
**សេចក្តីសន្និដ្ឋាន** ..................................................... ៥៦
**អនុសាសន៍** ..................................................... ៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

រូបវន្តបុគ្គលគ្រប់រូបដែលរស់នៅក្នុងសង្គម តែងតែមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកក្នុងសង្គមរបស់ពួកគេ ដោយសារការរស់នៅ គឺត្រូវតភ្ជាប់ជាមួយនឹងទំនាក់ទំនងសង្គម។ ជាក់ស្តែងដើម្បីការទំនាក់ទំនង ក៏ដូចជាការរស់នៅក្នុងសង្គមនីមួយៗ មានសុវត្ថិភាព របៀបរៀបរយល្អ ក្នុងថ្នាក់ដឹកនាំសង្គមនីមួយៗ តែងតែខិតខំ រិះរកនូវមធ្យោបាយ គោលនយោបាយ វិធីសាស្រ្តជាច្រើន ដើម្បីថែរក្សា បង្ការ ការពារ និងទប់ស្កាត់ នូវអំពើអវិជ្ជមាន ដែលបង្កឲ្យកើតមាននូវការប៉ះពាល់ ដល់ការរស់នៅ ទំនាក់ទំនង និងរបៀបរៀបរយនៃសង្គមរបស់ពួកគេ។ ជាការពិតណាស់ នៅក្នុងបណ្តាប្រទេស ជុំវិញពិភពលោក គេតែងតែបង្កើតនូវកម្មវិធីនយោបាយ យុទ្ធសាស្ត្រ ជាពិសេស គឺវិធានច្បាប់សម្រាប់ ប្រឆាំងទៅនឹងអំពើប្រព្រឹត្តខុសច្បាប់ផ្សេងៗ ដែលគេហៅថា បទល្មើសដែលបានកើតមានក្នុងសង្គមពួកគេ។ ទន្ទឹមនឹងនេះដែរ ក្នុងការគ្រប់គ្រងប្រទេសឲ្យមានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ រៀបរយល្អ វិធានច្បាប់បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំប្រទេសជាតិ។ បើក្រឡេកមកមើលប្រទេសកម្ពុជាយើងវិញម្តង ឃើញថាបន្ទាប់ពីសម័យសង្គ្រាមដ៏រាំរ៉ៃមក វិស័យជាច្រើនបានរីកលូតលាស់ល្អ។ ក្នុងនោះប្រសិនបើសង្កេតទៅលើវិស័យច្បាប់នៅប្រទេសកម្ពុជា ក៏មានភាពរីកចម្រើន និងវិវត្តទៅមុខកាន់តែប្រសើរឡើងផងដែរ។ ជាក់ស្តែងក្នុងការរក្សាសណ្តាប់ធ្នាប់នៅក្នុងសង្គមខ្មែរ អង្គការនីតិប្បញ្ញត្តិ បានបង្កើតច្បាប់ជាច្រើន ក្នុងការបង្ការ ការពារ និងប្រឆាំងទប់ស្កាត់ទៅនឹងបទល្មើស ដែលកើតមានក្នុងសង្គម។ ប៉ុន្តែ វិធានច្បាប់ដែលមានអានុភាពអនុវត្តទៅលើជីវភាពរស់នៅទូទៅនោះ គឺវិធានច្បាប់ព្រហ្មទណ្ឌដែលមានចែងនូវប្រភេទបទល្មើសជាច្រើននៅក្នុងនោះ។ ក្រមព្រហ្មទណ្ឌត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះនៅថ្ងៃទីនៅថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩។ កាន់តែពិសេសជាងនេះទៅទៀត ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវគោលការណ៍ទូទៅ ដើម្បីអនុវត្ត និងបានចែងនូវបទល្មើសជាច្រើនចាប់ពីបទ លហុ មជ្ឈិម និងបទឧក្រិដ្ឋ។ ដោយក្នុងក្រមព្រហ្មទណ្ឌចែងចេញជា ៦គន្ថី និង ៦៧២មាត្រា សុទ្ធសឹងតែកំណត់នូវឈ្មោះបទល្មើស ដែលកើតឡើងក្នុងជីវភាពរស់នៅ។ បើយើងក្រឡេកទៅមើលអតីតកាលមុននឹងមានវត្តមានក្រមព្រហ្មទណ្ឌនេះ នៅសម័យអន្តរកាល (១៩៩២-១៩៩៣) យើងប្រើប្រាស់នូវ បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ដែលត្រូវបានហៅថា ច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលមានតែចំនួន ៧៥មាត្រា តែប៉ុណ្ណោះ។[1] បើយើងប្រៀបធៀបប្រធានច្បាប់ទាំងពីរនេះ ឃើញថាក្រមព្រហ្មទណ្ឌបច្ចុប្បន្នមានលក្ខណៈប្រសើរ និងបាន

[1] បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល, ១០ កញ្ញា ១៩៩២។

ធ្វើឲ្យសង្គមខ្មែរយើងមានសណ្តាប់ធ្នាប់របៀបរៀបរយជាងមុន។ ទន្ទឹមនឹងនេះដែរ ដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តរឿងព្រហ្មទណ្ឌឲ្យមានប្រសិទ្ធភាពល្អ អង្គការនីតិប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ក៏បានបង្កើតឲ្យមាននូវក្រមនីតិវិធីព្រហ្មទណ្ឌ ដោយត្រូវបានអនុម័តនៅថ្ងៃ០៧ ខែមិថុនា ឆ្នាំ២០០៧។[2] គោលបំណងនៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺដើម្បីកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាម ដោយហ្មត់ចត់ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាព នៃបទល្មើសព្រហ្មទណ្ឌណាមួយ។[3] យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ សង្កេតឃើញថាមានការចែងទាក់ទងនឹងនីតិវិធីក្នុងការដោះស្រាយនៅពេលមានបទល្មើសព្រហ្មទណ្ឌកើតឡើង។ ជាក់ស្តែងដើម្បីជាភាពងាយស្រួលក្នុងការអនុវត្តនីតិវិធីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបែងចែកនូវនីតិវិធីសំខាន់ៗចំនួនបួន ដែលមានដូចជា ដំណាក់កាលនគរបាលយុត្តិធម៌ ដំណាក់កាលចោទប្រកាន់ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ដោយនៅពេលមានបទល្មើសណាមួយកើតឡើង ត្រូវអនុវត្តតាមដំណាក់កាលទាំងបួននេះ។ យ៉ាងណាមិញ ទោះបីជាដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌសំខាន់ៗមានចំនួន៤ ក៏ដោយ ប៉ុន្តែក្នុងបរិបទនៃកិច្ចស្រាវជ្រាវនេះ គឺនឹងធ្វើការស្រាវជ្រាវត្រឹមតែដំណាក់កាលស៊ើបសួរ ពោលគឺស្រាវជ្រាវតែអំពី សិទ្ធិអំណាច និងតួនាទីចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ តែប៉ុណ្ណោះ។ នៅក្នុងដំណាក់កាលស៊ើបសួរនេះទៀតសោត គឺជាដំណាក់កាល ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ។

## ២. ចំណោទបញ្ហា នៃការស្រាវជ្រាវ

នៅក្នុងដំណាក់កាលស៊ើបសួរ តើចៅក្រមស៊ើបសួរគឺជាអ្នកណា? ជាការពិតណាស់ នៅក្នុងប្រព័ន្ធយុត្តាធិការ នៃព្រះរាជាណាចក្រកម្ពុជា ចំពោះរឿងព្រហ្មទណ្ឌ បានបែងចែកចៅក្រមជាពីរ ដែលមានដូចជា ទីមួយ ចៅក្រមអយ្យការ ឬ អាចហៅបានថាព្រះរាជអាជ្ញា និងទីពីរ ចៅក្រមអសនៈ ដែលក្នុងនោះមានជាចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។ ដោយឡែក ចៅក្រមស៊ើបសួរ គឺជាចៅក្រមដែលបំពេញការងារនៅក្នុងមន្ទីរស៊ើបសួរនៃតុលាការជាន់ទាប ដែលជាតុលាការរាជធានីខេត្ត-ក្រុង។ ដើម្បីជាការឆ្លើយតបទៅកាន់ចំណោទបញ្ហាខាងលើ ក្នុងការស្រាវជ្រាវយើងនឹងធ្វើការបកស្រាយអំពីចៅក្រមស៊ើបសួរ ដែលគាត់មានតួនាទីធ្វើការបើកការស៊ើបសួរ ដើម្បីធ្វើកិច្ចស៊ើបសួរ ស្រាវជ្រាវ ស្វែងរកភស្តុតាងទាំងដាក់បន្ទុក និងដោះបន្ទុកនៅក្នុងរឿងព្រហ្មទណ្ឌ ដែលធ្វើឡើងបន្ទាប់ពីទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ហើយចៅក្រមស៊ើបសួរនឹងធ្វើការបិទបញ្ចប់ការស៊ើបសួរនៅពេលបំពេញកិច្ចស៊ើបសួរចប់ ដោយមានចេញនូវដីកាដំណោះស្រាយ។ គួរបញ្ជាក់ថា ចំពោះការប្រតិបត្តិនូវការងាររបស់ខ្លួននេះ ចៅក្រមស៊ើបសួរត្រូវបានប្រធានសាលាដំបូងចាត់តាំងចៅក្រមយ៉ាងតិច ២(ពីរ) រូប តាមដីកាសម្រេចឲ្យបំពេញតួនាទីជាចៅក្រមស៊ើបសួរនៅមន្ទីរស៊ើបសួរនៃតុលាការ

[2] ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នស/រកម/០៨០៧/០២៤, ៣០ វិច្ឆិកា ឆ្នាំ២០០៩។

[3] មាត្រា១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។

ព្រហ្មទណ្ឌនៃសាលាដំបូង។[4] ក្នុងន័យនេះ គឺចៅក្រមស៊ើបសួរបំពេញកិច្ចការរបស់ខ្លួនបានតាមរយៈការចាត់ចែងប្រធានសាលាដំបូងដែលចៅក្រមនោះស្ថិតនៅ។

## ៣. គោលបំណងនៃការស្រាវជ្រាវ

ចំពោះគោលបំណងក្នុងការស្រាវជ្រាវ ប្រធានបទ **"ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ"** នេះ គឺចង់សិក្សាឲ្យច្បាស់ពីតួនាទី និងសិទ្ធិអំណាចចៅក្រមស៊ើបសួរ ក្នុងការបើកការស៊ើបសួរ និងការបិទការស៊ើបសួរ។ ដោយសារតែ ក្នុងដំណាក់កាលស៊ើបសួរជាដំណាក់កាលមួយមានលក្ខណៈស្មុគស្មាញ និងមានវិសាលភាពធំជាងដំណាក់កាលផ្សេងៗទៀត។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

យ៉ាងណាមិញ ទោះបីជាដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌសំខាន់ៗ មានចំនួន បួនក៏ដោយ ប៉ុន្តែ ក្នុងបរិបទ ក៏ដូចជាដែនកំណត់នៃកិច្ចការស្រាវជ្រាវនេះ គឺនឹងធ្វើការស្រាវជ្រាវត្រឹមតែដំណាក់កាលស៊ើបសួរតែប៉ុណ្ណោះ ដែលជាដំណាក់កាលសំខាន់ក្នុងចំណោមដំណាក់កាលទាំងបួន។ មានន័យថា ការស្រាវជ្រាវធ្វើឡើងចាប់ផ្តើមត្រឹមពី ការបើកការស៊ើបសួររបស់ចៅក្រមស៊ើបសួរ និងបញ្ចប់ទៅវិញ ត្រឹមការបិទការស៊ើបសួរដោយការចេញនូវដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ សូមបញ្ជាក់ផងដែរថា កិច្ចការស្រាវជ្រាវមួយនេះ គឺមិនបានលើកយកនូវនីតិវិធី ស្តីពីមោឃៈភាពនៃការស៊ើបសួរ និងនីតិវិធីនៅក្នុងសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍យកមកសិក្សានោះទេ។

## ៥. សារៈសំខាន់ នៃការស្រាវជ្រាវ

តាមរយៈប្រធានបទនៃសារណា ស្តីអំពី **"ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ"** នេះ នឹងអាចផ្តល់សារប្រយោជន៍យ៉ាងច្រើនទាក់ទងនឹងការយល់ដឹងកាន់តែច្បាស់អំពីតួនាទី និងអំណាចរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ ពោល គឺទទួលបានចំណេះដឹងទាក់ទងនឹង ការបើក ការបិទ និងវិធានស្រាវជ្រាវ ដែលចៅក្រមស៊ើបសួរធ្វើឡើងនៅក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលមានដូចជា ការសួរចម្លើយ ការស្តាប់ចម្លើយ ការចេញដីកា និងការប្រើប្រាស់វិធានការនិរន្តរាយផ្សេងៗ របស់ចៅក្រមស៊ើបសួរ ដើម្បីធ្វើឲ្យការប្រព្រឹត្តទៅនៃកិច្ចរបស់ខ្លួនដំណើរការទៅដោយរលូន។ កាន់តែពិសេសជាងនេះទៅទៀត គឺប្រធានបទនេះ ជួយឲ្យទទួលបាននូវចំណេះដឹងទាក់ទងនឹងការអនុវត្តជាក់ស្តែងមួយចំនួន ក្នុងដំណាក់កាលនេះ ថាតើការប្រព្រឹត្តទៅក្នុងកិច្ចរបស់ចៅក្រមស៊ើបសួរនេះមានលក្ខណៈយ៉ាងដូចម្តេចខ្លះ? លើសពីនេះទៅទៀត នៅក្នុងចំណុចបញ្ចប់នៃការស្រាវជ្រាវនេះ នឹងទទួលបានការយល់ដឹងអំពីផលវិបាក និងចំណុចខ្វះខាតមួយចំនួនទាក់ទងនឹងការអនុវត្តនីតិវិធីរបស់ចៅក្រមស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរ។

[4] មាត្រា២០ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ,លេខ នស/រកម/០៧១៤/០១៥ ,១៦ កក្កដា ឆ្នាំ២០១៤។

## ៦. រចនាសម្ព័ន្ធ នៃការស្រាវជ្រាវ

ទាក់ទងទៅនឹងប្រធាបទ “**ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ**” នៅក្នុងចំណុចបន្ទាប់ នឹងធ្វើការបកស្រាយនូវចំណុចសំខាន់ទាក់ទងនឹង៖

(**ជំពូកទី១**) **មូលហេតុដែលនាំឲ្យបើកការស៊ើបសួរ**

(**ជំពូកទី២**) **សិទ្ធិអំណាចរបស់ចៅក្រមក្នុងការស៊ើបសួរ**

(**ជំពូកទី៣**) **ការបិទការស៊ើបសួរ។**

# ជំពូកទី១
# មូលហេតុដែលនាំឲ្យ
# បើកការស៊ើបសួរ

# ជំពូកទី១
# មូលហេតុដែលនាំឲ្យបើកការស៊ើបសួរ

ដំណាក់កាលស៊ើបសួរ គឺជាដំណាក់កាលដែលធ្វើឡើងក្នុងគោលបំណងស្រាវជ្រាវស្វែងរកនូវអត្ថិភាព ឬ នត្ថិភាពនៃបទល្មើសនៅក្នុងរឿងក្តីមួយ ដែលមិនមែនជាការស្វែងរកត្រឹមតែអត្ថិភាពនៃបទល្មើស ដើម្បីចោទប្រកាន់ដូចព្រះរាជអាជ្ញានោះទេ។ តើការស៊ើបសួរត្រូវបានបើកដោយសារមូលហេតុអ្វីខ្លះ? ការស៊ើបសួរត្រូវបានបើក ដោយសារមូលហេតុចំនួនពីរសំខាន់ៗគឺ (**ផ្នែកទី១**) **ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ** និង (**ផ្នែកទី២**) **ការបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។**

## ផ្នែកទី១៖ ការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ក្រោយពេលចៅក្រមស៊ើបសួរទទួលបានបណ្តឹងពីព្រះរាជអាជ្ញារួចមក ដោយមានការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចៅក្រមស៊ើបសួរអាចចាប់ផ្តើមបាននូវការស៊ើបសួររបស់ខ្លួន ដោយចៅក្រមស៊ើបសួរត្រូវតែបំពេញកិច្ចស៊ើបសួរ តែត្រឹមចំណុចដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាប៉ុណ្ណោះ។[5] មានន័យថា នៅពេលចៅក្រមស៊ើបសួរទទួលបានបណ្តឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវ ឬ អាចធ្វើការស៊ើបសួរតែអំពីអង្គហេតុនៅក្នុងដីកានោះតែប៉ុណ្ណោះ។ ដូចនេះ លោកពុំអាចធ្វើការស៊ើបសួរទៅលើអង្គហេតុណាមួយក្រៅពីចំណុចដែលបានកំណត់នៅក្នុងដីការបស់ព្រះរាជអាជ្ញាបានឡើយ។ ឧទាហរណ៍៖ ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីបទ "ឆបោក" បន្ទាប់មកព្រះរាជអាជ្ញាបានធ្វើការបញ្ជូនដីកានេះ ទៅកាន់ចៅក្រមស៊ើបសួរដើម្បីបើកការស៊ើបសួរ។ ប៉ុន្តែនៅពេលដំណើរការនៃកិច្ចស៊ើបសួរប្រព្រឹត្តទៅ ស្រាប់តែចៅក្រមស៊ើបសួរបានពិនិត្យឃើញនូវអង្គហេតុថ្មីផ្សេងមួយទៀត គឺ "បទលួច" បន្ថែមទៀត។ ដូច្នេះ ចៅក្រមស៊ើបសួរមិនអាចធ្វើការស៊ើបសួរទៅលើរឿងដែលជាអង្គហេតុថ្មីនោះឡើយ លុះត្រាតែមាន "ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម" ពីព្រះរាជអាជ្ញាថ្មីមួយទៀត ដែលធ្វើការចោទប្រកាន់ទៅលើបទល្មើសថ្មីខាងលើ។ ហេតុដូច្នេះ ក្នុងករណីដែលនៅក្នុងអំឡុងពេលធ្វើការស៊ើបសួរមានការស្វែងរកឃើញនូវអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។

បន្ទាប់មក ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ប៉ុន្តែចៅក្រមស៊ើបសួរពុំចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

[5] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

បន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះគឺជាស្ថានទម្ងន់ទោសលើបទល្មើសក្នុងអង្គហេតុមុន ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកដំបូង។[6] ជាក់ស្តែង ក្នុងករណីដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពី "បទលួច" តាមរយៈមាត្រា៣៥៣នៃក្រមព្រហ្មទណ្ឌ។ ដោយឡែក នៅពេលដែលចៅក្រមស៊ើបសួរបានបើកការស៊ើបសួរស្រាប់លេចឃើញនូវ "បទលួចដែលមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា" តាមរយៈមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរទៅលើបទល្មើសនោះបាន ដោយមិនចាំបាច់ស្នើសុំឲ្យមាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញានោះឡើយ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទនៅក្រោមការពិនិត្យនៃបទល្មើសដែលបានលេចឡើងនៅពេលដែលខ្លួនបានបើកការស៊ើបសួរនោះផងដែរ។ ជាងនេះទៅទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរអាចត្រូវចេញបាន លុះត្រាតែបំពេញនូវលក្ខខណ្ឌ និងទម្រង់ផងដែរ។

### ១.១. លក្ខខណ្ឌនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាសេចក្តីមួយដែលព្រះរាជអាជ្ញាលោកធ្វើការស្នើសុំទៅកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការស៊ើបសួរទៅលើបទល្មើសដែលបានកើតឡើង។ ការស៊ើបសួរអាចបើកប្រឆាំងលើបុគ្គលម្នាក់ ឬ ច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬ ប្រឆាំងទៅលើអញ្ញាតជន។[7] ការស៊ើបសួរនេះទៀតសោត ត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញាដោយអនុលោមតាមមាត្រា ៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ (ការបើកការស៊ើបសួរ) នេះ។[8] ដីកានេះអាចចេញបាន លុះត្រាតែត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនដែលអាចធ្វើឲ្យការបើកការស៊ើបសួរអាចធ្វើទៅបាន ដោយផ្អែកទៅតាមប្រភេទនៃបទល្មើសដែលក្នុងនោះមានដូចជា (១.១.១) **ក្នុងករណីបទឧក្រិដ្ឋ** និង (១.១.២) **ក្នុងករណីបទមជ្ឈិម**។

#### ១.១.១. ករណីបទឧក្រិដ្ឋ

បទឧក្រិដ្ឋ គឺជាប្រភេទបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈធ្ងន់ធ្ងរ ដែលបានកំណត់នូវអតិបរមានៃទោសដាក់ពន្ធនាគារ ក្រោមរូបភាព ទី១.ជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០ឆ្នាំ ទី២.ជាទោសដាក់ពន្ធនាគារអស់មួយជីវិត។[9] នៅពេលមានបទឧក្រិដ្ឋកើតឡើង ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា តម្រូវឲ្យមានការបើកការស៊ើបសួរជាចាំបាច់ ដែលជាកាតព្វកិច្ច ពោលគឺមិនអាចធ្វើតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ឬ ដីកាបង្គាប់ឲ្យបង្ហាញខ្លួនភ្លាមបាននោះទេ គឺត្រូវតែឆ្លង

[6] មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[7] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[8] មាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[9] មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

កាត់ការស៊ើបសួរសិន។ មូលហេតុដែលបទឧក្រិដ្ឋតម្រូវឲ្យបើកការស៊ើបសួរជាកាតព្វកិច្ច ដោយសារតែបទឧក្រិដ្ឋជាបទល្មើសមានលក្ខណៈធ្ងន់ធ្ងរ ឬ មានលក្ខណៈស្មុគស្មាញ ជាការប្រឈមមុខទៅនឹងការដាក់ពន្ធនាគារមានរយៈពេលយូរច្រើនឆ្នាំ។ ហេតុនេះទាមទារឲ្យមានសមត្ថកិច្ចច្រើនក្នុងការចូលរួមដើម្បីជៀសវាងការសម្រេចសេចក្តីខ្វះខាត ដែលធ្វើឲ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិសេរីភាពរបស់បុគ្គល ផ្ទុយទៅនឹងគោលការណ៍សេរីភាពជាមូលដ្ឋាន។ ចំពោះបទឧក្រិដ្ឋនេះដែរ ព្រះរាជអាជ្ញាត្រូវតែធ្វើបណ្តឹងទៅចៅក្រមស៊ើបសួរដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីបើកការស៊ើបសួរជាកាតព្វកិច្ចដាច់ខាត។[10] ហើយក្នុងករណីនេះ ការស៊ើបសួរត្រូវតែធ្វើដោយខានមិនបានចំពោះបទឧក្រិដ្ឋ។[11] ផ្អែកតាមស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជាតម្រូវឲ្យមានការបើកការស៊ើបសួរជាចាំបាច់ ដើម្បីគោរពនូវគោលការណ៍ទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងគោលការណ៍សេរីភាពជាមូលដ្ឋានដែលសន្ធិសញ្ញា ឬ ក៏ច្បាប់មួយចំនួនបានប្រគល់ជូនប្រជាពលរដ្ឋផងដែរ។[12] ឧទាហរណ៍៖ មាន “បទឃាតកម្ម” មួយបានកើតឡើងហើយមានវត្ថុតាងមូលសព្វគ្រប់ហើយ ទោះបីជាយ៉ាងណាក៏ដោយ ព្រះរាជអាជ្ញាមិនអាចធ្វើការចោទប្រកាន់តាមរយៈ ដីកាបញ្ជូនរឿងទៅជំនុំជម្រះភ្លាម និងដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់បានទេ គឺត្រូវតែចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរដែរ។

### ១.១.២. ករណីបទមជ្ឈិម

បទមជ្ឈិម គឺជាប្រភេទបទល្មើសព្រហ្មទណ្ឌដែលមានលក្ខណៈនៃទោសស្រាលជាងបទឧក្រិដ្ឋ ហើយត្រូវបានកំណត់អតិបរមានៃទោសដាក់ពន្ធនាគារត្រូវទទួលរង មានរយៈពេលលើសពី៦ថ្ងៃ និងក្រោម ឬ ស្មើនឹង៥ឆ្នាំ។[13] នៅក្នុងករណីបទមជ្ឈិមនេះដែរ ព្រះរាជអាជ្ញាមានជម្រើសក្នុងការធ្វើការចោទប្រកាន់ ក្រៅពីធ្វើការចោទប្រកាន់តាមរយៈការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ដោយព្រះរាជអាជ្ញាគាត់អាចធ្វើការថ្លឹងថ្លែងក្នុងការចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទៅកាន់ចៅក្រមស៊ើបសួរ ដើម្បីបើកការស៊ើបសួរ។ ក្នុងករណីដែលគាត់យល់ឃើញថា រឿងក្តីមានលក្ខណៈស្មុគស្មាញ ឬ មិនទាន់មូលនៅឡើយ ឬ នៅតែជាអញ្ញាតជន[14] ដែលមិនអាចធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមបានទេ គាត់អាចធ្វើការបើកការស៊ើបសួរដើម្បីស្វែងរកការពិត ឬ ស្វែងរកនូវពិរុទ្ធភាពដើម្បីសម្តែងឲ្យឃើញនូវការពិត។

---

[10] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[11] មាត្រា១២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[12] បញ្ញត្តិនេះចែងស្របតាមគោលការណ៍សេរីភាពមូលដ្ឋាន ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ត្រូវបានអនុម័តដោយអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ និងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[13] ក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧,មាត្រា ៤៧។

[14] អញ្ញាតជន គឺជាជនដែលគេ មិនស្គាល់អត្តសញ្ញាណ ឬ មិនទាន់ស្គាល់នូវសារតា។

យ៉ាងណាមិញ ប្រសិនបើរឿងនោះមិនទាន់មូល ឬ មិនទាន់សម្តែងឲ្យឃើញនូវការពិតទេនោះ ប៉ុន្តែព្រះរាជអាជ្ញាបានធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមក៏ដោយ នៅពេលរឿងនោះទៅដល់ចៅក្រមជំនុំជម្រះ ហើយចៅក្រមជំនុំជម្រះគាត់យល់ថារឿងនេះមិនទាន់មូលនៅឡើយ ចៅក្រមជំនុំជម្រះបញ្ជូនត្រលប់មកព្រះរាជអាជ្ញាវិញ ដើម្បីឲ្យព្រះរាជអាជ្ញាធ្វើការចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដែរ។ ទោះជាយ៉ាងណាក៏ដោយ ការស៊ើបសួរអាចធ្វើទៅបានលុះត្រាតែរឿងនេះមិនទាន់មូល ឬ មិនទាន់បង្ហាញនូវពិរុទ្ធភាពនៅឡើយ។ ដូច្នេះ ព្រះរាជអាជ្ញានឹងធ្វើការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដើម្បីឲ្យចៅក្រមស៊ើបសួរធ្វើការស្រាវជ្រាវរកនូវពិរុទ្ធភាព ឬ ស្វែងរកនូវអត្ថិភាព និងនត្ថិភាពនៃបទល្មើសនោះ។ ឧទាហរណ៍៖ បុគ្គលម្នាក់បានលួចទូរស័ព្ទមួយគ្រឿង(ពុំមានភស្តុតាងច្បាស់លាស់)។ ប៉ុន្តែដោយហេតុថាបុគ្គលនោះបានរត់គេចខ្លួនបាត់ ដោយពុំទាន់ស្វែងរកខ្លួនឃើញ ដូច្នេះ ព្រះរាជអាជ្ញាត្រូវធ្វើការបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ លោកមិនអាចធ្វើការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬ ការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាមបានឡើយ។

### **១.២.ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

ទម្រង់ គឺសំដៅលើក្បួនខ្នាតក្នុងការប្រតិបត្តិ ឬ ក៏ការតាក់តែងអ្វីមួយប្រកបដោយភាពច្បាស់លាស់ ដែលអាចជាទម្រង់នៃក្រដាសស្នាម ឬ ក៏ជាក្បួនសម្រាប់ធ្វើអ្វីមួយ។ នៅចំណុចនេះ ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌអំពីទម្រង់នេះ គឺតម្រូវឲ្យត្រូវប្រតិបត្តិតាមយ៉ាងខ្ជាប់ខ្ជួន ដើម្បីតាក់តែងនូវទម្រង់ដីកានោះឲ្យមានលក្ខណៈពេញលេញតាមច្បាប់ និងមានអានុភាពតាមផ្លូវច្បាប់ផងដែរ។ លើសពីនេះទៅទៀត ដីកានេះត្រូវបានតាក់តែងឡើងដោយព្រះរាជអាជ្ញាក្នុងការធ្វើប្តឹងទៅកាន់ចៅក្រមស៊ើបសួរដើម្បីឲ្យបើកការស៊ើបសួរ។ តាមការអនុវត្តជាក់ស្តែង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរធ្វើឡើងដោយព្រះរាជអាជ្ញាក៏ពិតមែន ប៉ុន្តែការរៀបរៀងទម្រង់នៃដីកានេះ គឺធ្វើឡើងដោយក្រឡាបញ្ជីដែលជាជំនួយការរបស់ព្រះរាជអាជ្ញា គឺគាត់ជាអ្នកធ្វើពង្រៀងដីកានេះ។

បន្ទាប់មក គាត់យកដីកានេះជូនព្រះរាជអាជ្ញាដើម្បីត្រួតពិនិត្យមើលបន្ថែមទៀត ប្រសិនបើត្រឹមត្រូវហើយនោះ គាត់នឹងធ្វើការចុះហត្ថលេខា ព្រមទាំងវាយត្រាផងដែរ។ ជាងនេះទៅទៀត នៅក្នុងទម្រង់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ ត្រូវសរសេរនូវខ្លឹមសារមួយចំនួនរួមមាន៖

- សេចក្តីសង្ខេបនៃអង្គហេតុ
- ការកំណត់ឈ្មោះបទល្មើស
- ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង
- ឈ្មោះបុគ្គល ដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

នៅផ្នែកខាងក្រោមនៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាផងដែរ។[15] ទម្រង់នៃដីកានេះមានលក្ខណៈដាច់ខាត ដែលទាមទារត្រូវតែគោរព។ បើពុំដូច្នេះទេ ដីកាបញ្ជូនរឿងឲ្យស៊ើបសួរនេះ ត្រូវទុកជាមោឃៈ ឬ ទុកជាអាសារឥតការ។[16]

## ផ្នែកទី២៖ ការបើកការស៊ើបសួរដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

តើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរជាអ្វី? ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជារបបគតិយុត្តមួយដែលបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីការពារបុគ្គលមួយចំនួនដែលត្រូវបានទទួលរងនូវការខូចខាត ឬ បាត់បង់នូវផលប្រយោជន៍ដែលបណ្តាលមកពីជនបង្ក ដែលបង្កើតឲ្យមាននូវព្យសនកម្មនៃបទល្មើសនៅពេលបច្ចុប្បន្ន។ ហើយព្យសនកម្មនេះអាចជាព្យសនកម្មខាងសម្ភារ រូបរាងកាយ និងផ្លូវចិត្ត។ ជាក់ស្តែង ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវធ្វើទៅបាននៅរាល់គ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ ជាពិសេសនៅដំណាក់កាលចៅក្រមស៊ើបសួរ បុគ្គលគ្រប់រូបដែលបានប្រកាសថាខ្លួនជាជនរងគ្រោះ អាចធ្វើការប្រកាសខ្លួន ឬ ធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរបានគ្រប់ពេលវេលាផងដែរ។[17]

### ២.១. បុគ្គលដែលអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

តើអ្នកណាអាចធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន? ជាទូទៅ ជនដែលអាចធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាជនរងគ្រោះដែលទទួលរងព្យសនកម្មពីបទល្មើសដែលបានប្រព្រឹត្តឡើង។ ចំពោះជនរងគ្រោះដែលទទួលរងព្យសនកម្មពីបទល្មើសព្រហ្មទណ្ឌ អាចប្តឹងបរិហារពីបទល្មើសដែលកើតមកលើខ្លួនបានដើម្បីឲ្យជនបង្កនោះទទួលរងនូវទោស។ ប៉ុន្តែប្រសិនបើជនរងគ្រោះនោះ យល់ឃើញថាខ្លួនត្រូវបានបាត់បង់នូវផលប្រយោជន៍អ្វីមួយពីបទល្មើសដែលបានកើតឡើងនោះ ក៏អាចធ្វើការប្តឹងទាមទារនូវសំណងនៃខូចខាតដែលខ្លួនបានបាត់បង់ផងដែរ ដោយធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ជនគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ចតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះបាន ហើយពាក្យបណ្តឹងដែលដាក់ទៅចៅក្រមស៊ើបសួរក្នុងនាមជនរងគ្រោះដោយមេធាវីរបស់សាមីខ្លួន។[18] ម្យ៉ាងវិញទៀត ជនរងគ្រោះនោះមានសិទ្ធិក្នុងការទាមទារសំណងនៃការខូចខាត អាចធ្វើឡើងគ្រប់ដំណាល់កាលនៃនីតិវិធីព្រហ្មទណ្ឌទាំងអស់ ប្រសិនបើខ្លួនយល់ឃើញថា មានការប៉ះពាល់នូវផល

[15] ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានកំណត់ក្នុង ឧបសម្ព័ន្ធទី១។

[16] មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[17] មាត្រា១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧, មាត្រា១៣៧។

[18] មាត្រា១៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ប្រយោជន៍របស់ខ្លួន។ របបគតិយុត្តថ្មីនេះ ក្រមនីតិវិធីព្រហ្មទណ្ឌបាន បង្កើតឡើងដែលអាចហៅបានថា "ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី" ដែលត្រូវបានកើតឡើងនៅពេល ដែលព្រះរាជអាជ្ញាធ្វើការតម្កល់រឿងទុកមិនចាត់ការទៅលើរឿងក្តីនោះ ដែលខ្លួនបានប្តឹងតាមរយៈបណ្តឹងសាមញ្ញ[19] ។ មួយវិញទៀត នៅពេលដែលព្រះរាជអាជ្ញាបានធ្វើការតម្កល់រឿងទុកមិនចាត់ការ ដោយសារតែគាត់យល់ឃើញថាអំពើដែលកើតឡើងមិនគួរធ្វើការចោទប្រកាន់នោះទេ (រឿងមានលក្ខណៈតូចតាចពេក ដូចជាលួចស្វាយ ជាអាទិ៍) ដូច្នេះ ជនរងគ្រោះអាចមានជម្រើសដើម្បីទទួលនូវសំណងនៃការខូចខាតបាន គឺគាត់ត្រូវធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ។ កាន់តែពិសេសជាងនេះទៅទៀត គោលបំណងដែលបង្កើតនូវរបបគតិយុត្តមួយនេះឡើង គឺដោយហេតុថាដើម្បីការពារផលប្រយោជន៍របស់ជន ដែលទទួលរងនូវការបំពានពីបទល្មើស។ ម៉្យាងវិញទៀត នៅពេលដែលជននោះមិនអាចទទួលបានការចំណាត់ការពីព្រះរាជអាជ្ញាទេ គាត់នឹងមិនអស់ផ្លូវក្នុងការប្តឹងទាមទារតវ៉ានូវសំណងខូចខាតនោះទេ។ ពោល គាត់ក៏អាចធ្វើតាមរបបគតិយុត្តថ្មីនេះបានដែរ ដែលមានកំណត់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ។ មួយវិញទៀត ការប្តឹងទៅចៅក្រមស៊ើបសួរ គឺជាការដាក់ឲ្យបណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ បើយោងតាមមាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មានន័យថា ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម អាចដាក់ពាក្យប្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ ដែលក្នុងនោះ ពាក្យបណ្តឹងរបស់ជនដែលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមានអានុភាពជាការប្តឹងដល់ចៅក្រមស៊ើបសួរ អំពីបណ្តឹងអាជ្ញានៅក្នុងលក្ខខណ្ឌដែលបញ្ញត្តិដោយក្រមនេះ ដែលគេហៅថា "ការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះ"។ ផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់នូវនីតិវិធីមួយចំនួនដោយយោងតាម មាត្រា១៣៩ និងមាត្រា១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

### ២.២. នីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នៅក្នុងនីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវអនុវត្តនូវនីតិវិធីសំខាន់ចំនួនពីរ ដែលនៅក្នុងនោះមានដូចជា (**២.២.១**)**ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា** និង (**២.២.២**)**ការបង់ប្រាក់តម្កល់**។

#### ២.២.១. ការបញ្ជូនបណ្តឹងទៅព្រះរាជអាជ្ញា

ចំពោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទាក់ទងនឹងអំពើដែលខ្លួនបានទទួលរងព្យសនកម្មនៅមុខចៅក្រមស៊ើបសួរ។ ឧទាហរណ៍៖ នៅពេល ស្ត្រីម្នាក់ បានទទួលរងនូវព្យសនកម្មពី

[19] បណ្តឹងសាមញ្ញ គឺជាបណ្តឹងដែលធ្វើឡើងតាមនីតិវិធីដាក់ពាក្យបណ្តឹងធម្មតា ដែលធ្វើឡើងដើម្បីប្តឹងទាមទារ ឬ ប្តឹងបរិហារ ទៅលើបទល្មើសព្រហ្មទណ្ឌមួយបានកើតឡើង។

អំពើឆបោក ដោយខាតបង់នូវទឹកប្រាក់ជាច្រើន ប៉ុន្តែនៅដំណាក់កាលចោទប្រកាន់ ព្រះរាជអាជ្ញាបានធ្វើការតម្កល់រឿងទុកឥតចាត់ការ នាំឲ្យស្ត្រីនោះអាចធ្វើការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយតាមរយៈការដាក់បណ្តឹងអាជ្ញាឲ្យមានចលនាដោយជនរងគ្រោះដើម្បីប្តឹងជនបង្កនោះបាននៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្រោយពីទទួលពាក្យបណ្តឹង ចៅក្រមស៊ើបសួរ ត្រូវធ្វើការពិនិត្យបណ្តឹងនោះថាតើត្រឹមត្រូវ ឬ អត់? ករណីនេះចៅក្រមមានសិទ្ធិក្នុងការទទួលយក ឬ ច្រានចោលពាក្យបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបាន។ ជាក់ស្តែង បើចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹងរួចហើយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនបណ្តឹងនេះទៅកាន់ព្រះរាជអាជ្ញា។ តាមរយៈសកម្មភាពនេះបញ្ជាក់ឲ្យឃើញថាបណ្តឹងដែលតាំងខ្លួនជាដើមណ្តឹងរដ្ឋប្បវេណីត្រូវធ្លាក់ទៅព្រះរាជអាជ្ញា ដោយព្រះរាជអាជ្ញាត្រូវប្តឹងទៅចៅក្រមស៊ើបសួរវិញតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ នេះបើយោងតាមមាត្រា១៣៩ នៃក្រមនីតិវិធីនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនោះផងដែរ ព្រះរាជអាជ្ញាអាចសុំឲ្យចៅក្រមស៊ើបសួរមិនឲ្យធ្វើការស៊ើបសួរបាន ក្នុងករណីដែលបណ្តឹងអាជ្ញាត្រូវបានផុតរលត់[20] ឬ ករណីដែលអំពើដែលប្តឹងនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌ ។

នៅក្នុងករណី ដែលព្រះរាជអាជ្ញាបានស្នើសុំកុំឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរនោះ ចៅក្រមស៊ើបសួរមានជម្រើសពីរយ៉ាងគឺ៖

- ប្រសិនបើសម្រេចមិនធ្វើការស៊ើបសួរទេ នាំឲ្យត្រូវចេញដីកាសម្រេចភ្ជាប់ជាមួយសំអាងហេតុបញ្ជាក់ពីមូលហេតុដែលខ្លួនសម្រេចមិនធ្វើការស៊ើបសួរដើម្បីធ្វើការជូនដំណឹងទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណីជាបន្ទាន់ ។
- ប៉ុន្តែចំពោះករណីដែលចៅក្រមស៊ើបសួរ លោកសម្រេចថាធ្វើការស៊ើបសួរ នាំឲ្យចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុបញ្ជាក់ពីមូលហេតុដូចគ្នាទៅឲ្យព្រះរាជអាជ្ញាជាបន្ទាន់។[21]

សូមបញ្ជាក់ផងដែរថា បណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាយន្តការថ្មីដែលទើបបញ្ចូលនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះ។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីត្រូវធ្វើការបង់ប្រាក់តម្កល់ទុកទៅតាមចៅក្រមស៊ើបសួរជាអ្នកយល់ឃើញ។

### ២.២.២. ការបង់ប្រាក់តម្កល់

នៅក្នុងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើបានដោយផ្អែកទៅលើធនធាននៃដើមបណ្តឹងរដ្ឋប្បវេណី និងទៅលើការលំបាកនៃរឿងដែលអាចយល់ឃើញជាមុន។ ចៅក្រមស៊ើបសួរកំណត់តាមរយៈដីកា

[20] បណ្តឹងអាជ្ញារលត់ មានន័យថាព្រះរាជអាជ្ញាមិនអាចធ្វើចំណាត់ការទៅលើបណ្តឹងនោះបានទៀតទេ។

[21] មាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

សម្រេចនូវចំនួនទឹកប្រាក់ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង់ ព្រមទាំងរយៈពេលដែលត្រូវបង់ប្រាក់នេះផងដែរ។[22] នៅក្នុងន័យនេះគឺចៅក្រមស៊ើបសួរក៏អាចមិនតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបង់ប្រាក់ក៏បានដែរ ប្រសិនបើគាត់យល់ឃើញធនធានរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាក ដូចជាភាពក្រីក្រ ជាអាទិ៍ ដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីពុំមានលទ្ធភាពអាចបង់ប្រាក់តម្កល់ទុកបានទេ។ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចលើកលែងមិនឲ្យបង់ប្រាក់បាន ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់ដើមបណ្តឹងរដ្ឋប្បវេណី។[23] ម្យ៉ាងវិញទៀត ប្រសិនបើចៅក្រមស៊ើបសួរតម្រូវឲ្យបង់ប្រាក់តម្កល់ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីមិនបានបង់ក្នុងរយៈពេលកំណត់ដោយចៅក្រមស៊ើបសួរទេនោះ ចៅក្រមស៊ើបសួរនឹងប្រកាសថាមិនអាចទទួលពាក្យបណ្តឹងនោះបានទេ។ មួយវិញទៀត ចំពោះមូលហេតុដែលទាមទារឲ្យមានការបង់ប្រាក់តម្កល់ទុកមុន គឺដោយសារតែផ្លូវទីមួយដែលច្បាប់បើកផ្លូវឲ្យភាគី (ជនរងគ្រោះ) ដែលមានសិទ្ធិប្តឹងត្រូវបានបញ្ចប់ ហើយការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាផ្លូវចុងក្រោយ ដែលអាចចាត់ទុកថាបណ្តឹង ដែលប្តឹងនោះមានភាគរយត្រឹម៥០%តែប៉ុណ្ណោះ។ មានន័យថា អំពើដែលដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការប្តឹងក្នុងពេលនេះ គឺដែលអាចជាបទល្មើស ឬ អាចជាមិនមែនជាបទល្មើសដូចព្រះរាជអាជ្ញាសម្រេចពីមុន។ ជាមួយគ្នានោះដែរ ការប្តឹងនេះអាចធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ភាគីម្ខាងទៀត ដូចជាកិត្តិយស កេរ្តិ៍ឈ្មោះ ពេលវេលា និងទឹកប្រាក់របស់គេ។ ដូចនេះ បណ្តឹងនេះគឺតម្រូវឲ្យដើមបណ្តឹងរដ្ឋប្បវេណី ត្រូវដាក់ប្រាក់តម្កល់ ដែលត្រូវរក្សាទុកយ៉ាងមានសុវត្ថិភាពក្នុងធនាគារ ដោយនៅពេលចប់នីតិវិធីប្រាក់នឹងប្រគល់ឲ្យដើមបណ្តឹងវិញ។ ដោយឡែក ប្រសិនបើការប្តឹងរបស់ដើមបណ្តឹងមានភាពទុច្ចរិតមិនត្រឹមត្រូវ ហើយធ្វើឲ្យខូចខាតប្រយោជន៍ដូចដែលបានរៀបរាប់នៅខាងលើដល់ភាគីម្ខាងទៀត នោះនៅពេលដែលភាគីម្ខាងទៀតប្តឹងទាមទារព្យសនកម្មដែលកើតចេញពីការធ្វើបណ្តឹងដោយបំពាន[24] ឬ បន្លាយពេល[25] តុលាការអាចចេញដីកាសម្រេចឲ្យបង់ប្រាក់ពិន័យរដ្ឋប្បវេណីដែលបានតម្កល់ទុកនោះ។ ជាមួយគ្នានោះដែរ អំពើបែបនេះអាចប្រឈមទៅនឹងការប្តឹងបកពី "បទបរិហារបង្កាច់កេរ្តិ៍"[26] តាមរយៈដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ (ដែលនេះជាការធ្វើបណ្តឹងឲ្យជួសជុលការខូចខាត)។ ហើយប្រាក់ពិន័យនេះទៀតសោត ពុំអាចលើសពីចំនួនទឹកប្រាក់តម្កល់ទុកបានឡើយ។ ការធ្វើបណ្តឹងនេះអាចធ្វើទៅបានលុះត្រាតែបុគ្គលដែលមានឈ្មោះនៅក្នុងពាក្យប្តឹងនោះប៉ុណ្ណោះទើបអាចធ្វើទៅបាន។ គួរបញ្ជាក់ថា ចំពោះប្រាក់តម្កល់នោះច្បាប់មិនអាចកំណត់បានទេ គឺអាស្រ័យលើឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរជាអ្នកសម្រេច ដោយពិចារណាលើធនធានរបស់ដើមបណ្តឹង

[22] មាត្រា១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[23] id

[24] បណ្តឹងដោយបំពាន គឺជាបណ្តឹងដែលបុគ្គលណាម្នាក់មានបំណងទុច្ចរិតចង់បាននូវផលប្រយោជន៍អ្វីមួយ។

[25] ការបន្លាយពេល គឺជាការចង់ពន្យាពេលក្នុងដំណើរការនៃនីតិវិធីឲ្យមានភាពយូរដើម្បីឲ្យខូចប្រយោជន៍របស់ភាគីម្ខាងទៀត។

[26] មាត្រា៣១១ នៃក្រមព្រហ្មទណ្ឌ,លេខ នស/រកម/១១០៩/០២២,៣០ វិច្ឆិកា ២០០៩។

រដ្ឋប្បវេណី និងភាពលំបាកនៃរឿង។ ប៉ុន្តែផ្ទុយទៅវិញ ប្រសិនបើបណ្តឹងនោះធ្វើឡើងដោយត្រឹមត្រូវមែន មិនមានការបំពាន ឬ បណ្តឹងដោយអូសបន្លាយពេលវេលាទេនោះ ប្រាក់តម្កល់ទុកនេះត្រូវបង្វិលទៅឲ្យសាមីខ្លួនវិញនៅពេលបញ្ចប់នីតិវិធី។

# ជំពូកទី២
# សិទ្ធិអំណាចរបស់ចៅក្រម
# ក្នុងការស៊ើបសួរ

# ជំពូកទី២
# សិទ្ធិអំណាចរបស់ចៅក្រមក្នុងការស៊ើបសួរ

## ផ្នែកទី១៖ កិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

នៅក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរមានតួនាទីសំខាន់ក្នុងការស៊ើបសួរស្វែងរកភស្តុតាងដាក់បន្ទុកផង និងដោះបន្ទុកផងដើម្បីស្វែងរកការពិត ឬ អត្ថិភាពនៃបទល្មើសមុននឹងបញ្ជូនរឿងទៅជំនុំជម្រះ។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរនៅពេលបំពេញកិច្ចស៊ើបសួររបស់ខ្លួនក្នុងដំណាក់កាលស៊ើបសួរត្រូវតែមានក្រឡាបញ្ជីអមជាមួយជានិច្ច។[27] ដោយផ្អែកតាមស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរទទួលបានសិទ្ធិអំណាចក្នុងការស្វែងរកពិរុទ្ធភាព ដែលក្នុងនោះចៅក្រមស៊ើបសួរស្វែងរកភស្តុតាងតាមរយៈពីររបៀបដែលមានដូចជា (១.១)**កិច្ចនីតិវិធីនៃការស៊ើបសួរ** និង (១.២) **ការចាត់ឲ្យស៊ើបសួរជំនួស។**

### ១.១. កិច្ចនីតិវិធីនៃការស៊ើបសួរ

តើកិច្ចនិតីវិធីនៃការស៊ើបសួរប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ? ជាការពិតណាស់ ចៅក្រមស៊ើបសួរអាចធ្វើការស្រាវជ្រាវដោយខ្លួនឯងដើម្បីស្វែងរកភស្តុតាង[28] ឲ្យឃើញនូវការពិត។ ពោល គឺជាការស្វែងរកនូវពិរុទ្ធភាព នៃបទល្មើសដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ម្យ៉ាងវិញទៀត នៅក្នុងសមត្ថកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរអាចធ្វើការបើកការស៊ើបសួរដោយខ្លួនឯងបាន ប្រសិនបើគាត់យល់ឃើញថា ការបើកការស៊ើបសួរនោះមានសារៈសំខាន់ដើម្បីស្វែងរកការពិត ដោយមិនចាំបាច់មានការស្នើសុំ ឬ មានបណ្តឹងស្នើសុំពីភាគីឡើយ នៅក្នុងករណីដែលគាត់បានរកឃើញថា នៅក្នុងបទល្មើសដែលត្រូវបានចោទប្រកាន់ដោយព្រះរាជអាជ្ញានោះ មានលេចនូវមុខសញ្ញានៃការចូលរួមប្រព្រឹត្តបទល្មើសពីសំណាក់បុគ្គលថ្មីផ្សេងទៀត។[29]

ក្នុងចំណុចនេះផងដែរ គឺចង់មានន័យថា ចៅក្រមស៊ើបសួរមានឆន្ទានុសិទ្ធិពេញលេញក្នុងការពិចារណា ឬ ការសម្រេចឲ្យធ្វើការស៊ើបសួរដោយខ្លួនឯង ប្រសិនបើគាត់យល់ឃើញថា មានអត្ថប្រយោជន៍ក្នុងការស្វែងរកការពិតបាន។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរ ដើម្បីស្វែងរកការពិតតាមរយៈកម្មវត្ថុពីរ ដែលក្នុងនោះរួមមាន (១.១.១) **ការស្រាវជ្រាវទាក់ទងនឹងបុគ្គល** និង (១.១.២) **ការស្រាវជ្រាវទាក់ទងនឹងវត្ថុ។**

---

[27] មាត្រា១២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[28] យោងតាមសទ្ទានុក្រមពាក្យច្បាប់ ក្រមព្រហ្មទណ្ឌ, ឆ្នាំ២០១១, ភស្តុតាង សំដៅលើព័ត៌មានគ្រប់ប្រភេទរួមមាន ឯកសារ ព្រឹត្តិការណ៍ វត្ថុជាក់ស្តែងដែលដាក់បង្ហាញនៅពេលស៊ើបអង្កេត ស៊ើបសួរ ឬ សវនាការ ដើម្បីបង្ហាញអំពីអត្ថិភាពនៃអង្គហេតុជាក់លាក់។

[29] ឯកឧត្តម កើត រិទ្ធ, បទសម្ភាសដោយ ពិធីការី នៃទូរទស្សន៍ជាតិកម្ពុជា, ទូរទស្សន៍ជាតិកម្ពុជា, ០៨ មករា ២០០៨។

### ១.១.១. ការស្រាវជ្រាវទាក់ទងនឹងបុគ្គល

ចំពោះការស្រាវជ្រាវទាក់ទងនឹងបុគ្គល ចៅក្រមស៊ើបសួរស្វែងរកការពិតតាមរយៈ (១.១.១.១) **ការសួរចម្លើយជនត្រូវចោទ** (១.១.១.២) **ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី** (១.១.១.៣) **ការស្តាប់ចម្លើយសាក្សី** និង (១.១.១.៤) **ការសួរតទល់គ្នា**។

#### ១.១.១.១. ការសួរចម្លើយជនត្រូវចោទ

ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យនូវបុគ្គលដែលចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ក៏ដូចជាបុគ្គលគ្រប់រូបដែលមានតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់គ្នាយ៉ាងខ្លាំងដែលបង្ហាញថាបានចូលរួមប្រព្រឹត្តបទល្មើស ទោះបីជាគ្មានការចង្អុលឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរក៏ដោយ។[30] ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរអាចធ្វើការដាក់បុគ្គលនោះឲ្យស្ថិតនៅក្រោមការពិនិត្យក្នុងឋានៈជាចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិត។[31] នៅពេលបង្ហាញខ្លួនលើកដំបូងចៅក្រមស៊ើបសួរមានភារកិច្ចមួយចំនួនដូចជា៖

- ពិនិត្យអត្តសញ្ញាណជនត្រូវចោទ
- ប្រាប់ជននោះឲ្យដឹងពីរឿងរ៉ាវដែលចោទប្រកាន់
- ប្រាប់អំពីឈ្មោះនៃបទល្មើសដែលកំណត់ដោយច្បាប់
- ប្រាប់ជនត្រូវចោទថាខ្លួនអាចឆ្លើយ ឬ មិនឆ្លើយបានដោយសេរី។[32]

ប្រសិនបើជនត្រូវចោទចង់ឆ្លើយ ចៅក្រមស៊ើបសួរត្រូវទទួលចម្លើយនោះភ្លាម។ លើសពីនេះទៅទៀត នៅពេលសួរចម្លើយជនត្រូវចោទ ជននោះត្រូវមានមេធាវីអមជានិច្ច។ ប៉ុន្តែក្នុងករណីជនត្រូវចោទពុំមានមេធាវីអមទេនោះ ចៅក្រមស៊ើបសួរនឹងធ្វើការចាត់តាំងមេធាវីដើម្បីការពារក្តីដល់ជនត្រូវចោទនោះ។ កាលណាជនត្រូវចោទមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុតចំនួនប្រាំថ្ងៃមុនការស៊ើបសួរមកដល់ដើម្បីទុកថិរវេលាឲ្យមេធាវីអាចពិនិត្យមើលសំណុំរឿងនៃនីតិវិធីបាន។[33] ក្នុងការសួរចម្លើយនេះ ជនត្រូវចោទអាចត្រូវបានសួរចម្លើយតែក្នុងករណីជននោះនៅចំពោះមុខមេធាវីរបស់ខ្លួនតែប៉ុណ្ណោះ។ លើកលែងតែករណីមេធាវីរបស់ជនត្រូវចោទនោះ មិនបានចូលបង្ហាញខ្លួនតាមថ្ងៃ និងពេលវេលា ដែលចៅក្រមកំណត់តាមរយៈការកោះហៅ[34] ត្រឹមត្រូវ នាំឲ្យចៅក្រមស៊ើបសួរអាចធ្វើការសួរចម្លើយជនត្រូវចោទ ដោយពុំចាំបាច់មានវត្តមានមេធាវី របស់ពួកគេ

---

[30] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[31] មាត្រា១២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[32] មាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[33] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[34] ទម្រង់នៃដីកាកោះមានកំណត់ក្នុង ឧបសម្ព័ន្ធទី២។

បាន។[35]ជាមួយគ្នានោះដែរ នៅពេលដែលជនត្រូវចោទត្រូវបានសួរចម្លើយដោយគ្មានវត្តមានរបស់មេធាវី នៅក្នុងកំណត់ហេតុត្រូវចុះនិទ្ទេសកំណត់ហេតុ។ ជាមួយគ្នានោះដែរ ក្នុងករណីពិសេសចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទបានដោយមិនចាំបាច់កោះហៅមេធាវី បើជនត្រូវចោទបានបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលមេធាវីត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយផ្សេង[36]ពីកំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ និងក្នុងកំណត់ហេតុនោះត្រូវចុះហត្ថលេខាដោយជនត្រូវចោទទៀតផង។ ម្យ៉ាងវិញទៀត ចៅក្រមក៏អាចធ្វើការសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់ធ្វើការកោះហៅមេធាវីបានដែរ នៅពេលបន្ទាន់ដែលជាហេតុអាចនាំឲ្យគ្រោះថ្នាក់ដល់ស្លាប់ ឬ ជាការភ័យខ្លាចចំពោះការបាត់បង់តម្រុយភស្តុតាងជាដើម។ ករណីនេះ គឺចង់សំដៅលើការព្រួយបារម្ភចំពោះការបាត់បង់នូវតម្រុយ ឬ ចម្លើយដែលអាចបំភ្លឺនូវការពិត នាំឲ្យចៅក្រមស៊ើបសួរអាចធ្វើការសួរចម្លើយជាបន្ទាន់បាន។ ចំពោះសួរចម្លើយដោយបន្ទាន់បង្ខំនេះត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ។ ជាងនេះទៅទៀត នៅពេលសួរចម្លើយ ព្រះរាជអាជ្ញា និងមេធាវីក៏អាចធ្វើការលើកសំណួរសួរទៅជនត្រូវចោទ ប៉ុន្តែសំណួរដែលលើកឡើងត្រូវមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ បើមិនអនុញ្ញាតចំពោះការលើកសំណួរនោះទេ ត្រូវចុះនិទ្ទេស។[37] ការកំណត់បែបនេះ គឺសបញ្ជាក់ឲ្យឃើញថាចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងទូលំទូលាយក្នុងដំណាក់កាលស៊ើបសួរ។ មួយវិញទៀត ក្នុងកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរទាក់ទងទៅនឹងរយៈពេលសម្រាប់ការសួរចម្លើយជនត្រូវចោទមានរយៈពេលអប្បបរមាចំនួន ៤ខែ តែប្រសិនបើ ៤ខែ កន្លងផុតទៅចាប់ពីពេលសួរចម្លើយនៅពេលជនជាប់ចោទមិនបានសួរចម្លើយ ឬ សួរតទល់នៅពេលខ្លួនបង្ហាញខ្លួនដំបូងទេនោះ ចៅក្រមស៊ើបសួរត្រូវតែទទួលចម្លើយ ប្រសិនបើជននោះស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយមកកាន់រូបគេ។ ប៉ុន្តែក្នុងករណីចៅក្រមស៊ើបសួរមិនព្រមកោះហៅ ជនត្រូវចោទនៅរយៈពេល ១ខែទេ ជនត្រូវចោទអាចប្តឹងទៅសភាស៊ើបសួរបាន។

ចំពោះអនីតិជន ក្នុងការសួរចម្លើយមានលក្ខណៈខុសពីនីតិជន ដោយត្រូវគោរពនូវលក្ខខណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពីយុត្តិធម៌អនីតិជន[38]។ នៅក្នុងដំណាក់កាលស៊ើបសួរ នៅពេលដែលចៅក្រមស៊ើបសួរទទួលបាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីតំណាងអយ្យការហើយចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ដែលនេះគឺជាការផ្តល់អាទិភាពចំពោះរឿងក្តីរបស់អនីតិជន។ នៅពេលដែលជនត្រូវចោទជាអនីតិជន ការស្តាប់ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ អាចត្រូវបានធ្វើឡើងដោយមានវត្តមានមេធាវីអមជានិច្ច។[39] ប៉ុន្តែ

[35] មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[36] កំណត់ហេតុផ្សេងក្នុងចំណុចនេះ គឺសំដៅទៅលើកំណត់ហេតុស្តីពីការបោះបង់ចោលមេធាវី។

[37] ទម្រង់នៃកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទមានកំណត់ក្នុង ឧបសម្ព័ន្ធទី៣។

[38] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

[39] មាត្រា៣២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

ប្រសិនបើនៅក្នុងករណីគ្មានការជ្រើសរើសមេធាវី ចៅក្រមស៊ើបសួរត្រូវចាត់តាំងមេធាវី ដើម្បីការពារក្តីដល់អនីតិជន។

### ១.១.១.២. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ចៅក្រមស៊ើបសួរកោះហៅដើមបណ្តឹងរដ្ឋប្បវេណីដើម្បីស្តាប់ចម្លើយដែលជាព័ត៌មានទាក់ទងទៅជាមួយនឹងបទល្មើស។ ការសួរធ្វើឡើង គឺដើម្បីឲ្យដើមបណ្តឹងឆ្លើយប្រាប់ពីហេតុការណ៍ ឬ អង្គហេតុដែលបានកើតឡើងមកលើខ្លួនព្រមទាំងបញ្ជាក់ពីថ្ងៃខែ ដែលត្រូវបានគេប្រព្រឹត្តសកម្មភាពមកលើខ្លួនផងដែរ។ ក្នុងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដូចជាជនត្រូវចោទផងដែរ។ ពោល គឺអាចមានសិទ្ធិទទួលបាននូវមេធាវីក្នុងការការពារសិទ្ធិរបស់ខ្លួនដែលត្រូវបានគេបំពាននោះ។ ក្នុងករណីដើមបណ្តឹងរដ្ឋប្បវេណីមានមេធាវីអម ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងយ៉ាងយូរបំផុត ៥ថ្ងៃមុនពេលស្តាប់ចម្លើយ។ នៅក្នុងន័យនេះ គឺដើម្បីឲ្យមេធាវីមានពេលក្នុងការពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ គួរបញ្ជាក់ផងដែរថា ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីតែនៅចំពោះមុខមេធាវីតែប៉ុណ្ណោះ។ លើកលែងតែករណីមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះមិនបានចូលបង្ហាញខ្លួនតាមថ្ងៃ និងពេលវេលា ដែលចៅក្រមកំណត់តាមរយៈការកោះហៅត្រឹមត្រូវ[40] នាំឲ្យចៅក្រមស៊ើបសួរអាចធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយពុំមានវត្តមានមេធាវីរបស់គេបាន។[41] ជាមួយគ្នានោះដែរ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្តាប់ចម្លើយដោយគ្មានវត្តមានរបស់មេធាវីនៅក្នុងកំណត់ហេតុត្រូវចុះនិទ្ទេសកំណត់ហេតុ។[42] ទន្ទឹមនឹងនេះដែរ ក្នុងករណីពិសេសចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបានដោយមិនចាំបាច់កោះហៅមេធាវី បើដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលមេធាវីត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយ ដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងកំណត់ហេតុនោះត្រូវចុះហត្ថលេខា ដោយដើមបណ្តឹងរដ្ឋប្បវេណីទៀតផង។ ករណីមួយទៀតដែរ ចៅក្រមក៏អាចធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់ធ្វើការកោះហៅមេធាវីបានដែរ នៅពេលបន្ទាន់ដែលជាហេតុអាចនាំឲ្យគ្រោះថ្នាក់ដល់ស្លាប់ ឬ ជាការភ័យខ្លាចចំពោះការបាត់បង់តម្រុយភស្តុតាងជាដើម។ ឧទាហរណ៍៖ “ក” បានវាយលោក “ខ” ដូច្នេះលោក “ខ” ក៏បានប្តឹងលោក “ក” ពីបទហិង្សា ហើយព្រមទាំងបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជម្ងឺចិត្ត។ ប៉ុន្តែដោយសារតែ “ក” ធ្លាប់បានគំរាមលោក “ខ” ថាកុំឲ្យនិយាយពីអំពើអាក្រក់របស់ខ្លួន ប្រសិនបើនិយាយគាត់នឹងសម្លាប់។ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចធ្វើការកោះហៅ

[40] ទម្រង់នៃដីកាកោះមានកំណត់ក្នុង ឧបសម្ព័ន្ធទី៤។

[41] មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[42] ទម្រង់នៃកំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីមានកំណត់ក្នុង ឧបសម្ព័ន្ធទី៥។

បន្ទាន់ដើម្បីបង្ការមិនឲ្យបាត់បង់នូវតម្រុយនៃភស្តុតាង។ ចំពោះការស្តាប់ចម្លើយដោយបន្ទាន់បង្ខំនេះ ក៏ត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុដែរ។

បើសង្កេតមកមើលការស្តាប់ចម្លើយរបស់អនីតិជនវិញម្តង ឃើញថាការស្តាប់ចម្លើយត្រូវតែធ្វើឡើងជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី[43] ហើយថែមទាំងត្រូវមាននូវវត្តមានមេធាវីការពារ អ្នកតំណាងដែលច្បាប់បានកំណត់[44] ឬ អ្នកទំនុងបម្រុងរបស់អនីតិជន[45] និងភ្នាក់ងារសង្គមកិច្ច។[46] ប៉ុន្តែប្រសិនបើវត្តមានអ្នកដែលបានរៀបរាប់ខាងលើផ្ទុយឧត្តមប្រយោជន៍របស់អនីតិជន។ ចំពោះការមិនអនុញ្ញាតត្រូវមានការពិគ្រោះជាមួយនឹងមេធាវី ឬ ភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ នៅក្នុងការស្តាប់ចម្លើយរបស់អនីតិជន ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានអ្នកតំណាងដែលច្បាប់បានកំណត់ ឬ អ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ច។ បន្ទាប់ពីស្តាប់ចម្លើយហើយភ្លាម អនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួន។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុបានទេនោះ ក្រឡាបញ្ជីត្រូវអានកំណត់ហេតុចម្លើយឲ្យអនីតិជនស្តាប់។ លើសពីនេះទៅទៀត នៅពេលដែលអនីតិជនសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយ អាចធ្វើបានមុននឹងចុះហត្ថលេខា ឬ ផ្តិតមេដៃ។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរអាចអនុញ្ញាតឲ្យមេធាវី ឬ អ្នកតំណាងដែលច្បាប់កំណត់ ឬ អ្នកទំនុកបម្រុងអនីតិជន ឬ ភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបានមានស្នើសុំ។ ក្រោយពីកំណត់ហេតុ ឬមានការកែប្រែរួចរាល់ហើយ អនីតិជន ឬ បុគ្គលដទៃផ្សេងទៀតត្រូវចុះហត្ថលេខា ឬ ផ្តិតម្រាមដៃលើកំណត់ហេតុចៅក្រមស៊ើបសួរ បើមិនមានការយល់ព្រមចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេស។[47]

### ១.១.១.៣. ការស្តាប់ចម្លើយសាក្សី

បន្ទាប់ពីបានធ្វើការសិក្សាទាក់ទងនឹងការសួរចម្លើយជនត្រូវចោទ ព្រមទាំងការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីក្នុងចំណុចខាងលើរួចមកហើយ នៅក្នុងចំណុចនេះនឹងធ្វើការសិក្សាទាក់ទងនឹងការស្តាប់ចម្លើយសាក្សីវិញម្តង។ ដើម្បីងាយស្រួលក្នុងការបកស្រាយអំពីការស្តាប់ចម្លើយរបស់ចៅក្រមស៊ើបសួរមានការប្រព្រឹត្តទៅ

[43] នីតិវិធីកុមារមេត្រី សំដៅនីតិវិធីដែលធ្វើឡើងដើម្បីលើកទឹកចិត្តឲ្យអនីតិជនអាចចូលរួមក្នុងរឿងក្តី ដោយក្នុងនោះមានដូចជា ការប្រើប្រាស់ភាសា និងសកម្មភាពដែលអាចឲ្យអនីតិជនយល់បាន។ (ដកស្រង់ចេញពីច្បាប់ស្តីពីយុត្តិធម៌អនីតិជនមាត្រា៥)

[44] អ្នកតំណាងដែលច្បាប់បានកំណត់ សំដៅទៅលើអ្នកអាណាព្យាបាលនៃអនីតិជន អ្នកអាណាព្យាបាលទូទៅ និងហិតូបត្ថម្ភកៈ។

[45] អ្នកទំនុកបម្រុងរបស់អនីតិជន សំដៅទៅលើរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬ ដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងរយៈពេលអនុវត្តនីតិវិធី ដែលមានចែងក្នុងច្បាប់នេះ។

[46] មាត្រា៣៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

[47] id

ដូចម្តេចនោះ គឺត្រូវដឹងថាតើសាក្សីជាអ្វី? ជាមុនសិន។ ដូចនេះ សាក្សី គឺជារូបវន្តបុគ្គលដែលបានដឹងពីរឿងរ៉ាវពី អតីតកាល ឬ ហេតុការណ៍ដែលបានកើតឡើងពីមុនទាក់ទងនឹងការប្រព្រឹត្តបទល្មើសរួច ដែលត្រូវបានតុលាការ ឬ អាជ្ញាធរបានកោះអញ្ជើញមកបំភ្លឺពីរឿងរ៉ាវដែលបានកើតឡើងនៅចំពោះមុខ។ នៅក្នុងដំណាក់កាលស៊ើបសួរ អាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ចម្លើយដែលមានប្រយោជន៍នៅក្នុងការសម្តែងឲ្យឃើញការពិត។ ដូច្នេះ បើយោងតាមបញ្ញត្តិនេះ ចៅក្រមស៊ើបសួរអាចកោះហៅបុគ្គលគ្រប់រូបក្នុងឋានៈជាសាក្សីចូលមក បង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរក្នុងគោលបំណងដើម្បីស្វែងរកការពិត។ ទាក់ទងនឹងការកោះហៅនោះ ទៀតសោត នីតិវិធីក្នុងការកោះហៅនេះចៅក្រមស៊ើបសួរធ្វើឡើងតាមរយៈដីកាកោះ[48] ដើម្បីឲ្យឆ្លើយបំភ្លឺការពិត។ ចំពោះបុគ្គលដែលបានកោះហៅក្នុងនាមជាសាក្សីនោះ មានកាតព្វកិច្ចក្នុងការចូលខ្លួនដើម្បីឲ្យចៅក្រមស៊ើប សួរស្តាប់ចម្លើយ។ ប៉ុន្តែប្រសិនបើបុគ្គលដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅតាមរយៈដីកាកោះ រឹងទទឹងមិន ព្រមចូលបង្ហាញខ្លួនទេនោះ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចអាចសុំកងកម្លាំងសារធារណៈបង្ខំសាក្សីនោះ ឲ្យចូលមកបង្ហាញខ្លួនបាន។[49] ជាក់ស្តែង បញ្ជានេះត្រូវមានកំណត់អត្តសញ្ញាណរបស់សាក្សីហើយត្រូវចុះកាល បរិច្ឆេទ ហត្ថលេខាចៅក្រមស៊ើបសួរ និងបោះត្រាដើម្បីឲ្យបញ្ជានោះមានភាពច្បាស់លាស់ដើម្បីឲ្យមានអានុភាព អនុវត្ត។ ទន្ទឹមនឹងនេះដែរ បើមានការរឹងទទឹងពីសំណាក់សាក្សី ដែលត្រូវចៅក្រមស៊ើបសួរកោះហៅកើតមាន ឡើង ការរឹងទទឹងរបស់សាក្សីនោះនឹងត្រូវចាត់ទុកជាបទល្មើស ដែលមានចែងក្នុងមាត្រា៥៣៨ (បទបដិសេធ ក្នុងការចូលខ្លួន) នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។ មួយវិញទៀត បើពិនិត្យមកមើលទិដ្ឋភាពនៃការ ស្តាប់ចម្លើយសាក្សីវិញម្តង ឃើញថាការស្តាប់ចម្លើយរបស់សាក្សីត្រូវធ្វើឡើងដាច់ដោយឡែកពីគ្នាពីការសួរចម្លើយ ជនល្មើស ក៏ដូចជាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី។[50] ប្រសើរជាងនេះទៅទៀត ការស្តាប់នោះត្រូវធ្វើ ឡើងជាសាធារណៈនៅក្នុងសវនាការ។ មួយវិញទៀត មុននឹងចៅក្រមស៊ើបសួរធ្វើការស្តាប់សាក្សី សាក្សីនោះ ត្រូវតែធ្វើការស្បថជាមុនសិន ស្របតាមសាសនា ឬ ជំនឿរបស់ខ្លួនថានិយាយតែការពិត។[51] ផ្ទុយទៅវិញ សាក្សីមួយចំនួនមិនត្រូវទាមទារឲ្យមានការស្បថឡើយដែលសាក្សីទាំងនោះមានដូចជា៖

- ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ
- កូនប្រុស កូនស្រី និង បច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ
- បង ប្អូនប្រុស ស្រីរបស់ជនត្រូវចោទ

[48] ទម្រង់នៃដីកាកោះហៅសាក្សីមានកំណត់ក្នុង ឧបសម្ព័ន្ធទី៦។

[49] មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[50] id

[51] មាត្រា១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

- បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ
- ប្តី ឬ ប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាហើយក៏ដោយ
- កុមារអាយុតិចជាង ១៨ឆ្នាំ។[52]

លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរក៏ត្រូវពិនិត្យមើលទៅលើលក្ខណៈសម្បត្តិរបស់សាក្សីមុនពេលធ្វើការស្តាប់ចម្លើយ។ ពោល គឺសាក្សីណាមួយដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តនូវបទល្មើស ចៅក្រមស៊ើបសួរមិនអាចធ្វើការស្តាប់ចម្លើយនោះទេ។ ក្នុងន័យនេះ គឺដើម្បីគោរពសិទ្ធិការពារខ្លួន។[53] នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការដាក់បុគ្គលដែលមានតម្រុយពិរុទ្ធភាពនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងអំពីការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ដោយស្របតាមមាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយឡែក បើក្រឡេកមើលករណីដែលសាក្សីឈឺ ឬ ពុំអាចធ្វើដំណើរទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរបានតាមការកោះហៅ ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជីអាចចុះទៅកាន់លំនៅឋាន ឬ ទីកន្លែងដែលសាក្សីនោះរស់នៅដើម្បីទទួលចម្លើយ។[54] អ្វីដែរសំខាន់នោះ គឺនៅគ្រប់រាល់ពេលស្តាប់ចម្លើយសាក្សី ចៅក្រមស៊ើបសួរដែលមានក្រឡាបញ្ជីអម ត្រូវធ្វើកំណត់ហេតុជាការចាំបាច់។[55]

### ១.១.១.៤. ការសួរតទល់

ការសួរតទល់ សំដៅលើការសួរចម្លើយ ឬ ក៏ស្តាប់ចម្លើយច្រើនព្រមពេលជាមួយគ្នាក្នុងគោលបំណងដើម្បីស្វែងរក ឬ ក៏ដើម្បីឲ្យលេចចេញនូវការពិតក្នុងរឿងក្តី។ ជាក់ស្តែង ការស្វែងរកនូវការពិតក្នុងរឿងក្តី គឺធ្វើឡើងតាមរយៈការបញ្ចេញយោបល់ និងការបង្ហាញនូវគោលជំហររបស់បុគ្គលម្នាក់ៗដែលចៅក្រមដាក់ឲ្យតទល់គ្នា។ ជាមួយគ្នានោះដែរ ការសួរតទល់ត្រូវធ្វើឡើងនៅក្រោមរូបភាពជាការបង្ហាញនូវវត្តមានរួមគ្នារវាង ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និងជនត្រូវចោទ។ កាន់តែពិសេសជាងនេះទៅទៀត ចំពោះអ្នកដែលមានសិទ្ធិក្នុងការលើកជាសំណួរសម្រាប់សួរតទល់នេះមានដូចជា ព្រះរាជអាជ្ញា និងមេធាវី។ ប៉ុន្តែចំពោះការលើកជាសំណួរនេះត្រូវតែមានការអនុញ្ញាតពីចៅក្រមស៊ើបសួរជាមុនសិន ទើបអាចធ្វើការចោទជាសំណួរបាន។ ម្យ៉ាងវិញទៀត នីតិវិធីនៃការសួរតទល់នេះ គឺត្រូវបានអនុវត្ត និងប្រព្រឹត្តទៅដូចការសួរចម្លើយជនត្រូវចោទ ឬ សួរចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែរ។ គួរបញ្ជាក់ផងដែរថា នៅរាល់ការសួរតទល់ត្រូវតែមាននូវកំណត់ហេតុជាចាំបាច់ ដែលមានកំណត់អំពីការប្រព្រឹត្តទៅនៃការសួរតទល់ ដែលកំណត់ហេតុនោះហៅថា កំណត់ហេតុសួរតទល់[56]។

---

[52] មាត្រា១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[53] មាត្រា១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[54] មាត្រា១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[55] ទម្រង់នៃកំណត់ហេតុស្តីពីការស្តាប់ចម្លើយសាក្សីមានកំណត់ក្នុង ឧបសម្ព័ន្ធទី៧។

[56] ទម្រង់នៃកំណត់ហេតុសួរតទល់មានកំណត់ក្នុង ឧបសម្ព័ន្ធទី៨។

### ១.១.២. ការស្រាវជ្រាវទាក់ទងនឹងវត្ថុ

នៅក្នុងដំណាក់កាលស៊ើបសួរ ដើម្បីធ្វើការស្វែងរកការពិតឲ្យបានគ្រប់ជ្រុងជ្រោយ ចៅក្រមស៊ើបសួរមិនត្រឹមតែត្រូវធ្វើការស៊ើបសួរទាក់ទងនឹងបុគ្គលប៉ុណ្ណោះទេ ប៉ុន្តែគាត់ថែមទាំងត្រូវធ្វើការស្រាវជ្រាវទាក់ទងនឹងវត្ថុទៀតផង។ តើការស្រាវជ្រាវទាក់ទងនឹងវត្ថុប្រព្រឹត្តយ៉ាងដូចម្តេចខ្លះ? ជាក់ស្តែង ការស្រាវជ្រាវទាក់ទងវត្ថុត្រូវបានបែងចែកជា (១.១.២.១) **ការឆែកឆេរនិងការចាប់យកវត្ថុតាង** (១.១.២.២) **ការធ្វើកោសលវិច័យ** និង (១.១.២.៣) **ការស្តាប់ទូរស័ព្ទ**។

#### ១.១.២.១. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ការឆែកឆេរនៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ មានលក្ខណៈធំធេងជាងការឆេកឆេរនៅក្នុងដំណាក់កាលផ្សេងៗទៀត ពីព្រោះការឆែកឆេរចូលរួមការចាប់យកវត្ថុតាងនៅក្នុងដំណាក់កាលនេះជាសកម្មភាពសំខាន់មួយដែលចៅក្រមស៊ើបសួរត្រូវធ្វើប្រសិនបើយល់ឃើញថាជាការចាំបាច់។ ស្របពេលជាមួយគ្នានេះដែរ ដោយសារតែចៅក្រមស៊ើបសួរមានតួនាទីក្នុងការដាក់បន្ទុក និងដោះបន្ទុក ជាហេតុនាំឲ្យការឆែកឆេរព្រមទាំងការចាប់យកវត្ថុតាងជាកត្តាសំខាន់មួយក្នុងការស្វែងរកវត្ថុតាងដែលបង្កឡើងពីបទល្មើស ឬ ស្វែងរកវត្ថុតាងនៅក្នុងបទល្មើស ដែលបានការកំណត់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។ ជាមួយគ្នានោះដែរ ការឆែកឆេរ គឺជាការរុករក ឬ ក៏ការកកាយរកនូវតម្រុយនៅទីកន្លែងដែលមានលក្ខណៈបិទបាំងនូវការពិតនោះ។ ចំណែក ការចាប់យកវត្ថុតាង គឺជាការដកហូតនូវវត្ថុដែលបានប្រព្រឹត្តបទល្មើស ឬ វត្ថុដែលជាប់ទាក់ទិននឹងការប្រព្រឹត្តបទល្មើស។ ក្នុងការឆែកឆេរ ចៅក្រមស៊ើបសួរ ត្រូវគោរពនូវវិធានអនុវត្តចំពោះការឆែកឆេរ ដែលបានកំណត់ក្នុងមាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ដោយក្នុងនោះចៅក្រមស៊ើបសួរត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬ បើគ្មានត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ដែលខ្លួនចាត់តាំង។ ប៉ុន្តែសាក្សីនោះមិនអាចជាសមាសភាពនគរបាលយុត្តិធម៌ ឬ កងរាជអាវុធហត្ថបានទេ។ ចំណែករយៈពេលនៃការចូលឆែកឆេរវិញ សង្កេតឃើញថាចៅក្រមស៊ើបសួរមិនអាចចូលឆែកឆេរមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ៦ល្ងាចបានទេ លើកលែងតែៈ

- ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហដល់សាធារណជន
- ក្នុងករណីនៅគ្រប់គ្រងទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ ឬ ប្រើប្រាស់គ្រឿងញៀន។[57]

ក្រៅពីការកំណត់នូវពេលវេលាក្នុងការចូលឆែកឆេរ ស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បានកំណត់នូវលក្ខខណ្ឌមួយចំនួន ដែលទាក់ទងទៅនឹងការឆែកឆេរក្នុងការិយាល័យមេធាវី ដែលត្រូវប្រព្រឹត្តទៅនៅចំពោះប្រធានគណៈមេធាវី ឬ ប្រតិភូរបស់ប្រធានគណៈមេធាវី។[58] អ្វីដែលសំខាន់នោះ រាល់ការឆែកឆេរ ត្រូវធ្វើពី

[57] មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[58] id

កំណត់ហេតុស្តីការឆែកឆេរ ហើយកំណត់ហេតុនោះផងដែរ ត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណអ្នកកាន់កាប់ទីកន្លែង ប្រសិនបើការឆែកឆេរនោះធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង។ ប៉ុន្តែបើការឆែកឆេរធ្វើឡើងចំពោះមុខសាក្សីពីររូប កំណត់ហេតុនោះចុះអត្តសញ្ញាណរបស់សាក្សីនោះ ហើយបើការឆែកឆេរធ្វើឡើងនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬ ប្រតិភូនៃប្រធានគណៈមេធាវី។ ក្រោយពីបានចុះនិទ្ទេសក្នុងកំណត់ហេតួចរាល់អស់ហើយចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សី ឬ ប្រធានគណៈមេធាវី ឬ ប្រតិភូគណៈមេធាវីត្រូវចុះហត្ថលេខានៅលើកំណត់ហេតុនោះ។

ជាពិសេសជាងនេះទៅទៀត នៅក្នុងការប្រព្រឹត្តទៅនៃការឆែកឆេរ ប្រសិនបើចៅក្រមស៊ើបសួរ រកឃើញពីភស្តុតាងទាំងនោះបាន ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង ហើយបិទស្លាកបោះត្រាលើវត្ថុតាងនោះ។ ពេលដែលចាប់វត្ថុតាង និង បិទស្លាកហើយចៅក្រមស៊ើបសួរត្រូវធ្វើការបង្ហាញវត្ថុដែលចាប់នោះទៅកាន់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។ នៅក្នុងនោះក្រោយពីចៅក្រមស៊ើបសួរបានបង្ហាញវត្ថុដល់អ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់រួចមក ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្តីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។[59] ទន្ទឹមនឹងនេះដែរ កំណត់ហេតុស្តីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និង ក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬ សាក្សីពីរនាក់។[60]

### ១.១.២.២. ការធ្វើកោសលវិច័យ

ការធ្វើកោលសវិច័យ គឺជាការពិនិត្យ ឬ ធ្វើការស្វែករកនូវតម្រុយនៃបទល្មើសផ្សេងៗទៅលើភស្តុតាង ឬ វត្ថុតាងដោយផ្អែកលើលក្ខណៈមធ្យោបាយបច្ចេកទេស និងវិទ្យាសាស្ត្រផងដែរ។ នៅពេលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរបង្គាប់ឲ្យធ្វើកោសលវិច័យ ដែលជាការពិនិត្យ ឬ ស្វែករកនូវតម្រុយនៃបទល្មើសផ្សេងៗទៅលើភស្តុតាង ឬ វត្ថុតាងដោយផ្អែកលើមធ្យោបាយបច្ចេកទេស និងវិទ្យាសាស្ត្រ។ ឧទាហរណ៍៖ ក្នុងការពិនិត្យនូវសារធាតុញៀន ដើម្បីឲ្យឃើញច្បាស់ថាតើមាននូវគ្រឿងញៀនពិតមែន ឬ ក៏គ្មាន ដើម្បីធ្វើការសម្រេចនូវទោសដោយផ្អែកទៅលើសារធាតុញៀនដែលមាន។ មួយវិញទៀត ការធ្វើកោសលវិច័យអាចធ្វើឡើងដើម្បីពិនិត្យលើសពជាដើម។ ចំពោះការធ្វើកោសលវិច័យនេះដែរ ត្រូវធ្វើឡើងបានដោយមានការបង្គាប់ពីចៅក្រមស៊ើបសួរ ឬ ការដាក់ពាក្យសុំរបស់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។[61] ស្របពេលជាមួយគ្នានេះដែរ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទមានមេធាវីអម មេធាវីអាចស្នើសុំក្នុងនាមដើមបណ្តឹង ឬ ជនត្រូវចោទបាន ក្នុងការធ្វើកោសលវិច័យទៅចៅក្រមស៊ើបសួរ។ ចំណែកអ្នកជំនាញ ដែលនឹងត្រូវមាន

[59] មាត្រា១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[60] id

[61] មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

កាតព្វកិច្ចធ្វើកោសលវិច័យក្នុងរឿងព្រហ្មទណ្ឌ ជាធម្មតាចៅក្រមស៊ើបសួរ ត្រូវជ្រើសរើសអ្នកជំនាញនោះតាមជំនាញដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ឲ្យធ្វើកោសលវិច័យ។[62] ការចាត់តាំងនោះត្រូវធ្វើតាមរយៈដីកាចាត់តាំងអ្នកជំនាញ[63] ដែលដីកានោះត្រូវបញ្ជាក់អំពីបេសកកម្មដែលអ្នកជំនាញត្រូវបំពេញ រួមជាមួយនឹងរយៈពេលដែលអ្នកជំនាញត្រូវបំពេញបេសកកម្ម។ ក្នុងនោះបេសកកម្មដែលបានកំណត់ត្រូវតែទាក់ទងនឹងបញ្ហាបច្ចេកទេសតែប៉ុណ្ណោះ។[64] ក្រៅពីនេះទៅទៀត ចៅក្រមស៊ើបសួរក៏អាចធ្វើការចាត់តាំងអ្នកជំនាញដែលពុំមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិឲ្យបំពេញនូវកិច្ចការធ្វើកោសលវិច័យបានផងដែរ។ ប៉ុន្តែ នៅពេលដែលចៅក្រមស៊ើបសួរចាត់តាំងអ្នកជំនាញដែលពុំមានឈ្មោះក្នុងបញ្ជីថ្នាក់ជាតិនោះ គឺគាត់ត្រូវឲ្យអ្នកជំនាញនោះធ្វើការស្បថមុននឹងបំពេញបេសកកម្មរបស់ខ្លួន។ លើកលែងតែអ្នកជំនាញមានក្នុងបញ្ជីស្រាប់ ហើយការស្បថនោះធ្វើឡើងតាមជំនឿសាសនារបស់ខ្លួនថាត្រូវផ្តល់ជំនួយយ៉ាងស្មោះត្រង់ក្នុងការស្វែងរកយុត្តិធម៌។ ទន្ទឹមនឹងនេះដែរ ចំពោះការចាត់តាំងអ្នកជំនាញក្រៅបញ្ជីថ្នាក់ជាតិ ត្រូវធ្វើឡើងតាមដីកាចាត់តាំងអ្នកជំនាញ ដែលមានសំអាងហេតុជាពិសេស។ អ្វីដែលសំខាន់ក្នុងការចាត់តាំងនេះគឺអាចចាត់អ្នកជំនាញម្នាក់ ឬ ជាក្រុម គឺអាស្រ័យលើកាលៈទេសៈ និងបេសកកម្មតម្រូវ។[65] នៅក្នុងការប្រព្រឹត្តទៅនៃការធ្វើកោសលវិច័យទាំងអស់ត្រូវស្ថិតក្រោមការពិនិត្យរបស់ចៅក្រមស៊ើបសួរ ដោយក្នុងនោះអ្នកជំនាញត្រូវជូនព័ត៌មានដល់ចៅក្រមស៊ើបសួរពីសកម្មភាពនៃបេសកកម្មរបស់ខ្លួន។[66] ចំពោះរបាយការណ៍របស់អ្នកជំនាញ នៅពេលប្រតិបត្តិការក្នុងការធ្វើកោលសវិច័យត្រូវបានបញ្ចប់ អ្នកជំនាញត្រូវធ្វើរបាយការណ៍ពណ៌នាយ៉ាងច្បាស់អំពីប្រតិបត្តិការកោសលវិច័យរបស់ខ្លួន ហើយថែមទាំងត្រូវធ្វើសេចក្តីសន្និដ្ឋាន ដោយអ្នកជំនាញត្រូវបញ្ជាក់ថាបានធ្វើដោយផ្ទាល់ខ្លួននូវប្រតិបត្តិការរបស់ខ្លួន និងបានបំពេញនូវប្រតិបត្តិការដែលរៀបរាប់ក្នុងរបាយការណ៍នោះ។ ប្រសើរជាងនេះទៅទៀត របាយការណ៍នេះក៏ត្រូវការកាលបរិច្ឆេទ និងចុះហត្ថលេខាផងដែរ។[67] នៅក្នុងការធ្វើកោសលវិច័យ បើមានការបំបែកស្លាកចៅក្រមស៊ើបសួរត្រូវបិទស្លាកជាថ្មីលើវត្ថុនោះវិញ ហើយព្រមទាំងត្រូវធ្វើនូវកំណត់ហេតុស្តីពីការបិទស្លាកថ្មីលើវត្ថុទាំងនោះ។[68] លើសពីនេះទៅទៀត ក្រោយពីបានធ្វើកោសលវិច័យ អ្នកជំនាញត្រូវប្រគល់វត្ថុដែលចាប់យកទៅឲ្យចៅក្រមស៊ើបសួរវិញ។ មួយវិញទៀត ក្រោយពីធ្វើរបាយការណ៍ត្រូវបានធ្វើរួចរាល់ចៅក្រមស៊ើបសួរ

[62] មាត្រា១៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[63] ទម្រង់នៃដីកាចាត់តាំងអ្នកជំនាញមានកំណត់ក្នុង ឧបសម្ព័ន្ធទី៩។

[64] មាត្រា១៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[65] មាត្រា១៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[66] មាត្រា១៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[67] មាត្រា១៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[68] id

ត្រូវជូនព័ត៌មាននេះទៅកាន់ព្រះរាជអាជ្ញា ដោយរបាយការណ៍ត្រូវបញ្ចូលក្នុងសំណុំរឿងស៊ើបសួរ។ បន្ទាប់មក ចៅក្រមស៊ើបសួរត្រូវកោះហៅជនត្រូវចោទ ដើមបណ្តឹង និងមេធាវី ដើម្បីប្រាប់ឲ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ[69]។[70] នៅក្រោយពេលដែលព្រះរាជអាជ្ញា ដើមបណ្តឹង ជនត្រូវចោទ ឬ មេធាវីបានទទួលដំណឹងពីការធ្វើកោសលវិច័យរួចរាល់ហើយ ពួកគេមានសិទ្ធិក្នុងការដាក់ពាក្យសុំធ្វើកោសលវិច័យបន្ថែម[71] ឬ ប្រតិកោសលវិច័យ[72] ដែលក្នុងនោះចៅក្រមស៊ើបសួរត្រូវកំណត់រយៈពេលទទួលពាក្យស្នើសុំនោះមិនតិចជាងរយៈពេល ១០ថ្ងៃនោះទេ។ ក្នុងករណីនេះកាលណាចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យបន្ថែម ឬ ប្រតិកោសលវិច័យទេ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ជាមួយគ្នានោះដែរ ដីកានេះត្រូវសម្រេចក្នុងរយៈពេល៥ថ្ងៃ ប្រសិនបើពាក្យសុំចេញមកពីព្រះរាជអាជ្ញា និង១ខែ ប្រសិនបើពាក្យស្នើសុំចេញពីជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។[73] ដោយឡែក បើចៅក្រមស៊ើបសួរទទួលពាក្យសុំនោះ ប៉ុន្តែមិនព្រមសម្រេចក្នុងរយៈពេល ៥ថ្ងៃចំពោះពាក្យសុំរបស់ព្រះរាជអាជ្ញា និង១ខែចំពោះពាក្យសុំរបស់ជនត្រូវចោទ និង ដើមបណ្តឹង អ្នកស្នើសុំទាំងនោះអាចប្តឹងទៅសភាស៊ើបសួរបាន។[74]

### ១.១.២.៣. ការស្តាប់ទូរស័ព្ទ

ការស្តាប់ទូរស័ព្ទ គឺជាតម្រូវការចាំបាច់មួយដែលធ្វើឡើង ដើម្បីស្វែងរកឲ្យឃើញនូវការពិត។ យោងតាមស្មារតីក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១២៧ សង្កេតឃើញថាការស្តាប់ទូរស័ព្ទ គឺជាវិធានពិសេសដែលកំណត់សម្រាប់ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ដែលផ្ទុយពីការកំណត់ដាក់ជាមួយនឹងការស្តាប់ទូរស័ព្ទក្នុងដំណាក់កាលស្រាវជ្រាវរបស់នគរបាលយុត្តិធម៌។ ទាក់ទងនឹងចំណុចនេះដែរ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបើកផ្លូវដល់ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យស្តាប់ ថតការសន្ទនា ចាប់ និង ថតគ្រប់ការឆ្លងឆ្លើយ តាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារទូរសារ ឬ សារតាមអ៊ីនធើណែត។[75] អ្វីដែលពិសេសនេះ គឺចៅក្រមស៊ើបសួរ អាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និង ថត ដោយការចូលទៅក្នុងទីកន្លែងនោះ គឺមិនអាចត្រូវបានហាមឃាត់ដោយសំអាងលើមូលហេតុអ្វីបានទេ សូម្បីតែកន្លែងយោធា។[76] ក្នុងនោះដើម្បី

[69] សេចក្តីសន្និដ្ឋាននៃកោសលវិច័យ គឺជាការយល់ឃើញរបស់អ្នកជំនាញផ្អែកតាមរយៈការធ្វើកោសលវិច័យរបស់ខ្លួន។

[70] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[71] ពាក្យសុំធ្វើកោសលវិច័យស្រូវតែធ្វើជាលាយលក្ខ័ណអក្សរ ព្រមទាំងមានសំអាងហេតុត្រឹមត្រូវ។

[72] ប្រតិកោសលវិច្ឆ័យ ជាការធ្វើកោសលវិច្ឆ័យឡើងវិញ មិនមែនជាការធ្វើកោសលវិច្ឆ័យបន្ថែម។

[73] មាត្រា១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[74] មាត្រា១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[75] id

[76] id

ឲ្យការបង្គាប់ឲ្យស្តាប់ទូរស័ព្ទអាចប្រព្រឹត្តទៅបាន ច្បាប់បានបើកផ្លូវឲ្យចៅក្រមស៊ើបសួរអាចសុំឲ្យគ្រប់អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការជំនាញតាំងឧបករណ៍បច្ចេកទេស និង ធ្វើការថត ដោយលោកត្រូវចេញដីកាដោយបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទនៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងរយៈពេលនៃបេសកកម្ម។[77] ជាមួយគ្នានោះដែរ អង្គភាពសាធារណៈ មន្ត្រីរាជការដែលចាត់តាំង ត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ ក្នុងការប្រតិបត្តិ និងការអនុវត្តបេសកកម្មរបស់អង្គភាពសាធារណៈ ឬ គ្រប់មន្ត្រីរាជការដែលត្រូវបានចៅក្រមស៊ើបសួរចាត់តាំង ត្រូវតែជូនព័ត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅនៃបេសកកម្មទាក់ទងនឹងការលំបាកដែលខ្លួនជួបប្រទះ។ ទាក់ទងនឹងលទ្ធផលដែលជាសំឡេងដែលថតបានពីការស្តាប់អង្គភាពសាធារណៈ ឬ មន្ត្រីរាជការដែលបំពេញបេសកកម្មនោះ ត្រូវធ្វើការចម្លងទៅជាលាយលក្ខណ៍អក្សរដែលឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសំឡេងដែលថតបាននោះ ដើម្បីប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។

### ១.២. ការចាត់ឲ្យស៊ើបសួរជំនួស

បន្ទាប់ពីបានធ្វើការអត្ថាធិប្បាយទាក់ទងជាមួយនឹងការស្រាវជ្រាវ ដែលធ្វើឡើងដោយផ្ទាល់របស់ចៅក្រមស៊ើបសួររួចមក ក្នុងចំណុចនេះសូមធ្វើការលើកយកនូវការបង្គាប់ឲ្យស៊ើបសួរជំនួសពីចៅក្រមស៊ើបសួរទៅឲ្យចៅក្រមស៊ើបសួរផ្សេងទៀត (ទូទាំងប្រទេស) ឬ មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈការចេញដីកាចាត់ឲ្យស៊ើបសួរជំនួស។ មូលហេតុដែលនាំឲ្យមានការចាត់ឲ្យស៊ើបសួរជំនួសនោះ គឺដោយសារកត្តាមួយចំនួនទាក់ទងនឹងភូមិសាស្ត្រ ឬ ការជួបនូវឧបសគ្គមួយចំនួន ជាហេតុនាំឲ្យមិនអាចបំពេញនូវកិច្ចការរបស់ខ្លួនបាន។ ដូច្នេះចៅក្រមស៊ើបសួរត្រូវធ្វើការផ្ទេរសិទ្ធិអំណាចរបស់ខ្លួនតាមរយៈ (១.២.១) **ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ** ឬ (១.២.២) **ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌** ក្នុងការបំពេញកិច្ចស៊ើបសួរជំនួស។

#### ១.២.១. ការស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរ

នៅពេលដីកាចាត់ឲ្យស៊ើបសួរជំនួសចេញឲ្យដល់ចៅក្រមស៊ើបសួរណាម្នាក់ នាំឲ្យចៅក្រមនោះទទួលបាននូវកិច្ចដែលត្រូវធ្វើតាមដីកាចាត់ឲ្យស៊ើបសួរពីចៅក្រមដើមនោះ។ ជាក់ស្តែងនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបញ្ជាក់ពីកិច្ចដែលត្រូវធ្វើដែលមានលក្ខណៈច្បាស់លាស់។ យោងតាមស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា១៧៤ បានបញ្ញត្តិថា កិច្ចដែលចៅក្រមស៊ើបសួរផ្សេងធ្វើត្រូវបញ្ជាក់ក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួសដែលការបញ្ជាក់នោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើសដែលចោទប្រកាន់។ ជាមួយគ្នានេះដែរ ដីកានោះត្រូវតែមានការណែនាំឲ្យបានច្បាស់លាស់ ដោយមិនត្រូវមានលក្ខណៈមិនច្បាស់លាស់ទេទាក់ទងនឹងកិច្ចដែលបង្គាប់ឲ្យស៊ើបសួរ។ ឧទាហរណ៍៖ ចៅក្រមស៊ើបសួរបានចេញដីកាចាត់ឲ្យស៊ើបសួរជំនួសទៅកាន់

[77] id

ចៅក្រមស៊ើបសួរផ្សេងនៃតុលាការផ្សេងទៀត ហើយគាត់បានកំណត់នៅក្នុងដីកានោះអំពីការចាត់ឲ្យមានការសួរចម្លើយជនត្រូវចោទ ឬ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ កាន់តែពិសេសជាងនេះទៅទៀត ដីកាចាត់ឲ្យស៊ើបសួរជំនួសក៏ត្រូវតែកំណត់ចិរវេលាសម្រាប់ធ្វើការចាត់ឲ្យស៊ើបសួរផងដែរ។ ពោល គឺមានចុះរយៈពេល ដើម្បីឲ្យចៅក្រមស៊ើបសួរអនុវត្តនូវកិច្ចរបស់ខ្លួន។ ជាក់ស្តែង ដីកានេះត្រូវតែមានចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រាដោយចៅក្រមស៊ើបសួរ (ដើម) ដើម្បីឲ្យដីកានោះមានអានុភាពត្រឹមត្រូវ។ ដូច្នេះ ប្រសិនបើក្នុងករណីដែលលើសរយៈពេល ដែលបានកំណត់ក្នុងដីការចាត់ឲ្យស៊ើបសួរជំនួសចៅក្រម ដែលទទួលភារកិច្ចតាមដីកា ត្រូវស្នើសុំពន្យាពេល ឬ អាចបញ្ចប់តាមកាលកំណត់ក្នុងដីកានោះតែម្តង។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរអាចត្រូវដកហូតដីកាចាត់ឲ្យស៊ើបសួរជំនួសបានគ្រប់ពេល ប្រសិនបើចៅក្រមស៊ើបសួរយល់ឃើញថាកិច្ចនោះគ្រប់គ្រាន់ហើយ ឬក៏បានប្រមូលបានតម្រុយគ្រប់គ្រាន់ហើយ។ គួរបញ្ជាក់ផងដែរ កាលណាដីកាចាត់ឲ្យស៊ើបសួរជំនួសត្រូវបានចេញឲ្យដល់ចៅក្រមស៊ើបសួរណាម្នាក់ ចៅក្រមស៊ើបសួរនោះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរដែលបានផ្ទេរឲ្យខ្លួន។ ចំពោះសិទ្ធិអំណាចដែលបានតាមដីកាចាត់ឲ្យស៊ើបសួរជំនួសទៅលើចៅក្រមស៊ើបសួរផ្សេងទៀតនេះ មានលក្ខណៈទូលាយជាងការចាត់ឲ្យស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌ទៅទៀត ទាក់ទងនឹងវិធានការស្រាវជ្រាវ ឬ អំណាចរបស់ចៅក្រមស៊ើបសួរ ជាអាទិ៍។

### ១.២.២. ការស៊ើបសួរជំនួសដោយមន្ត្រីនគរបាលយុត្តិធម៌

ដោយនៅក្នុងចំណុចមុន មានការរៀបរាប់ទាក់ទងជាមួយនឹងការចាត់ឲ្យស៊ើបសួរជំនួសតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសឲ្យទៅចៅក្រមស៊ើបសួរផ្សេងដើម្បីធ្វើការបំពេញកិច្ចស៊ើបសួរ។ ដូចនេះនៅក្នុងចំណុចនេះ នឹងធ្វើការរៀបរាប់អំពីការចាត់ឲ្យស៊ើបសួរជំនួសដល់មន្ត្រីនគរបាលយុត្តិធម៌វិញម្តង។ តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចដែលមានចែងក្នុងដីកា។ ការចាត់ឲ្យស៊ើបសួរជំនួសមានលក្ខណៈត្រូវបានកម្រិត ឬ មិនទូលំទូលាយ ដូចការចាត់ឲ្យស៊ើបសួរជំនួសដោយចៅក្រមស៊ើបសួរផ្សេងទេ មានន័យថាមន្ត្រីនគរបាលយុត្តិធម៌បំពេញកិច្ចរបស់ខ្លួនតាមអ្វី ដែលបានកំណត់ក្នុងដីកាចាត់ឲ្យស៊ើបសួរតែប៉ុណ្ណោះ។ ហើយរាល់កិច្ចដែលមន្ត្រីនគរបាលយុត្តិធម៌បំពេញ ត្រូវស្ថិតក្រោមអំណាចរបស់ចៅក្រមស៊ើបសួរដែលចេញដីកានោះ។ ជាគោលការណ៍ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចដែលចៅក្រមស៊ើបសួរឲ្យស៊ើបសួរជំនួសនោះបានតែក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ។ ប៉ុន្តែជាអញ្ញត្រកម្មមន្ត្រីនគរបាលយុត្តិធម៌ក៏អាចបំពេញកិច្ចរបស់ខ្លួនក្រៅដែនដីរបស់ខ្លួន ឬ នៅលើក្នុងវិសាលភាពដែនដីជាតិទាំងមូលបាន។ កាលណាមន្ត្រីនគរបាយយុត្តិធម៌ធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ស្របពេលជាមួយគ្នានោះដែរ ចៅក្រម ដែលបានអនុញ្ញាតឲ្យមានការពន្លាតសមត្ថកិច្ចត្រូវជូនព័ត៌មានគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា

ដែលមានសមត្ថកិច្ចខាងដែនដី។[78] គួរបញ្ជាក់ថា កិច្ចដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើមានលក្ខណៈខុសពីចៅក្រមស៊ើបសួរធ្វើ ដែលកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ធ្វើបាននោះមានដូចជា (**១.២.២.១**) **ការស្តាប់ចម្លើយសាក្សី** (**១.២.២.២**) **ការស្តាប់ទូរស័ព្ទ** (**១.២.២.៣**) **ការធ្វើការឆែកឆេរ និងការចាប់យក** រួមជាមួយនឹង (**១.២.២.៤**)**ការឃាត់ខ្លួន**។

### ១.២.២.១. ការស្តាប់ចម្លើយសាក្សី

ក្នុងការស្តាប់ចម្លើយសាក្សី មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅសាក្សី ដែលខ្លួនគិតថាអាចផ្តល់ព័ត៌មានដែលមានតម្រុយបាន។ ក្នុងករណីដែលការកោះហៅនោះត្រូវបានសាក្សីមិនព្រមចូលខ្លួនដើម្បីផ្តល់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជូនចៅក្រមដើម្បីចេញបញ្ជាឲ្យចូលខ្លួន ដោយចុះអត្តសញ្ញាណនៃសាក្សីព្រមទាំងការចុះកាលបរិច្ឆេទ ហត្ថលេខា និងបោះត្រារបស់ចៅក្រមស៊ើបសួរ។ ហើយការបញ្ជានោះទៀតសោត ក៏អាចតម្រូវឲ្យមាននូវការប្រើកម្លាំងសាធារណៈ ដើម្បីបង្ខំឲ្យសាក្សីចូលបង្ហាញខ្លួនផងដែរ។[79] នៅពេលបញ្ចប់ភារកិច្ចរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការរាយការណ៍ និងកំណត់ហេតុជូនចៅក្រមស៊ើបសួរ។ ទន្ទឹមនឹងនេះដែរ មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងសួរចម្លើយជនត្រូវចោទ។

### ១.២.២.២. ការស្តាប់ទូរស័ព្ទ

ក្នុងការស្តាប់ទូរស័ព្ទរបស់មន្ត្រីនគរបាលយុត្តធម៌តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌អាចស្តាប់ការថតសន្ទនាទូរស័ព្ទ ការឆ្លងឆ្លើយ ឬ ការស្តាប់ និងការថតការឆ្លងឆ្លើយតាមមធ្យោបាយទូរគមនាគមន៍ ដូចជាទូរសារ ឬ អ៊ីនធើណែតបាន។ ក្រោយពេលដែលធ្វើការស្តាប់រួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកត្រូវធ្វើការចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេង ដែលថតបានដោយឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារនៃសម្លេងដែលថតបានពេលនោះឲ្យទៅចៅក្រមស៊ើបសួរ។

### ១.២.២.៣. ការធ្វើការឆែកឆេរ និងការចាប់យក

ធ្វើការឆែកឆេរ និងចាប់យក មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរនឹងចាត់យកវត្ថុតាង នៅទីនោះការឆែកឆេរធ្វើឡើងចំពោះមុខអ្នកកាន់កាប់ទីកន្លែងប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែងទេនោះ ការឆែកឆេរត្រូវធ្វើចំពោះសាក្សីពីររូបដែលមិនមែនជានគរបាលយុត្តិធម៌ ឬ កងរាជអាវុធហត្ថដែលជាកម្លាំងដែលរួមឆែកឆេរនោះឡើយ។ ការប្រតិបត្តិការរបស់មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវធ្វើឡើងមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចបានទេ។ បន្ទាប់ពីធ្វើការឆែកឆេរ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌បានស្វែងរកវត្ថុ

[78] មាត្រា៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[79] មាត្រា ១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ទាក់ទងតម្រុយបទល្មើស មន្ត្រីនគរបាលយុត្តិធម៌នោះត្រូវធ្វើការបិទស្លាកលើវត្ថុដែលចាប់បាន ធ្វើការបោះត្រា ព្រមទាំងធ្វើកំណត់ហេតុស្តីពីការធ្វើកំណត់ហេតុ។

### ១.២.២.៤. ការឃាត់ខ្លួន

តាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ទទួលបាននូវសិទ្ធិអំណាចក្នុងការឃាត់ខ្លួនជនត្រូវចោទ។ ជាក់ស្តែង នៅក្នុងអំឡុងពេលចុះប្រតិបត្តិការស៊ើបសួរ តាមដីកាចាត់ឲ្យស៊ើបសួរជំនួសរបស់ចៅក្រមស៊ើបសួរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឃាត់ខ្លួនបុគ្គល ដែលខ្លួនសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស។[80] ទន្ទឹមនឹងនេះដែរ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចធ្វើការឃាត់ខ្លួន បុគ្គលដែលខ្លួនយល់ឃើញថាអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុដែលបានកើតឡើងបានផងដែរ ក្នុងករណីមួយចំនួនដូចខាងក្រោម៖

- បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន
- មានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។[81]

លើសពីនេះទៅទៀត រាល់ពេលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើនូវកិច្ចសំខាន់ចំនួន៣ទាក់ទងនឹងកំណត់ហេតុ ដែលមានដូចជា ការធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួន ការចុះការឃាត់ខ្លួនក្នុងបញ្ជីនៃការឃាត់ខ្លួន និងការធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន។ ក្នុងន័យនេះមានន័យថានៅរាល់ពេលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការឃាត់ខ្លួនបុគ្គលណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួននោះ។[82] ស្របពេលជាមួយគ្នានោះដែរ គ្រប់ការឃាត់ខ្លួនក៏ត្រូវ ធ្វើការចុះនៅក្នុងបញ្ជីស្តីពីការឃាត់ខ្លួន[83]ផងដែរ ដើម្បីរក្សាទុកសម្រាប់ជូនទៅអាជ្ញាសាលាតុលាការ ក្នុងករណីដែលត្រូវការ។[84] ជាងនេះទៅទៀត មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុសរុបស្តីពីការឃាត់ខ្លួនរបស់ខ្លួនផងដែរ។[85] សូមបញ្ជាក់ផងដែរថា ការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌នៅក្នុងបរិបទនេះ ស្ថិតក្រោមអំណាច និងការគ្រប់គ្រងរបស់ចៅក្រមស៊ើបសួរ ដែលគាត់ជាអ្នកចេញដីកាចាត់ឲ្យស៊ើបសួរជំនួស។

## ផ្នែកទី២៖ សិទ្ធិអំណាចក្នុងការប្រើវិធានការនិរន្តរាយ

តើចៅក្រមស៊ើបសួរមានសិទ្ធិអំណាចអ្វីខ្លះក្នុងការប្រើវិធានការនិរន្តរាយ? ជាក់ស្តែង អំណាចរបស់ចៅក្រមស៊ើបសួរ សំដៅលើអំណាចក្នុងការចេញដីកាដើម្បីធានាឲ្យការប្រព្រឹត្តទៅនៃនីតិវិធីក្នុងដំណាក់កាល

---

[80] មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[81] id

[82] id

[83] បញ្ជីស្តីពីការឃាត់ខ្លួន ត្រូវមាននៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬ កងរាជអាវុធហត្ថ។

[84] មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[85] មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ស៊ើបសួរប្រកបដោយប្រសិទ្ធភាព និងភាពរលូន។ ក្នុងចំណុចបន្ទាប់ នឹងធ្វើការសិក្សាទៅលើ (**២.១**) **វិធានការនិរន្តរាយ** និង (**២.២**) **ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**។

**២.១. វិធានការនិរន្តរាយ**

តើអ្វីហៅថាវិធានការនិរន្តរាយ? វិធានការនិរន្តរាយ គឺជាវិធានការដែលចៅក្រមស៊ើបសួរប្រើសម្រាប់ទប់ស្កាត់មិនឲ្យមានអន្តរាយនៅក្នុងដំណាក់កាលស៊ើបសួរ ដោយវិធានការនេះបានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរចេញដីកាសំខាន់ៗដើម្បីធ្វើយ៉ាងណាដើម្បីធានាឲ្យការស៊ើបសួរដំណើរការទៅបានយ៉ាងរលូនទៅមុខដោយពុំមានឧបសគ្គ។ ទន្ទឹមនឹងនេះដែរ ដើម្បីស្វែករកនូវការពិតក្នុងរឿងក្តី ច្បាប់បានប្រគល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរ ដែលសិទ្ធិអំណាចនោះមានលក្ខណៈចាប់បង្ខំ ព្រមទាំងផ្តល់នូវការប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់ជនត្រូវចោទ នៅពេលដែលចៅក្រមប្រើប្រាស់សិទ្ធិអំណាចទាំងនេះ។ ក្នុងបរិបទនេះគឺមានន័យថា ចៅក្រមស៊ើបសួរអាចចេញដីកាដើម្បីប្រឆាំងទៅនឹងបុគ្គលដែលមិនព្រមឆ្លើយតប ឬ ចូលខ្លួនតាមដីកាកោះរបស់តុលាការ ដែលដីកាទាំងនេះរួមមាន (**២.១.១**) **ដីកាបង្គាប់ឲ្យចូលខ្លួន** (**២.១.២**) **ដីកាបង្គាប់ឲ្យនាំខ្លួន** (**២.១.៣**) **ដីកាបង្គាប់ឲ្យចាប់ខ្លួន** និង (**២.១.៤**) **ដីកាបង្គាប់ឲ្យឃុំខ្លួន**។

**២.១.១. ដីកាបង្គាប់ឲ្យចូលខ្លួន**

តើអ្វីទៅជាដីកាបង្គាប់ឲ្យចូលខ្លួន? ជាការពិតណាស់ ដីកាបង្គាប់ឲ្យចូលខ្លួន សំដៅទៅលើការបញ្ជាដល់បុគ្គលណាម្នាក់ ដើម្បីឲ្យចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ដែលដីកានេះចៅក្រមស៊ើបសួរអាចចេញចំពោះជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ដីកានេះមិនអាចចេញទៅលើសាក្សីបានឡើយ។ ជាទូទៅ ដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវបានចេញចំពោះជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាព ដើម្បីធ្វើការស្វែងរក និងបញ្ជាក់ឲ្យឃើញនូវការពិតអំពីអង្គហេតុ ក៏ដូចជាការស្វែងរកនូវជនពាក់ព័ន្ធដែលជាភស្តុតាងចាំបាច់ផងដែរ។ លើសពីនេះទៅទៀត នៅពេលចេញដីការនេះ ត្រូវធ្វើការជូនដំណឹងដល់ជនដែលពាក់ព័ន្ធ ដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ ឬ អាជ្ញាសាលា។[86] ជាមួយគ្នានោះដែរ ដើម្បីចេញនូវដីកានេះបាន ចៅក្រមស៊ើបសួរត្រូវតែគោរពនូវលក្ខខណ្ឌមួយចំនួន ដែលនឹងលើកឡើងនៅក្នុងចំណុចខាងក្រោមនេះ។

**២.១.១.១. លក្ខខណ្ឌ**

គួរបញ្ជាក់ផងដែរ ដីកាបង្គាប់ឲ្យចូលខ្លួន ធ្វើឡើងដើម្បីបញ្ជាដល់បុគ្គលដែលជាជនត្រូវចោទចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ក្នុងគោលបំណងធ្វើការសួរនូវព័ត៌មាន ដូចជាស្តាប់ចម្លើយ ឬ ការសួរចម្លើយអំពីរឿងហេតុ ដែលពាក់ព័ន្ធនឹងបទល្មើសដែលព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់។ យ៉ាងណាមិញ

[86] មាត្រា១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ដីកានេះត្រូវជាចាំបាច់ត្រូវមានចុះនិទ្ទេសដែលកំណត់អំពី៖

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ[87]
- ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលកំណត់
- ថ្ងៃ ខែ ឆ្នាំ ម៉ោង និងទីកន្លែងត្រូវចូលបង្ហាញខ្លួន[88]
- ឈ្មោះ និង ឋានៈចៅក្រមស៊ើបសួរ ដែលចេញដីកានេះ
- ចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។[89]

បើក្រឡេកទៅមើលការអនុវត្តជាក់ស្តែងវិញ បន្ទាប់ពីចុះនិទ្ទេសដែលបានរៀបរាប់ទាំងឡាយខាងលើរួចរាល់ហើយ ចៅក្រមស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងបោះត្រាជាចាំបាច់ដើម្បីឲ្យដីកានោះមានអានុភាពអនុវត្តបាន។[90]

### ២.១.១.២. ការអនុវត្តនៃដីកាបង្គាប់ឲ្យចូលខ្លួន

បន្ទាប់ពីចេញដីកាបង្គាប់ឲ្យចូលខ្លួន ត្រូវផ្តល់ដំណឹងដល់ជន ដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងអាជ្ញាសាលា ដែលត្រូវបញ្ជាក់បុគ្គលនោះអំពីកម្មវត្ថុនៃដីកា ដោយឲ្យជននោះទទួលយកនូវចុងដីកា ហើយត្រូវធ្វើការចុះហត្ថលេខា ឬក៏ផ្តិតមេដៃនៅលើដើមដីកានោះផងដែរ។ បន្ទាប់ពីនោះ ដើមដីកាដែលមានចុះហត្ថលេខាត្រូវបង្វិលជូនចៅក្រមស៊ើបសួរវិញ។ គួរបញ្ជាក់ផងដែរ មន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងអាជ្ញាសាលា ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីគ្រប់ការលំបាកក្នុងការអនុវត្តបេសកកម្មរបស់ខ្លួន។[91] នៅក្នុងករណី បុគ្គលដែលត្រូវបានតុលាការកោះហៅតាមរយៈដីកាបង្គាប់ឲ្យចូលខ្លួននោះ មិនព្រមចូល ឬ បដិសេធចូលខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរនឹងធ្វើការចេញនូវដីកាបង្គាប់ឲ្យនាំខ្លួន។

### ២.១.២. ដីកាបង្គាប់ឲ្យនាំខ្លួន

តើអ្វីទៅជាដីកាបង្គាប់ឲ្យនាំខ្លួន? ជាក់ស្តែង ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាដីកាដែលធ្វើឡើងក្នុងន័យជាការបញ្ជាដល់កម្លាំងសាធារណៈឲ្យនាំខ្លួនបុគ្គលណាម្នាក់នៅចំពោះមុខចៅក្រមស៊ើបសួរ។[92] ចំពោះបុគ្គលដែលជាកម្មវត្ថុដែលកំណត់ក្នុងដីកានេះអាចជាជនត្រូវចោទ ឬ បុគ្គលណាម្នាក់ដែលមានតម្រុយពិរុទ្ធភាព។ យោងតាម

[87] អត្តសញ្ញាណបុគ្គលមានដូចជា៖ ឈ្មោះ ភេទ សញ្ជាតិ ទីកន្លែងកំណើត អាសយដ្ឋាន។

[88] កាលបរិច្ឆេទដែលបានកំណត់ឲ្យជូលបង្ហាញខ្លួន។

[89] មាត្រា១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[90] ទម្រង់នៃដីកាបង្គាប់ឲ្យចូលខ្លួនមានកំណត់ក្នុង ឧបសម្ព័ន្ធទី១០។

[91] មាត្រា១៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[92] មាត្រា១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ក្រមនីតិវិធីព្រហ្មទណ្ឌបច្ចុប្បន្ន ចៅក្រមស៊ើបសួរមិនអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនទៅលើសាក្សីបានទេ ទោះបីជាសាក្សីនោះរឹងទទឹងមិនព្រមចូលខ្លួនតាមការកោះហៅក៏ដោយ ដែលបញ្ញត្តិនេះសបញ្ជាក់ពីសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ។ ទោះបីជាមានការបញ្ញត្តិបែបនេះក៏ដោយ ក៏ពុំមែនមានន័យថា ចៅក្រមស៊ើបសួរគ្មានសិទ្ធិអំណាចបង្ខំសាក្សីឲ្យចូលខ្លួន នៅពេលសាក្សីរឹងទទឹងមិនព្រមចូលបង្ហាញខ្លួននោះឡើយ។ ជាក់ស្តែង ចៅក្រមស៊ើបសួរអាចបង្ខំសាក្សីឲ្យចូលខ្លួនបាន តាមរយៈការស្នើសុំកងកម្លាំងសាធារណៈ[93]ដើម្បីបង្ខំសាក្សីដែលរឹងទទឹងឲ្យបង្ហាញខ្លួនបាន។[94]

### ២.១.២.១. លក្ខខណ្ឌ

ដីកាបង្គាប់ឲ្យនាំខ្លួន គឺត្រូវធ្វើឡើងដោយគោរពតាមលក្ខខណ្ឌមួយចំនួន ដោយដីកានេះអាចចេញបានចំពោះតែជនត្រូវចោទ ឬ ជនដែលមានតម្រុយពិរុទ្ធភាពតែប៉ុណ្ណោះ។ ប៉ុន្តែដីកានេះពុំអាចចេញចំពោះសាក្សីបាននោះទេ។ មួយវិញទៀត ដីកានេះអាចចេញបានចំពោះបទល្មើសជាប្រភេទបទមជ្ឈិម និងបទឧក្រិដ្ឋតែប៉ុណ្ណោះ ដោយមិនអាចចេញទៅលើបទលហុបានទេ។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួន នៅក្នុងករណីដែលជនដែលត្រូវបានតុលាការកោះហៅ មិនព្រមចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួន។ ប៉ុន្តែ ក្នុងករណីជនត្រូវចោទមិនបានរត់គេចខ្លួន តែជននោះនៅតែពុំចូលខ្លួនតាមដីកាបង្គាប់ឲ្យចូលខ្លួនក្តី ចៅក្រមស៊ើបសួរក៏អាចចេញនូវដីកានេះបាន ប្រសិនបើគាត់អាចដឹង ឬ កំណត់នូវទីកន្លែងរបស់ជននោះ។

ជាទូទៅ ចៅក្រមស៊ើបសួរ ចេញដីកាបង្គាប់ឲ្យចូលខ្លួនមុន ទើបក្រោយមកចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឲ្យនាំខ្លួនជាក្រោយ ក្នុងករណីដែលបុគ្គលដែលត្រូវបានបង្គាប់ឲ្យចូលខ្លួននោះ បានបដិសេធមិនព្រមចូលខ្លួនតាមការបង្គាប់ ឬមិនចូលខ្លួន។ ប៉ុន្តែក្នុងករណីដែលចៅក្រមស៊ើបសួរគិតថាជាការចាំបាច់ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យនាំខ្លួនភ្លាមៗបានតែម្តង ដោយមិនចាំបាច់ចេញដីកាបង្គាប់ឲ្យចូលខ្លួនជាមុននោះទេ។ ចំពោះនិទ្ទេសនៅក្នុងដីកាបង្គាប់ឲ្យនាំខ្លួន សង្កេតឃើញថាមិនមានលក្ខណៈខុសគ្នាពីដីកាបង្គាប់ឲ្យចូលខ្លួននោះទេ ដែលត្រូវចុះនិទ្ទេសដូចជាៈ

- អត្តសញ្ញាណបុគ្គលដែលពាក់ព័ន្ធ
- ឈ្មោះបទល្មើស និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស
- ឈ្មោះ និងឋានៈចៅក្រមស៊ើបសួរ ដែលចេញដីកានេះ
- ចុះកាលបរិច្ឆេទ និងហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។

[93] កងកម្លាំងសាធារណៈ អាចជាកងរាជអាវុធហត្ថ ឬ មន្ត្រីនគរបាល ជាអាទិ៍ដែលបម្រើប្រយោជន៍សាធារណៈ ដែលត្រូវបានចាត់តាំងឲ្យបំពេញកិច្ចការងារអ្វីមួយ។

[94] មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ក្រោយពីការចុះនិទ្ទេសរួចហើយចៅក្រមស៊ើបសួរចាំបាច់ត្រូវតែចុះកាលបរិច្ឆេទ ហត្ថលេខា ក៏ដូចជាបោះត្រាលើដីកា ដើម្បីឲ្យដីកានោះមានអានុភាពត្រឹមត្រូវអនុវត្តតាមច្បាប់។

**២.១.២.២. ការអនុវត្តនៃដីកាបង្គាប់ឲ្យនាំខ្លួន**

ចំពោះការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន គឺជាតួនាទីរបស់នគរបាលយុត្តិធម៌។ ក្នុងករណីបន្ទាន់ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬ កងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ។[95] មន្ត្រីនគរបាលយុត្តិធម៌មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គលដែលពាក់ព័ន្ធមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចបានឡើយ។ ចំណែក ការបញ្ជូនដីកាវិញ ឃើញថាក្រឡាបញ្ជីត្រូវប្រគល់ដើមដីកានេះ ទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកអនុវត្តដីកា។ មួយវិញទៀត នៅក្នុងការបំពេញបេសកកម្មរបស់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ចៅក្រមស៊ើបសួរអំពីការអនុវត្តរបស់ខ្លួន។ បន្ទាប់ពីមន្ត្រីនគរបាលយុត្តិធម៌ធ្វើការចាប់ខ្លួនរួចរាល់ហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវនាំខ្លួនបុគ្គលដែលពាក់ព័ន្ធនោះទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរ ឬ ដល់អ្នកជំនួស[96] យ៉ាងយូរបំផុតថ្ងៃបន្ទាប់។ ប្រសិនបើការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឲ្យមានសេរីភាពវិញ។ ប៉ុន្តែបើមានមូលហេតុនៃកាលៈទេសៈ[97]បុគ្គល ដែលពាក់ព័ន្ធមិនអាចត្រូវនាំទៅបង្ហាញខ្លួនដល់ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានទេ ត្រូវតែនាំខ្លួននេះទៅក្នុងអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬ ទៅក្នុងពន្ធនាគារ។ ចំពោះចិរវេលាឃុំខ្លួនបុគ្គលណាម្នាក់តាមរយៈការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន គឺត្រូវតែរាប់បញ្ចូលទៅក្នុងចិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន។[98]

**២.១.៣. ដីកាបង្គាប់ឲ្យចាប់ខ្លួន**

ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺបញ្ជាចេញដោយចៅក្រមស៊ើបសួរដើម្បីបង្គាប់ដល់កម្លាំងសាធារណៈឲ្យស្រាវជ្រាវចាប់ និងឲ្យនាំបុគ្គលដែលជាជនត្រូវចោទ ឬ បុគ្គលដែលមានតម្រុយពិរុទ្ធភាពទៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ដើម្បីឃុំឃាំងទុក។[99] លើសពីនេះ ដីកាបង្គាប់ឲ្យចាប់ខ្លួនជាវិធានការមួយដែលមានលក្ខណៈចាប់បង្ខំ ដែលចេញដីកានេះដើម្បីឲ្យមន្ត្រីអនុវត្តច្បាប់ចាប់ខ្លួនជនត្រូវចោទដើម្បីយកមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ យ៉ាងណាមិញ ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវបានចេញដោយចៅក្រមស៊ើបសួរក៏ដោយ ប៉ុន្តែចំពោះការធានានូវប្រសិទ្ធភាព ក្រមនីតិវិធីព្រហ្មទណ្ឌតម្រូវឲ្យ នៅពេលមុនចេញដីកានេះ ចៅក្រមស៊ើបសួរត្រូវ

[95] មាត្រា១៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[96] អ្នកជំនួសក្នុងករណីបរិបទនេះ អាចជាចៅក្រមជំនួសផ្សេងទៀត ឬ ក្រឡាបញ្ជី។

[97] មូលហេតុនៃកាលៈទេសៈពិសេស សំដៅទៅលើករណីមួយចំនួនដូចជា គ្រោះធម្មជាតិ ប្រធានសក្ដិ ជាអាទិ៍។

[98] មាត្រា១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[99] មាត្រា១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ទទួលយោបល់ពីព្រះរាជអាជ្ញាក្នុងដីកានេះជាមុនសិន ដើម្បីសម្រេចនូវមូលហេតុក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញាផងដែរ។

**២.១.៣.១. លក្ខខណ្ឌ**

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួនបានចំពោះជនត្រូវចោទដែលមានតម្រុយពិរុទ្ធភាពពោល គឺមិនអាចចេញទៅលើសាក្សីបានទេ។ មួយវិញទៀត ដីកានេះចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោមៈ

- បង្គាប់ឲ្យចាប់ខ្លួនជនត្រូវចោទ ឬ បុគ្គលណាដែលមានតម្រុយពិរុទ្ធភាព
- បទល្មើសដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ
- បុគ្គលដែលពាក់ព័ន្ធបានគេចខ្លួនមិនដឹងនៅកន្លែងណា( នៅក្នុងដែនដីព្រះរាជាណាចក្រកម្ពុជា ) ឬ ស្ថិតនៅក្រៅដែនដីព្រះរាជាណាចក្រកម្ពុជា។[100]

ទោះបីជាបានបំពេញនូវលក្ខខណ្ឌខាងលើក៏ដោយ ប៉ុន្តែដីកានេះត្រូវសុំយោបល់ពីព្រះរាជអាជ្ញាដូចដែលបានរៀបខាងលើព្រមទាំងមានមូលហេតុផងដែរ។ ហើយចំពោះការជូនដំណឹងទៅកាន់ព្រះរាជអាជ្ញាអំពីការស្នើឲ្យចាប់ខ្លួននេះ ចៅក្រមស៊ើបសួរត្រូវធ្វើឡើងតាមរយៈដីកាបញ្ជូនឲ្យឆ្លើយ។ មូលហេតុនៃការជូនដំណឹងសុំយោបល់ពីព្រះរាជអាជ្ញា គឺដោយសារតែការផ្អែកលើហេតុផល ព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកទទួលបន្ទុក និងជាអ្នកមានភារកិច្ចក្នុងការអនុវត្ត និងការផ្សព្វផ្សាយដីកាបង្គាប់ឲ្យចាប់ខ្លួនផ្ទាល់។ ម៉្យាងវិញទៀតយោបល់ដែលព្រះរាជអាជ្ញាធ្វើការឆ្លើយតបចំពោះការចាប់ខ្លួនលើជនពាក់ព័ន្ធ គឺមិនជាប់ជាកាតព្វកិច្ចដល់ចៅក្រមស៊ើបសួរនោះទេ។ ក្នុងន័យនេះចង់សំដៅថា ចៅក្រមស៊ើបសួរមានសិទ្ធិឯករាជ្យពេញលេញក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួន ដោយមានមូលហេតុ សំអាងហេតុ និងសំអាងច្បាប់ត្រឹមត្រូវ។

ទន្ទឹមនឹងនេះ ដីកានេះត្រូវចុះនិទ្ទេសៈ

- កំណត់អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ
- កំណត់បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើស
- កំណត់ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា
- បន្ទាប់ពីចុះនិទ្ទេសរួច ចៅក្រមស៊ើបសួរត្រូវតែចុះកាលបរិច្ឆេទ ចុះហត្ថលេខា និងបោះត្រាដើម្បីឲ្យដីកានេះត្រឹមត្រូវតាមច្បាប់។[101]

ការនិទ្ទេសទាំងនេះត្រូវតែគោរពតាម បើពុំដូច្នេះទេ ដីកានេះនឹងមានមោឃភាព ។

[100] មាត្រា១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[101] មាត្រា១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

### ២.១.៣.២. ការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន

ការអនុវត្តដីកានេះ ជាតួនាទីរបស់ព្រះរាជអាជ្ញា ដែលគាត់ជាអ្នកធានារ៉ាប់រងក្នុងការផ្សព្វផ្សាយដីកានេះ។ ទាក់ទងទៅនឹងការផ្សព្វផ្សាយ ឃើញថាអាចធ្វើបានទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។ ចំពោះការផ្សព្វផ្សាយក្នុងស្រុក អាចធ្វើបានតាមរយៈកាសែត ផេកហ្វេសបុក ជាអាទិ៍។ ចំណែក ការផ្សព្វផ្សាយក្រៅប្រទេស អាចធ្វើបានតាមរយៈក្រសួងយុត្តិធម៌ ដោយមានមន្ត្រីនគរបាលជាជំនួយ។ ក្នុងនោះ ព្រះរាជអាជ្ញាធ្វើឡើងតាមរយៈក្រសួងយុត្តិធម៌ដែលផ្ញើទៅតាមស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាទៅកាន់ប្រទេសរបស់ជនដែលជាកម្មវត្ថុនៃដីកាបង្គាប់ឲ្យចាប់ខ្លួននោះ ឬ តាមដោយយន្តការនានាដែលមានប្រសិទ្ធភាព។ ផ្អែកតាមសកម្មភាពខាងលើនេះ បង្ហាញឲ្យឃើញថាការអនុវត្តដីកាបង្គាប់ឲ្យចាប់ខ្លួន មានវិសាលភាពអាចធ្វើឡើងទាំងក្នុងប្រទេស និងក្រៅប្រទេស។ ពិសេសជាងនេះទៅទៀត ការអនុវត្តដីកាក៏ជាតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តដីកាផងដែរ ក្នុងនាមខ្លួនជាអ្នកចាប់ខ្លួនបុគ្គលដែលបានកំណត់នៅក្នុងដីកា ដើម្បីបញ្ជូនទៅកាន់តុលាការ។ គួរបញ្ជាក់ផងដែរ ព្រះរាជអាជ្ញាត្រូវប្រគល់ដើមដីកាដល់មន្ត្រីនគរបាលយុត្តិធម៌រយៈយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីឲ្យមន្ត្រីនគរបាលយុត្តិធម៌យកដីកានេះចុះទៅចាប់បុគ្គលដែលបានកំណត់ក្នុងដីកានៅទីលំនៅឋានរបស់គេ ដោយការចាប់នោះមិនត្រូវធ្វើឡើងមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានទេដោយហេតុថាគឺជាការគោរពសិទ្ធិលំនៅឋានរបស់បុគ្គលឯកជន។ បន្ទាប់ពីចាប់ខ្លួន និង ឃុំខ្លួននៅពន្ធនាគាររួចមក មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនបុគ្គលដែលពាក់ព័ន្ធនោះទៅបង្ហាញចំពោះមុខចៅក្រមស៊ើបសួរ ឬ អ្នកជំនួសចៅក្រមស៊ើបសួរក្នុងរយៈពេលខ្លីបំផុតប្រសិនបើស្ថិតនៅក្នុងដំណាក់កាលស៊ើបសួរនៅឡើយ។ ម៉្យាងវិញទៀតបុគ្គលដែលមិនបានបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរ ឬ អ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួនទេនោះ បុគ្គលត្រូវធ្វើការស្តាប់ចម្លើយពីព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួនធ្វើការស្តាប់ចម្លើយ។ បន្ទាប់ពីពេលព្រះរាជអាជ្ញានោះមក ព្រះរាជអាជ្ញាត្រូវធ្វើកំណត់ហេតុ ដើម្បីបញ្ជូនទៅចៅក្រមស៊ើបសួរ។[102]

ដីកាបង្គាប់ឲ្យចាប់ខ្លួន មានអានុភាពបង្គាប់ដល់កម្លាំងសាធារណៈឲ្យធ្វើការចាប់នឹងនាំខ្លួនជនត្រូវចោទ ឬ បុគ្គលណាដែលមានតម្រុយពិរុទ្ធភាពដែលធ្វើការចាប់ខ្លួនទៅកាន់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ដើម្បីឲ្យមណ្ឌលឃុំខ្លួនយកឲ្យប្រធានពន្ធនាគារទទួលយកនឹងឃុំខ្លួនជននោះ។ នៅពេលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនជននោះទៅដល់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន នោះត្រូវតែរក្សាដើមដីកា ឬ ចុងដីកាទុកដែលបានបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម។[103] ទោះបីជាយ៉ាងណាក៏ដោយ ដីកានេះមិនត្រូវ

[102] មាត្រា២០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[103] id

បានបាត់បង់អានុភាពនៅពេល ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយបិទការស៊ើបសួរនោះទេ។ ពោល គឺដីកានេះនៅតែមានអានុភាពដដែល ដរាបណាបណ្ដឹងអាជ្ញាមិនទាន់រលត់។ ទន្ទឹមនឹងនេះដែរ ចំពោះថិរវេលាដែលត្រូវឃាត់ខ្លួនបុគ្គលណាម្នាក់ តាមរយៈដីកាបង្គាប់ឲ្យចាប់ខ្លួនត្រូវរាប់បញ្ចូលជាមួយថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នប្រសិនបើមាន។

### ២.១.៤. ការឃុំខ្លួនបណ្ដោះអាសន្ន

តើអ្វីទៅជាការឃុំខ្លួនបណ្ដោះអាសន្ន? ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាការដកសិទ្ធិសេរីភាពដល់បុគ្គលដែលជាជនត្រូវចោទ ដែលប៉ះពាល់ដល់សិទ្ធិក្នុងការដើរហើរដល់ជននោះ។ ជាក់ស្ដែង ការឃុំខ្លួនបណ្ដោះអាសន្ន ជាការប្រើនូវអំណាចបង្ខំរបស់ចៅក្រមស៊ើបសួរ ដែលមានលក្ខណៈពិសេសជាងនៅដំណាក់កាលផ្សេងៗទៀត។ ពោល គឺវាមានភាពទូលំទូលាយ ប៉ុន្តែត្រូវគោរពនូវលក្ខខណ្ឌផងដែរ។

#### ២.១.៤.១. លក្ខខណ្ឌ

ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានទប់ស្កាត់មួយដែលមានចរិកលក្ខណៈរឹងពឹងបំផុតនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលវិធានការនេះត្រូវបានតុលាការអនុវត្តចំពោះជនត្រូវចោទ ដែលត្រូវបានចោទពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ មួយវិញទៀត ការឃុំខ្លួនបណ្ដោះអាសន្ននេះអាចអនុវត្តបានតែនៅក្នុងករណីមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម ដែលច្បាប់បានផ្ដន្ទាទោស ដាក់ពន្ធនាគារ ស្មើ ឬ លើសពី១ឆ្នាំ។ ករណីនេះ មានន័យថាប្រសិនបើបទល្មើសជាបទមជ្ឈិមដែលត្រូវបានផ្ដន្ទាទោសមិនលើសពី១ឆ្នាំ ឬ ត្រឹមតែជាបទលហុទេនោះ គឺមិនមែនជាមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នបានឡើយ។ ឧទាហរណ៍៖ ជនត្រូវចោទបានប្រព្រឹត្តបទលួច ដែលត្រូវផ្ដន្ទាទោសពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន)រៀល តាមមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនបណ្ដោះអាសន្នបាន។ ជាទូទៅ នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ជនត្រូវចោទត្រូវបានដាក់ក្រោមការត្រួតពិនិត្យរបស់តុលាការ។ ប៉ុន្តែចៅក្រមស៊ើបសួរមានអំណាចបង្គាប់ឲ្យឃុំខ្លួនជនត្រូវចោទបាននៅពេលដែលការឃុំខ្លួននោះ ជាមូលហេតុដើម្បីបង្ការនូវអន្តរាយមួយចំនួននៅក្នុងនីតិវិធីដែលមានចែងក្នុងមាត្រា២០៥ដូចតទៅ៖

១. ដើម្បីបញ្ចប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតឡើងសារជាថ្មី

២. ដើម្បីរារាំងកុំឲ្យមានការគាបសង្កត់ ដូចជាសាក្សី ជនរងគ្រោះ ឬ ដើម្បីរារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

៣. ដើម្បីរក្សាភស្តុតាង ឬ តម្រុយជាសម្ភារ

៤. ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

៥. ដើម្បីការពារសន្តិសុខឲ្យជនត្រូវចោទ

៦. ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស។[104]

### ២.១.៤.២. ការអនុវត្តការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបានតាមរយៈដីកាចំនួនពីរ គឺទីមួយ ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងទីពីរ ដីកាបង្គាប់ឲ្យឃុំខ្លួន ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ឬ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នធ្វើឡើង គឺគ្រាន់តែបញ្ជាក់ប្រាប់ជន ដែលជាកម្មវត្ថុនៃដីកាឲ្យដឹងអំពីរយៈពេល នៃឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ។ លើសពីនេះទៅទៀត ចៅក្រមស៊ើបសួរ ត្រូវធ្វើការចេញនូវដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នមុនសិន ទើបក្រោយមកគាត់អាចចេញនូវដីកាបង្គាប់ឲ្យឃុំខ្លួនបាន។ ក្នុងបរិបទនេះ គឺមានន័យថា បន្ទាប់ពីចៅក្រមស៊ើបសួរចេញនូវដីកាឃុំខ្លួនបណ្តោះអាសន្នហើយ គាត់ត្រូវចេញដីកាបង្គាប់ឲ្យឃុំខ្លួនមួយទៀត ដើម្បីឲ្យប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនអាចទទួលយក និងធ្វើការឃុំខ្លួនបុគ្គលដែលជាកម្មវត្ថុនៃដីកាឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនបាន។ ផ្ទុយទៅវិញ ប្រសិនបើគ្មានដីកាដីកាបង្គាប់ឲ្យឃុំខ្លួននេះទេ ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនពុំអាចទទួលយក និងឃុំខ្លួនបុគ្គលដែលជាកម្មវត្ថុនៃដីកាឃុំខ្លួនបណ្តោះអាសន្នបានឡើយ ទោះបីជាមានដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក៏ដោយ។ គួរបញ្ជាក់ផងដែរថា ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន គឺគ្រាន់តែបញ្ជាក់ប្រាប់ជនដែលជាកម្មវត្ថុនៃដីកាឲ្យដឹងអំពីរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយក្នុងដីកានោះត្រូវមានកំណត់អំពីអត្តសញ្ញាណ របស់ជនត្រូវចោទដែលនឹងត្រូវបានឃុំខ្លួន ព្រមជាមួយនឹងសំអាងហេតុយ៉ាងត្រឹមត្រូវ។[105] លើសពីនេះទៅទៀត ក្រោយពេលដែលមានការចេញដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នហើយ ចៅក្រមស៊ើបសួរត្រូវឲ្យដំណឹងដល់ជនត្រូវចោទឲ្យបានដឹងអំពីការឃុំខ្លួនរបស់គេ ក្នុងគោលបំណងដើម្បីឲ្យជនត្រូវចោទ ឬ មេធាវីរបស់ខ្លួនអាចបង្ហាញមធ្យោបាយការពារទាក់ទងការឃុំខ្លួនបណ្តោះអាសន្ននេះ។[106]

ជាក់ស្តែង និទ្ទេសដែលត្រូវចុះក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនគឺត្រូវតែចុះដូចខាងក្រោម៖

- លេខ ថ្ងៃ ខែ ឆ្នាំ សំណុំរឿង
- អត្តសញ្ញាណរបស់ជនត្រូវចោទ
- ប្រភេទបទល្មើស ដែលបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

[104] មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[105] ទម្រង់នៃដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នមានកំណត់ក្នុង ឧបសម្ព័ន្ធទី១១។

[106] មាត្រា២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

- ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា
- ដីកានេះត្រូវមានចុះលេខនៃការចេញដីកា ស្របតាមលំដាប់លេខរៀងនៃសៀវភៅចុះលេខដីកាបង្គាប់ឲ្យឃុំខ្លួន។

អ្វីដែលសំខាន់នោះ ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ ដើម្បីឲ្យមានអានុភាពអនុវត្ត។[107] ក្នុងការអនុវត្តដីកា នគរបាលយុត្តិធម៌ គឺជាអ្នកអនុវត្តដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងដីកាបង្គាប់ឲ្យឃុំខ្លួន ដោយធ្វើការចាប់ខ្លួនបុគ្គលដែលជាកម្មវត្ថុនៃដីកានេះបញ្ជូនទៅកាន់ពន្ធនាគារ ឬ មណ្ឌលឃុំខ្លួន ដើម្បីធ្វើការឃុំខ្លួនជាបណ្ដោះអាសន្ន។ ក្នុងពេលជាមួយគ្នានេះដែរ ក្រោយពីការចាប់ខ្លួនហើយនគរបាលយុត្តិធម៌ត្រូវបង្ហាញដីកាបង្គាប់ឲ្យឃុំខ្លួនទៅកាន់ប្រធានពន្ធនាគារ ឬ មណ្ឌលឃុំខ្លួនដើម្បីឲ្យទទួលយកបុគ្គលនោះឃុំទុកក្នុងពន្ធនាគារជាបណ្ដោះអាសន្ន។

### ២.១.៤.៣. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវធ្វើឡើងដោយមានថិរវេលាខុសគ្នា រវាងការឃុំខ្លួនបណ្ដោះអាសន្នលើនីតិជន និងលើអនីតិជន។

### ក. ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នចំពោះនីតិជន

ចំពោះការឃុំខ្លួនបណ្ដោះអាសន្ន ដែលអនុវត្តលើនីតិជនក្នុងបទឧក្រិដ្ឋ ត្រូវធ្វើឡើងមិនអាចលើសពី ៦ខែបានទេ។ សូមបញ្ជាក់ផងដែរថា ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន មិនត្រូវធ្វើលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់ឡើយ។ លើសពីនេះទៅទៀត នៅពេលផុតថិរវេលាឃុំខ្លួន ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួនបណ្ដោះអាសន្នបានចំនួន២ដង ដោយម្ដងបាន ៦ខែ ដោយចៅក្រមស៊ើបសួរផ្អែកតាមសំអាងហេតុត្រឹមត្រូវដែលជាមូលហេតុនៃការពន្យារពេល។ ចំណែក ការឃុំខ្លួនក្នុងបទមជ្ឈិមវិញ ចៅក្រមស៊ើបសួរអាចឃុំខ្លួនមិនអាចលើសពី ៤ខែនោះទេ។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរមិនអាចឃុំខ្លួនជនត្រូវចោទលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ។ ឧទាហរណ៍៖ បើសិនជនត្រូវចោទត្រូវបានចោទប្រកាន់ពីបទលួច ដែលត្រូវផ្ដន្ទាទោសពី ៦ខែ ទៅ៣ឆ្នាំ និងពិន័យជាប្រាក់ពី ១,០០០,០០០ (មួយលាន)រៀល ទៅ៦,០០០,០០០ (ប្រាំមួយលាន)រៀល តាមមាត្រា៣៥៦នៃក្រមព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមិនអាចធ្វើការឃុំខ្លួនលើស៣ខែនោះទេ។ ម៉្យាងវិញទៀត នៅពេលថិរវេលានៃការឃុំខ្លួនផុតថិរវេលា ចៅក្រមស៊ើបសួរអាចពន្យារពេលការឃុំខ្លួននោះបានរយៈពេល២ខែ ដោយពន្យារបានតែម្ដងគត់ ដោយនៅពេលចេញដីកាដែលមានសំអាងហេតុត្រឹមត្រូវ។ ជាងនេះទៅទៀត ចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ចៅក្រមស៊ើបសួរអាចធ្វើការឃុំខ្លួនជនត្រូវចោទបានដោយមិនលើសពី ១ឆ្នាំនោះទេ ដោយអាចពន្យារពេលបាន

[107] មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ចំនួន ២ដង ដោយម្តងបាន ១ឆ្នាំ។ ពិសេសជាងនេះទៅទៀត នៅគ្រប់ពេលដែលចៅក្រមស៊ើបសួរធ្វើការពន្យារពេលឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវធ្វើការជូនដំណឹងដល់ជនត្រូវចោទ ឬ មេធាវីជនត្រូវចោទឲ្យដឹង ដើម្បីមេធាវីបង្ហាញមធ្យោបាយការពារកូនក្តីរបស់ខ្លួន។

**ខ. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នចំពោះអនីតិជន**

ចំពោះអនីតិជនអាយុតិចជាងអាយុ១៤ឆ្នាំ មិនអាចត្រូវបានធ្វើការឃុំខ្លួននោះទេ ដោយចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជននោះឲ្យទៅឪពុកម្តាយ អាណាព្យាបាល ឬ មជ្ឈមណ្ឌលអប់រំថែរក្សាជាបណ្តោះអាសន្នសិន ដើម្បីរង់ចាំសេចក្តីសម្រេចរបស់តុលាការ។ ប៉ុន្តែការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងចំពោះអនីតិជនអាយុចាប់ពី១៤ដល់ក្រោម១៨ឆ្នាំបាន។ ចំពោះការឃុំបណ្តោះអាសន្នដែលអនុវត្តលើអនីតិជន ក្នុងបទឧក្រិដ្ឋ ដែលមានអាយុតិចជាង១៦ឆ្នាំ ត្រូវធ្វើឡើងមិនអាចលើសពី៤ខែបានទេ។ ដោយឡែក ចំពោះការឃុំបណ្តោះអាសន្នដែលអនុវត្តលើអនីតិជន ក្នុងបទឧក្រិដ្ឋ ដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោយ១៨ឆ្នាំ ត្រូវធ្វើឡើងមិនអាចលើសពី៦ខែបានទេ។ រីឯ ការឃុំបណ្តោះអាសន្នដែលអនុវត្តចំពោះអនីតិជនក្នុងបទមជ្ឈិម ដែលមានអាយុតិចជាង១៦ឆ្នាំ ត្រូវធ្វើឡើងមិនអាចលើសពី២ខែបានទេ។ ម្យ៉ាងវិញទៀត ចំពោះការឃុំបណ្តោះអាសន្នដែលអនុវត្តលើអនីតិជន ក្នុងបទមជ្ឈិម ដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោយ១៨ឆ្នាំ ត្រូវធ្វើឡើងមិនអាចលើសពី៤ខែបានទេ។ សូមបញ្ជាក់ផងដែរថា ការឃុំនៅក្នុងបទមជ្ឈិមមិនអាចធ្វើឡើងលើសពាក់កណ្តាលនៃអប្បបរមានៃទោសដែលច្បាប់កំណត់ឡើយ។ ការឃុំខ្លួនលើអនីតិជនក៏មិនអាចពន្យារពេលបានផងដែរ។

**២.២. ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**

តើការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការធ្វើឡើងនៅពេលណា? ជាការពិតណាស់ នៅពេលដែលចៅក្រមស៊ើបសួរបានសម្រេចថាមិនធ្វើការឃុំខ្លួនបណ្តោះអាសន្នទៅលើជនត្រូវចោទទេនោះ ចៅក្រមស៊ើបសួរមានសិទ្ធិក្នុងការដាក់ជននោះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ នៅក្នុងកថាខណ្ឌទីមួយខាងលើ បានរៀបរាប់រួចមកហើយទាក់ទិននឹងអំណាចរបស់ចៅក្រមស៊ើបសួរក្នុងការចេញដីកាទាំងបួន ពិសេសនោះ គឺដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នដែលជាវិធានការតឹងរឹង ដើម្បីអនុវត្តទៅលើជនត្រូវចោទក្នុងគោលបំណងបង្ការនូវអន្តរាយទាំងឡាយដែលកើតឡើងក្នុងដំណើរការនីតិវិធី។ ដូច្នេះ នៅក្នុងកថាខណ្ឌនេះនឹងធ្វើការរៀបរាប់ទាក់ទងនឹងយន្តការ ដែលអនុវត្តទៅលើជនត្រូវចោទ នៅពេលចៅក្រមស៊ើបសួរសម្រេចមិនឃុំខ្លួនជននោះ ឬ ដោះលែងជននោះឲ្យនៅក្រៅឃុំវិញម្តង ដែលយន្តការនេះត្រូវបានក្រមនីតិវិធីព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា ហៅថាការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ការដាក់ឲ្យនៅក្រោមការត្រួតពិនិត្យ សំដៅទៅលើយន្តការមួយដែលតុលាការសម្រេចកម្រិតនូវសេរីភាពមួយចំនួនរបស់ជនត្រូវចោទដែលកំពុងនៅក្រៅឃុំ ឬ ដែលសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ។ ជាការពិតណាស់ តុលាការ

ប្រើប្រាស់យន្តការនេះ ដើម្បីត្រួតពិនិត្យសកម្មភាពជនត្រូវចោទក្នុងន័យដើម្បីបង្ការកុំឲ្យមានអន្តរាយកើតឡើងធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អរបស់សង្គម និងដំណើរការនីតិវិធី។ ក្នុងការអនុវត្តជាក់ស្តែង ការដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវចេញ (២.២.១) **ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ហើយ (២.២.២) **ដីកានេះក៏អាចត្រូវបានកែប្រែ** បានផងដែរ។

## ២.២.១. ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺធ្វើឡើងដើម្បីបង្គាប់ឲ្យជនត្រូវចោទដែលកំពុងនៅក្រៅឃុំ ឬ ត្រូវបានចៅក្រមស៊ើបសួរសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ អនុវត្តនូវកាតព្វកិច្ចមួយចំនួនដែលមានក្នុងដីកានេះ។ ជាការពិតណាស់ ដីកានេះមានកំណត់នូវកាតព្វកិច្ចមួយចំនួនសម្រាប់អនុវត្តដើម្បីបង្ការភាពចលាចល ឬ អន្តរាយណាមួយជាយថាហេតុប៉ះពាល់ដល់នីតិវិធី។ ក្នុងនោះដែរ ចៅក្រមស៊ើបសួរអាចកំណត់កាតព្វកិច្ចមួយ ឬ ច្រើនផ្អែកទៅតាមកាលៈទេសៈនៃបទល្មើស ឬ មានការបារម្ភថាជនត្រូវចោទលែងចូលបង្ហាញខ្លួនតាមការកោះហៅពីមន្ត្រីតុលាការតទៅទៀត។

### ២.២.១.១. លក្ខខណ្ឌ

ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវគោរពលក្ខខណ្ឌមួយចំនួន ពោល គឺជនដែលអាចជាកម្មវត្ថុនៃដីកានេះត្រូវតែជាជនត្រូវចោទកំពុងនៅក្រៅឃុំ ដែលត្រូវបានចោទប្រកាន់បទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតាមក្រមព្រហ្មទណ្ឌ។ ប៉ុន្តែចំពោះបទលហុវិញ ចៅក្រមស៊ើបសួរពុំអាចប្រើនូវយន្តការនេះបានទេ។ ទន្ទឹមនឹងនេះដែរ ដីកានេះពុំអាចអនុវត្តទៅលើអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំនោះឡើយ។ ក្នុងនោះ ដីកានេះធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ ឬ តាមរយៈដីកាសន្និដ្ឋានសរុបរបស់ព្រះរាជអាជ្ញា។[108] ក្នុងករណីដែលចៅក្រមស៊ើបសួរយល់ឃើញថា ជនត្រូវចោទដែលកំពុងនៅក្រៅឃុំនឹងមិនចូលខ្លួនតាមការកោះហៅទេនោះ ចៅក្រមស៊ើបសួរអាចធ្វើការដាក់ជននោះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន។ មួយវិញទៀត ចៅក្រមស៊ើបសួរមានសិទ្ធិសម្រេចចេញដីកាដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយឆន្ទានុសិទ្ធិដោយមានកំណត់នូវ កាតព្វកិច្ចមួយចំនួននៅក្នុងដីកា បើគាត់គិតថាវាជាមូលហេតុក្នុងការបង្ការនូវអន្តរាយ ដែលអាចបង្កឡើងពីជនត្រូវចោទដែលកំពុងនៅក្រៅឃុំ។ ម្យ៉ាងទៀត ចំពោះករណី ដែលមានការស្នើសុំឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរបស់ព្រះរាជអាជ្ញាតាមរយៈដីកាសន្និដ្ឋានរបស់ខ្លួន ទៅកាន់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចទៅលើការស្នើសុំរបស់ព្រះរាជអាជ្ញានេះក្នុងរយៈពេល ៥ថ្ងៃ ចៅក្រមស៊ើបសួរត្រូវតែចេញនូវដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោម

[108] មាត្រា២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ការត្រួតពិនិត្យតាមផ្លូវតុលាការ ឬ ដីកាសម្រេចបដិសេធការសុំឲ្យដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។[109] ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេល ៥ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចប្ដឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសបាន។[110] មួយវិញទៀត ប្រសិនបើចៅក្រមស៊ើបសួរសម្រេចថាដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងពីដីកាសម្រេចនោះក្នុងរយៈពេលយ៉ាងខ្លីបំផុតនេះទៅកាន់ព្រះរាជអាជ្ញា និងជនត្រូវចោទ។ លើសពីនេះទៅទៀត នៅក្នុងដីកាបង្គាប់ចៅក្រមស៊ើបសួរត្រូវកំណត់ឲ្យច្បាស់លាស់នូវកាតព្វកិច្ច ដែលធ្វើឡើងដើម្បីកម្រិតសេរីភាពជនត្រូវចោទ ដែលកំពុងនៅក្រៅឃុំ។ យោងតាមមាត្រា២២៣ កាតព្វកិច្ចដែលចៅក្រមអាចកំណត់នៅក្នុងដីកាមានដូចជាៈ

១.មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ

២.មិនត្រូវផ្លាស់ប្ដូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

៣.មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

៤.ត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬ កងរាជអាវុធហត្ថដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៥.ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

៦.ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ

៧.មិនត្រូវបើកបររថយន្ត

៨.មិនត្រូវទទួល ឬ ជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

៩.ដាក់ប្រាក់ធានាដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ

១០.មិនត្រូវកាន់កាប់ ឬ តាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធដែលជនត្រូវចោទកាន់កាប់

១១.ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

១២.មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។

ចំពោះការអនុវត្តនៃលក្ខខណ្ឌទាំង១២ចំណុចខាងលើនេះ ចៅក្រមស៊ើបសួរមិនអាចហាមឃាត់ការអនុវត្តនូវ អាណត្តិបោះឆ្នោត ឬ សកម្មភាពខាងសហជីពបានទេ។ គួរបញ្ជាក់ផងដែរថា ដីកានេះ ត្រូវតែចុះនិទ្ទេស

[109] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ឆ្នាំសិក្សា, ទំព័រ៤២។

[110] មាត្រា២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ឲ្យបានច្បាស់លាស់ ប្រសិនបើពុំបានចុះនិទ្ទេសនោះទេ នឹងនាំឲ្យដីកានេះលែងមានអានុភាព ឬ គ្មានតម្លៃជាកម្មវត្ថុសម្រាប់អនុវត្តឡើយ។ ដែលនិទ្ទេសនោះមានដូចជា៖

១.ឈ្មោះចៅក្រមស៊ើបសួរ

២.ឈ្មោះក្រឡាបញ្ជី

៣.លេខ សំណុំរឿង ព្រមទាំងមាន ថ្ងៃ ខែ ឆ្នាំ

៤.លេខនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ព្រមទាំងមានចុះ ថ្ងៃ ខែ ឆ្នាំ

៥.លេខនៃដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ព្រមទាំងចុះ ថ្ងៃ ខែ ឆ្នាំ

៦.អត្តសញ្ញាណរបស់ជនត្រូវចោទ

៧.សំអាងហេតុ

៨.ប្រភេទនៃបទល្មើសដែលត្រូវបានចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

៩.ផ្នែកទីនៃការសម្រេចរបស់ដីកា

១០.ហត្ថលេខា និងត្រារបស់ចៅក្រមស៊ើបសួរ រួមទាំងហត្ថលេខារបស់ក្រឡាបញ្ជី។[111]

ជាមួយគ្នានោះដែរ ដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនេះ ត្រូវបញ្ជាក់នូវចំណាត់ការបន្ត ប្រសិនបើជនត្រូវចោទបានគេចវេះមិនគោរពកាតព្វកិច្ច ដែលបានកំណត់នៅក្នុងផ្នែកទីនៃការសម្រេចនៃដីកា។ ប៉ុន្តែបើយោងតាមច្បាប់ស្ដីពីអនីតិជនវិញ គឺអាចធ្វើការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ដែលចៅក្រមស៊ើបសួរអាចដាក់ជនត្រូវចោទ ដែលជាអនីតិជនឲ្យនៅក្រោមការត្រួតពិនិត្យរបស់តុលាការបានគ្រប់ពេល ដើម្បីជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីអនីតិជនត្រូវចោទត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារ។ ឧទាហរណ៍៖ ក្នុងដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការអាចកំណត់ដូចជា៖

- ការបង្គាប់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ ឬ ទំនុកបម្រុងរបស់អនីតិជន ឬ ក្រុមគ្រួសារណាមួយសមស្រប
- ការបង្គាប់ឲ្យស្ថិតក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬ មណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- ការបង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬ សេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀត ដែលតុលាការយល់ឃើញ ឬ ពិនិត្យឃើញថាមានសមស្រប។[112]

[111] ទម្រង់នៃដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានកំណត់ក្នុង ឧបសម្ព័ន្ធទី១២។

[112] មាត្រា៤១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

**២.២.១.២. ការអនុវត្តដីកា**

បន្ទាប់ពីចៅក្រមស៊ើបសួរ ចេញដីកាសម្រេចបង្គាប់ឲ្យដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ជាអ្នកយកដីកានេះទៅអនុវត្ត។ ជនត្រូវចោទត្រូវតែអនុវត្តនូវកាតព្វកិច្ច ដែលចៅក្រមស៊ើបសួរបានកំណត់ក្នុងដីកា ដោយមិនអាចមានចេតនាគេចវេះបានទេ។ ប្រសិនបើជននោះបានគេចវេះមិនគោរពតាមលក្ខខណ្ឌដែលមានកំណត់ក្នុងដីកា ចៅក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីជាជនត្រូវចោទត្រូវបានចោទប្រកាន់ក្នុងបទល្មើសដែលមានទោសជាប់ពន្ធនាគារមានរយៈពេលប៉ុន្មានក៏ដោយ។ មួយវិញទៀត ទោះបីជាជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នអស់រយៈពេលអតិបរមាដែលមានចែងក្នុងមាត្រា២០៨ មាត្រា២១០ មាត្រា២១៣ និងមាត្រា២១៤ក៏ដោយ។[113] ចំពោះការអនុវត្តដីកាបង្គាប់ដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានលក្ខណៈខុសគ្នាពីការអនុវត្តទៅលើអនីតិជន។ បើយោងតាមច្បាប់ស្ដីពីយុត្តិធម៌អនីតិជនវិញ សង្កេតឃើញថាអនីតិជនក៏អាចត្រូវបានដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ ចៅក្រមស៊ើបសួរបានដែរ ដើម្បីជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីដែលជនត្រូវចោទជាអនីតិជនត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគារ។[114] ឧទាហរណ៍៖ ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការចំពោះអនីតិជន ដោយកំណត់នូវលក្ខណ្ឌមួយចំនួន ដូចជា៖

- ការបង្គាប់ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្ដាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ អ្នកអាណាព្យាបាលទូទៅ ឬ ទំនុកបម្រុងរបស់អនីតិជន ឬ ក្រុមគ្រួសារណាមួយសមស្រប
- ការបង្គាប់ឲ្យស្ថិតក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬ មណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាល ដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- ការបង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬ សេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប ។

**២.២.២. ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ**

ការកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ សំដៅទៅលើការកែប្រែខ្លឹមសារ ការលុបចោល ឬ ការបញ្ចូលនូវកាតព្វកិច្ចថ្មី ដល់ជនត្រូវចោទដែលត្រូវបានដាក់តាមការត្រួតពិនិត្យតាមផ្លូវតុលាការ។[115] ទាក់ទងនឹងការកែប្រែ គឺអាចធ្វើឡើងបានតាមរយៈ (**២.២.២.១**) **ការផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ** (**២.២.២.២**) **បណ្ដឹង**

[113] មាត្រា២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[114] ចំពោះការអនុវត្តការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានតែលើអនីតិជនដែលមានអាយុ១៤ ដល់ក្រោម ១៨ឆ្នាំ។

[115] មាត្រា២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

**សុំកែប្រែរបស់ព្រះរាជអាជ្ញា និង (២.២.២.៣) បណ្តឹងសុំកែប្រែដោយជនត្រូវចោទ ។**

### ២.២.២.១. ការផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ

ចំពោះចៅក្រមស៊ើបសួរអាចធ្វើការកែប្រែលុបចោល ឬ បញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា ហើយក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានផងដែរ។[116] ក្នុងការកែប្រែនេះទៀតសោត អាចត្រូវបានធ្វើឡើងដោយផ្អែកលើមូលហេតុជាក់ស្តែង ដោយចៅក្រមស៊ើបសួរអាចធ្វើការ បន្ថែម ឬ បន្ធូរបន្ថយទាក់ទងនឹងកាតព្វកិច្ច ដែលមានកំណត់ក្នុងដីកាត្រួតពិនិត្យតាមផ្លូវតុលាការ។ មូលហេតុជាក់ស្តែង ដែលចៅក្រមស៊ើបសួរផ្អែកក្នុងការបន្ថែម ឬ បន្ធូរបន្ថយកាតព្វកិច្ច ឬ លុបចោលកាតព្វកិច្ចទៅលើជនត្រូវចោទ គឺផ្អែកសំខាន់ទៅលើបុគ្គលិកលក្ខណៈជាក់ស្តែង ឬ ក៏ជាស្ថានភាពនៃជីវភាពជាក់ស្តែងរបស់ជនត្រូវចោទ។

ឧទាហរណ៍៖ ករណីចៅក្រមស៊ើបសួរបន្ថែមកាតព្វកិច្ច ជនត្រូវចោទបានទៅលេងនៅទីកន្លែងផុលមាន់ ហើយជាញឹកញាប់តែងតែប្រព្រឹត្តបទល្មើស។ ដូច្នេះ ដើម្បីជៀសវាងការប្រព្រឹត្តបទល្មើសនេះ ចៅក្រមស៊ើបសួរក៏បានបន្ថែមនូវកាតព្វកិច្ចមួយទៀត គឺហាមមិនឲ្យជននោះទៅទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ។[117] គួរបញ្ជាក់ផងដែរថា ចៅក្រមស៊ើបសួរយកដីកាចាស់មកកែប្រែដោយបន្ថែម ឬ បន្ធូរបន្ថយទៅលើកាតព្វកិច្ចដែលមានស្រាប់។

### ២.២.២.២. បណ្តឹងសុំកែប្រែដោយព្រះរាជអាជ្ញា

នៅគ្រប់ពេលទាំងអស់ ព្រះរាជអាជ្ញាអាចធ្វើការសុំលុបចោល ឬ កែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការតាមរយៈបណ្តឹងសុំកែប្រែ ឬ បណ្តឹងសុំលើកលែងការត្រួតពិនិត្យតាមផ្លូវតុលាការរបស់ខ្លួនទៅកាន់ចៅក្រមស៊ើបសួរ ដោយក្នុងនោះចៅក្រមស៊ើបសួរ ត្រូវធ្វើការសម្រេចទៅលើបណ្តឹងនេះក្នុងរយៈពេល ៥ថ្ងៃ។[118] ក្នុងករណីនៅក្នុងរយៈពេល ៥ថ្ងៃបន្ទាប់ពីចៅក្រមស៊ើបសួរទទួលបានបណ្តឹងនេះ ប៉ុន្តែគាត់ពុំបានធ្វើការឆ្លើយតបទេ ព្រះរាជអាជ្ញាអាចប្តឹងសុំតាមរយៈពាក្យសុំទៅកាន់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរវិញបាន។ ប៉ុន្តែក្នុងក្របខណ្ឌនេះ ចៅក្រមស៊ើបសួរយល់ស្របទៅនឹងបណ្តឹងរបស់ព្រះរាជអាជ្ញានេះ ចៅក្រមស៊ើបសួរត្រូវសម្រេចតាមពាក្យសុំរបស់ព្រះរាជអាជ្ញានេះតែម្តង។

ផ្ទុយមកវិញ ប្រសិនបើចៅក្រមស៊ើបសួរបដិសេធទៅនឹងពាក្យបណ្តឹងរបស់ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចបដិសេធនឹងពាក្យសុំរបស់ព្រះរាជអាជ្ញាត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា។

---

[116] id

[117] មាត្រា២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[118] មាត្រា២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

### ២.២.២.៣. បណ្ដឹងសុំកែប្រែដោយជនត្រូវចោទ

ក្រៅពីចៅក្រមស៊ើបសួរ និងព្រះរាជអាជ្ញាអាចធ្វើការកែប្រែលើដីកាដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបាន ក្នុងនោះជនត្រូវចោទក៏អាចមានសិទ្ធិដាក់ពាក្យសុំបានលើដីកានេះបានផងដែរ។[119] ការដាក់ពាក្យសុំកែប្រែ ឬ លើកលែងការត្រួតពិនិត្យតាមផ្លូវតុលាការគ្រប់ពេលវេលាបានផងដែរ ក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវបញ្ជូនពាក្យសុំរបស់ជនត្រូវចោទនោះភ្លាម ក៏ដូចជាសំណុំរឿងទៅព្រះរាជអាជ្ញាភ្លាមៗ ដើម្បីពិនិត្យ និងផ្ដល់យោបល់។ ក្នុងនោះផងដែរ ចៅក្រមស៊ើបសួរសម្រេច គឺត្រូវតែសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ បន្ទាប់ពីការបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ មួយវិញទៀត ដីកានេះត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតទៅព្រះរាជអាជ្ញា និងជនត្រូវចោទ។ ដោយឡែក ក្នុងករណីដែលចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរចេញសេចក្ដីសម្រេចបដិសេធទៅលើការស្នើសុំឲ្យលើកលែង ឬ ឲ្យកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ជនត្រូវចោទអាចធ្វើការស្នើដាក់ពាក្យសុំជាម្ដងទៀតបានក្នុងរយៈពេល ៥ថ្ងៃ គិតចាប់ពីថ្ងៃចេញដីកាលើពាក្យសុំពីមុន។ មួយវិញទៀត បើចៅក្រមស៊ើបសួរមិនសម្រេចលើពាក្យសុំក្នុងរយៈពេល ៥ថ្ងៃទេនោះ ជនត្រូវចោទអាចធ្វើពាក្យបណ្ដឹងទៅសភាស៊ើបសួរដើម្បីសម្រេចជំនួសចៅក្រមស៊ើបសួរ។[120] ទន្ទឹមនឹងនេះដែរ ជនត្រូវចោទអាចធ្វើការដាក់ពាក្យសុំឲ្យលើកលែង ឬ ឲ្យកែប្រែបានការត្រួតពិនិត្យតាមផ្លូវតុលាការបានជាថ្មីម្ដងទៀតបាន មុនពេលចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរសម្រេចលើពាក្យសុំពីមុន ហើយចំពោះការសម្រេចរបស់ចៅក្រមស៊ើបសួរ ឬ សភាស៊ើបសួរលើការស្នើសុំលើកលែង ឬ ឲ្យកែប្រែសារជាថ្មីនោះ ត្រូវធ្វើឡើងយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ ដែលត្រូវចាប់ផ្ដើមគិតពីពេលចេញសេចក្ដីសម្រេចលើពាក្យសុំពីមុន។[121] ជារួមមកមានន័យថា ចំពោះការស្នើសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការ ជនត្រូវចោទអាចធ្វើបានគ្រប់ពេលវេលា ដោយគេអាចធ្វើការដាក់ពាក្យសុំសារជាថ្មីម្ដងទៀតបាន ប្រសិនបើគេយល់ឃើញថា កាតព្វកិច្ចដែលត្រូវបានកំណត់ដោយតុលាការទៅលើជនជាប់ចោទ មានលក្ខណៈប៉ះពាល់ដល់ជីវភាពចាំបាច់ប្រចាំថ្ងៃរបស់ជនជាប់ចោទ។ ឧទាហរណ៍៖ ជនជាប់ចោទ “ក” ត្រូវបានដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយនៅចំណុចមួយក្នុងចំណោមចំណុចទាំងមូល នៃការកំណត់កាតព្វកិច្ច របស់តុលាការបានកំណត់ឲ្យដកហូតនូវបណ្ណបើកបររបស់ជនជាប់ចោទ “ក” ជាបណ្ដោះអាសន្ន។ ប៉ុន្តែ ដោយសារការដកបណ្ណបើកបរនោះ ធ្វើឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់គាត់ប្រចាំថ្ងៃ ទើបគាត់សុំឲ្យកែប្រែដោយស្នើសុំឲ្យតុលាការកែប្រែ ឬ លុបកាតព្វកិច្ចនេះចេញ។ លុះក្រោយមក ដោយសារតែជនជាប់ចោទ “ក” មានជម្ងឺធ្ងន់ធ្ងរប្រចាំកាយ ត្រូវទៅព្យាបាលនៅបរទេសជាចាំបាច់ ដែលការធ្វើដំណើរទៅបរទេសនោះ គឺជា

[119] មាត្រា២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[120] id

[121] id

សកម្មភាពដែលត្រូវបានតុលាការហាមឃាត់ នាំឲ្យបុគ្គលនេះ អាចធ្វើការស្នើសុំកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការម្តងទៀតបាន ទៅលើត្រង់ចំណុច "ហាមឃាត់មិនឲ្យធ្វើដំណើរទៅបរទេស" ប្រសិនបើ ការព្យាបាលជម្ងឺនៅបរទេសជាការចាំបាច់សម្រាប់ជនត្រូវចោទ។

# ជំពូកទី៣
# ការបិទការស៊ើបសួរ

# ជំពូកទី៣
# ការបិទការស៊ើបសួរ

តើការបិទការស៊ើបសួរនៅក្នុងដំណាក់កាលស៊ើបសួរជាអ្វី? ការបិទការស៊ើបសួរ គឺជាចំណុចបញ្ចប់នៃដំណាក់កាលស៊ើបសួរ ដែលចៅក្រមស៊ើបសួរត្រូវធ្វើឡើងនៅពេល ដែលគាត់យល់ឃើញថាការស៊ើបសួររបស់ខ្លួនទាក់ទងនឹងបទល្មើស គឺមានភាពពេញលេញ និងគ្រប់ជ្រុងជ្រោយអស់ហើយ។ ប៉ុន្តែ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពីនីតិវិធីមួយចំនួនដែលចៅក្រមស៊ើបសួរត្រូវបំពេញនៅពេលបិទបញ្ចប់នីតិវិធីស៊ើបសួរ ដែលនីតិវិធីនោះ ត្រូវបានហៅថានីតិវិធីត្រៀមមុនការបិទការស៊ើបសួរ[122]។ តាមរយៈនីតិវិធីនេះ មានន័យថា ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ភាគីអំពីការបិទបញ្ចប់នៃកិច្ចស៊ើបសួររបស់ខ្លួន។ ជាក់ស្តែង មុនពេលបិទការស៊ើបសួរក្នុងជំហានបឋម ចៅក្រមត្រូវជូនព័ត៌មានអំពីការបិទបញ្ចប់របស់ខ្លួនទៅកាន់ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ជនត្រូវចោទ និងមេធាវីរបស់ពួកគេ ដើម្បីឲ្យដឹងអំពីការបិទការស៊ើបសួរតាមរយៈការចេញលិខិតជូនព័ត៌មាន ឬ ជូនដំណឹង[123] ។[124] ដូច្នេះ នៅក្នុងចំណុចខាងក្រោមនេះ នឹងលើកយកនូវចំណុចនីតិវិធីសំខាន់ៗមួយចំនួន ដែលចៅក្រមត្រូវធ្វើដើម្បីបិទការស៊ើបសួរ ដោយក្នុងនោះមានដូចជា (**ផ្នែកទី១**) **នីតិវិធីត្រៀមបិទការស៊ើបសួរ** និង (**ផ្នែកទី២**) **ដីកាដំណោះស្រាយ**។

## ផ្នែកទី១៖ នីតិវិធីត្រៀមបិទការស៊ើបសួរ

### ១.១. ការបំពេញកិច្ចស៊ើបសួរបន្ថែម

បន្ទាប់ពីចៅក្រមស៊ើបសួរបញ្ជូនព័ត៌មាន ស្តីពីការត្រៀមបិទការស៊ើបសួររបស់ខ្លួនដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរួចរាល់ហើយ នៅក្នុងរយៈពេល ២ថ្ងៃក្រោយ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ជាមួយគ្នានេះដែរ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបើកផ្លូវសម្រាប់ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យមានសិទ្ធិក្នុងការចូលរួមនៅក្នុងដំណើរការនៃនីតិវិធីត្រៀមបិទការស៊ើបសួរ ប្រសិនបើគូអង្គទាំងបីនេះយល់ឃើញថា ការស៊ើបសួរនៅមិនទាន់ពេញលេញនៅឡើយ ឬ ក៏យល់ឃើញថាការស៊ើបសួរបន្ថែមមានប្រយោជន៍ ពួកគេអាចធ្វើការស្នើសុំឲ្យបំពេញកិច្ចបន្ថែមបាន។ ជាមួយគ្នានោះដែរ ការស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែមនោះ គឺ

[122] នីតិវិធីត្រៀមមុនការបិទការស៊ើបសួរ គឺជានីតិវិធីមួយដែលចៅក្រមស៊ើបសួរធ្វើឡើងដើម្បីជូនដំណឹងទៅកាន់ភាគីនៅក្នុងរឿងក្តីឲ្យដឹងអំពីការបិទការស៊ើបសួរ។

[123]លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, ទំព័រ៤៤។

[124] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។
ទម្រង់នៃលិខិតជូនដំណឹងស្តីពីការបិទបញ្ចប់ការស៊ើបសួរមានកំណត់ក្នុង ឧបសម្ព័ន្ធទី១៣។

អាចធ្វើទៅបានតាមរយៈ (១.១.១) **ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយព្រះរាជអាជ្ញា** និង (១.១.២) **ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។**

### ១.១.១. ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយព្រះរាជអាជ្ញា

នៅក្នុងដំណាក់កាលចៅក្រមស៊ើបសួរ ច្បាប់បានអនុញ្ញាត ឲ្យព្រះរាជអាជ្ញាអាចធ្វើការស្នើសុំឲ្យបំពេញកិច្ចបន្ថែមបានផងដែរ ប្រសិនបើលក្ខខណ្ឌមួយចំនួនដូចខាងក្រោមត្រូវបានបំពេញ។

#### ១.១.១.១. លក្ខខណ្ឌ

ព្រះរាជអាជ្ញាត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនទើបគាត់អាចធ្វើការស្នើសុំបំពេញកិច្ចបន្ថែមនោះបាន។ ប្រសិនបើគាត់យល់ឃើញថា ការស៊ើបសួរបន្ថែមនោះមានប្រយោជន៍ដើម្បីស្វែងរកឲ្យឃើញនូវការពិតក្នុងរឿងក្ដី ដូចជា ករណីចៅក្រមស៊ើបសួរមិនទាន់បានស្ដាប់ចម្លើយសាក្សី ឬ ដើមបណ្ដឹងរដ្ឋប្បវេណី ឬ ករណីព្រះរាជអាជ្ញាមានការសង្ស័យថាតម្រុយពិរុទ្ធភាពនៅមាននៅឡើយ ដែលករណីទាំងនេះ គឺជាមូលហេតុមិនអាចធ្វើការបិទការស៊ើបសួរបាន នាំឲ្យព្រះរាជអាជ្ញាអាចធ្វើការស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមទៅកាន់ចៅក្រមស៊ើបសួរបាន។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ រាល់ការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមពីសំណាក់ព្រះរាជអាជ្ញា អាចធ្វើទៅបានតែទៅលើរឿងក្ដីតែមួយប៉ុណ្ណោះ។ មានន័យថា ព្រះរាជអាជ្ញាមិនអាចស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើរឿងផ្សេងពីរឿងដែលខ្លួនបានចោទប្រកាន់នោះទេ។ គួរបញ្ជាក់ថា ព្រះរាជអាជ្ញាធ្វើការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមតាមឆន្ទានុសិទ្ធិរបស់គាត់តែប៉ុណ្ណោះ មិនមែនជាការជាប់នូវកាតព្វកិច្ចអ្វីនោះឡើយ។

#### ១.១.១.២. ការអនុវត្ត

ការបញ្ជូនរឿងពីចៅក្រមស៊ើបសួរទៅកាន់ព្រះរាជអាជ្ញានេះ គឺដោយសារតែព្រះរាជអាជ្ញាជាម្ចាស់នៃបណ្ដឹងអាជ្ញា ដោយព្រះរាជអាជ្ញាត្រូវត្រួតពិនិត្យ ហើយធ្វើការឆ្លើយតបក្នុងរយៈពេលសមរម្យ[125] គិតចាប់ពីថ្ងៃដែលគាត់ទទួលបានព័ត៌មាននៃការជូនដំណឹងរបស់ចៅក្រមស៊ើបសួរ។ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាការស៊ើបសួរមិនទាន់ពេញលេញ ឬ ស្នើសុំឲ្យបំពេញកិច្ចណាមួយដែលខ្លួនយល់ថាមានប្រយោជន៍ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យស៊ើបសួរបន្ថែមទៀតបាន។[126] ឧទាហរណ៍ដូចជា ការមិនបានសួរចម្លើយជនណាម្នាក់ ឬ ពុំបានស្ដាប់ចម្លើយនូវចម្លើយសាក្សី។ ក្នុងន័យនេះ ចំពោះការស្នើសុំរបស់ព្រះរាជអាជ្ញាទៅកាន់ចៅក្រមស៊ើបសួរ ឲ្យដើម្បីធ្វើកិច្ចស៊ើបសួរបន្ថែម ព្រះរាជអាជ្ញាត្រូវចេញដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម[127]

---

[125] រយៈពេលសមរម្យនៅក្នុងចំណុចនេះ មានន័យថាជារយៈដែលអាចធ្វើទៅបាន ព្រោះនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាពុំបានកំណត់រយៈពេលច្បាស់លាស់នោះទេ។

[126] មាត្រា១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[127] ដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម គឺជាសេចក្ដីសម្រេចបន្ថែមរបស់ព្រះរាជអាជ្ញាដែលចេញទៅឲ្យចៅក្រមស៊ើបសួរ ដើម្បីឲ្យចៅក្រមស៊ើបសួរ ស៊ើបសួរថែមទៀតលើអង្គហេតុដដែល។

ទៅលើចំណុចដែលគាត់យល់ឃើញថាជាកង្វះខាតមិនទាន់បានបំពេញ។[128] តាមរយៈការទទួលបាននូវដីកាចាត់ឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមពីព្រះរាជអាជ្ញានេះ បើសិនជាចៅក្រមស៊ើបសួរបដិសេធមិនបំពេញកិច្ចនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ រួមជាមួយសំអាងហេតុក្នុងរយៈពេល១៥ថ្ងៃ ក្រោយពីទទួលដំណឹង ហើយត្រូវជូនដំណឹងបន្ទាន់ទៅដល់ព្រះរាជអាជ្ញាក្នុងរយៈពេលសមរម្យ។[129] មួយវិញទៀត ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតអាចឲ្យព្រះរាជអាជ្ញា មានសិទ្ធិក្នុងការប្តឹងទៅសភាស៊ើបសួរ ក្នុងករណីដែលចៅក្រមស៊ើបសួរមិនបានឆ្លើយតបក្នុងរយៈពេល ១៥ថ្ងៃ ទៅនឹងការស្នើសុំរបស់ខ្លួន។ ពោល ព្រះរាជអាជ្ញាអាចប្តឹងតាមរយៈពាក្យសុំទៅកាន់សភាស៊ើបសួរ ដែលជាស្ថាប័នមានសមត្ថកិច្ចដើម្បីធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរវិញម្តង។[130] គួរបញ្ជាក់ផងដែរ នៅពេលចៅក្រមស៊ើបសួរសម្រេចតាម ឬ បដិសេធទៅលើការស្នើសុំរបស់ព្រះរាជអាជ្ញា គាត់ត្រូវតែធ្វើការជូនដំណឹងទៅកាន់ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ។

### ១.១.២. ការស្នើឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមដោយជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

ចំពោះការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម គឺច្បាប់មិនត្រឹមតែធ្វើការបើកផ្លូវដល់ព្រះរាជអាជ្ញាអាចធ្វើការស្នើសុំនោះទេ ប៉ុន្តែច្បាប់ថែមទាំងបានបើកផ្លូវដល់ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការធ្វើការស្នើសុំបំពេញកិច្ចបន្ថែមបានផងដែរ។ ប៉ុន្តែការស្នើសុំនេះមានលក្ខណៈចង្អៀតជាងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់ព្រះរាជអាជ្ញា។ ពោលគឺ មិនទូលំទូលាយដូចការស្នើសុំបំពេញកិច្ចដោយព្រះរាជអាជ្ញានោះឡើយ ។

#### ១.១.២.១. លក្ខខណ្ឌ

នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទទទួលដំណឹងអំពីការបិទការស៊ើបសួរពីចៅក្រមស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណី ក៏ដូចជា ជនត្រូវចោទ អាចស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមបានគ្រប់ពេលវេលាទៅកាន់ចៅក្រមស៊ើបសួរ ប្រសិនបើខ្លួនគិតថាមានប្រយោជន៍ចំពោះការបង្ហាញនូវការពិត។ ចំពោះ ដើមបណ្តឹងរដ្ឋប្បវេណី ឬ មេធាវីការពារក្តីរបស់ខ្លួន អាចធ្វើការស្នើសុំឲ្យចៅក្រមស៊ើបសួរបំពេញកិច្ចបន្ថែមមួយចំនួន ដូចជាការស្តាប់ចម្លើយរបស់សាមីខ្លួនផ្ទាល់ ការស្តាប់ចម្លើយសាក្សី ការសួរចម្លើយជនត្រូវចោទ សួរតទល់ និងចុះដល់ទីកន្លែង។[131] ចំណែកឯ ជនត្រូវចោទ ឬ មេធាវីការពារក្តីរបស់ខ្លួន ក៏អាចស្នើសុំទៅកាន់ចៅក្រមស៊ើបសួរក្នុងការបំពេញកិច្ចបន្ថែមបានដែរ ដូចជា ការសួរចម្លើយសាមីខ្លួន ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី

[128] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, ទំព័រ៤៥។

[129] មាត្រា១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[130] id

[131] មាត្រា១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ការសួរតទល់គ្នា ឬ ការចុះទៅដល់ទីកន្លែង ជាដើម។[132] ប៉ុន្តែ ការស្នើសុំនេះចាំបាច់ត្រូវតែគោរពនូវលក្ខខណ្ឌចាំបាច់មួយចំនួនដូចជា៖

- ការស្នើសុំត្រូវតែផ្តល់ផលប្រយោជន៍ក្នុងរឿងក្តី
- ការស្នើសុំត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលមិនអាចធ្វើឡើងដោយផ្ទាល់មាត់នោះទេ
- ការស្នើត្រូវតែមានសំអាងហេតុដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់ថា តើការស្នើសុំនេះដើម្បីអ្វី?

ឧទាហរណ៍៖ ជនត្រូវចោទបានស្នើសុំឲ្យធ្វើការស្តាប់ចម្លើយសាក្សី ដោយហេតុថាសាក្សីនោះ គឺអាចនឹងបង្ហាញឲ្យឃើញនូវការពិតនៃរឿងក្តី ដូច្នេះ ជនត្រូវចោទអាចស្នើទៅកាន់ចៅក្រមស៊ើបសួរដើម្បីធ្វើការបំពេញកិច្ចបន្ថែមបាន។

### ១.១.២.២. ការអនុវត្ត

ចំពោះការអនុវត្ត នៅពេលមានការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម ដែលធ្វើឡើងដោយ ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ ឬក៏ មេធាវីរបស់ពួកគេ ទៅកាន់ចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវតែធ្វើការសម្រេចលើការស្នើសុំនោះ ក្រោយពីទទួលពាក្យសុំ ដោយរយៈពេលសម្រេចនេះ គឺធ្វើឡើងក្នុងរយៈពេលឆាប់រហ័សមួយតាមដែលអាចធ្វើទៅបាន។ ផ្ទុយទៅវិញ ប្រសិនបើចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ ឬ មេធាវីរបស់ពួកគេទេនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធ រួមជាមួយសំអាងហេតុក្នុងរយៈពេល ១ខែ ក្រោយពីទទួលដំណឹង ហើយត្រូវជូនដំណឹងបន្ទាន់ទៅដល់ព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។[133] ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ដោយមូលហេតុគាត់មិនបានសម្រេចក្នុងថិរវេលា ១ខែ ទេនោះ ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ ឬ មេធាវីរបស់ពួកគេ អាចប្តឹងដោយផ្ទាល់ តាមរយៈពាក្យសុំទៅកាន់សភាស៊ើបសួរដើម្បីធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរនេះវិញបាន។ មានន័យថា ប្រសិនបើចៅក្រមស៊ើបសួរមានភាពអសកម្ម ឬក៏ ទុកសំណុំរឿងនោះចោលមិនព្រមធ្វើចំណាត់ការលើរឿងក្តីទេនោះ ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ ឬ មេធាវីរបស់ពួកគាត់ ក៏អាចធ្វើការស្នើទៅកាន់សភាស៊ើបសួរ ដែលជានាយឋានានុក្រមរបស់ចៅក្រមស៊ើបសួរដើម្បីធ្វើការសម្រេចជំនួសបានផងដែរ។ គួរបញ្ជាក់ផងដែរថា ដើមបណ្តឹងរដ្ឋប្បវេណី ឬ ជនត្រូវចោទ ឬ មេធាវីរបស់ពួកគេ អាចដាក់ពាក្យស្នើសុំនោះជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ហើយដាក់ទៅកាន់លេខាធិការដ្ឋាននៃសាលាដំបូង ដើម្បីវាយត្រាចូលនៅខាងរដ្ឋបាល។ បន្ទាប់ពីផ្នែកលេខាធិការដ្ឋាននោះបានពិនិត្យរួចរាល់ហើយ គេត្រូវធ្វើការបញ្ជូនពាក្យសុំនោះទៅកាន់ចៅក្រមស៊ើបសួរ ដែលត្រូវបានដាក់ស្នើសុំនោះតែម្តង។ តាមរយៈពាក្យស្នើសុំឲ្យបំពេញកិច្ចបន្ថែម

[132] មាត្រា១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[133] មាត្រា១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

នេះ ចៅក្រមស៊ើបសួរអាចសម្រេចតាម ឬ សម្រេចផ្ទុយពីកម្មវត្ថុដែលបានរៀបរាប់ក្នុងពាក្យស្នើសុំខាងលើនេះ។

### ១.២. ដីកាសន្និដ្ឋានស្ថាពរ

តើដីកាសន្និដ្ឋានស្ថាពរជាអ្វី? ជាការពិតណាស់ ដីកាសន្និដ្ឋានស្ថាពរ គឺជាសេចក្តីសម្រេចធ្វើឡើងដោយមានកំណត់នូវការបញ្ចេញនូវយោបល់ទាក់ទងនឹងការវិនិច្ឆ័យលើផ្នែកអង្គហេតុ និងផ្នែកអង្គច្បាប់របស់តំណាងអយ្យការដែលបានធ្វើការចោទប្រកាន់ ឬ ក៏លើកលែងការចោទប្រកាន់។ កាលណាការស៊ើបសួរត្រូវបានចប់សព្វគ្រប់ហើយនោះ ចៅក្រមស៊ើបសួរត្រូវចេញនូវសេចក្តីសម្រេចអំពីការបិទបញ្ចប់ការស៊ើបសួរបាន ហើយត្រូវជូនដំណឹងដល់ភាគីទាំងអស់ ដែលមានដូចជា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី មេធាវីរបស់ជនទាំងនោះ និងព្រះរាជអាជ្ញាចំពោះការបញ្ចប់ការស៊ើបសួររបស់ខ្លួន។ ក្នុងចំណុចនេះ នៅពេលដែលព្រះរាជអាជ្ញាបានទទួលដំណឹងអំពីការបិទការស៊ើបសួរពីចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវចេញដីកាសន្និដ្ឋានស្ថាពរនេះ ប្រសិនបើគាត់យល់ឃើញថាកិច្ចស៊ើបសួរត្រូវបានធ្វើឡើងពេញលេញចប់សព្វគ្រប់អស់ហើយ។

#### ១.២.១. លក្ខខណ្ឌ

ដូចបានលើកឡើងម្តងរួចហើយថា ដីកាសន្និដ្ឋានស្ថាពរ គឺជាសេចក្តីសម្រេចមួយរបស់ព្រះរាជអាជ្ញា ធ្វើឡើងដើម្បីជាការឆ្លើយតបទៅនឹងការជូនដំណឹងរបស់ចៅក្រមស៊ើបសួរអំពីការបញ្ចប់ការស៊ើបសួរ ដែលមានគោលបំណងក្នុងការបិទបញ្ចប់ការស៊ើបសួរ ដោយយល់ស្របទៅនឹងការបញ្ចប់ការស៊ើបសួររបស់ចៅក្រមស៊ើបសួរ។[134] ជាងនេះទៅទៀត ដើម្បីឲ្យដីកាសន្និដ្ឋានស្ថាពរ មានអានុភាពអនុវត្តបាន ដីកានោះត្រូវតែធ្វើឡើងដោយដោយគោរពតាមលក្ខខណ្ឌ ៣យ៉ាងគឺ៖

- លក្ខខណ្ឌទី១៖ អាចចេញបានក្នុងករណីព្រះរាជអាជ្ញា យល់ឃើញថា ការស៊ើបសួរមានលក្ខណៈពេញលេញ និងមូលសព្វគ្រប់ អាចធ្វើការជំនុំជម្រះបាន
- លក្ខខណ្ឌទី២៖ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានស្ថាពរនេះដោយភ្ជាប់ជាមួយនឹងសំណុំរឿង
- លក្ខខណ្ឌទី៣៖ ដីកាសន្និដ្ឋានស្ថាពរចាំបាច់ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរ ដែលមិនអាចធ្វើឡើងដោយផ្ទាល់មាត់ (តាមរយៈទូរស័ព្ទ ជាអាទិ៍) បាននោះទេ ហើយត្រូវមានសំអាងហេតុត្រឹមត្រូវផងដែរ។

សរុបជារួមមក លក្ខខណ្ឌទាំងអស់ ដែលបានរៀបរាប់ខាងលើនេះ ត្រូវតែគោរពតាម ដោយមិនអាចខ្វះលក្ខខណ្ឌណាមួយបានឡើយ។ ប្រសិនបើខ្វះនោះ នឹងនាំឲ្យដីកាសន្និដ្ឋានស្ថាពរនេះពុំមានអានុភាពឡើយ។ ទន្ទឹមនឹងនេះដែរ នៅក្នុងដីកាសន្និដ្ឋានជាស្ថាពររបស់ព្រះរាជអាជ្ញា លោកអាចធ្វើការប្តឹងសុំជាការបញ្ជូនទៅជំនុំជម្រះ ឬ ការលើកលែងការចោទប្រកាន់បានផងដែរ។

[134] ទម្រង់នៃដីកាសន្និដ្ឋានស្ថាពរមានកំណត់ក្នុង ឧបសម្ព័ន្ធទី១៤។

### **១.២.២. នីតិវិធី**

នៅពេលដែលព្រះរាជអាជ្ញាបានទទួលការជូនដំណឹងពីការបិទការស៊ើបសួរ ពិសេស គឺការទទួលបានសំណុំរឿងពីចៅក្រមស៊ើបសួររួចរាល់ហើយ ប្រសិនបើព្រះរាជអាជ្ញាពិនិត្យមើលសំណុំរឿងនោះ ហើយយល់ឃើញថា ការស៊ើបសួររបស់ចៅក្រមស៊ើបសួរពិតជាមានភាពពិតប្រាកដ ព្រមទាំងមូលសព្វគ្រប់អស់ហើយ ព្រះរាជអាជ្ញាត្រូវបញ្ជូនសំណុំរឿងនេះទៅកាន់ចៅក្រមស៊ើបសួរវិញ ដោយមានភ្ជាប់ជាមួយនូវដីកាសន្និដ្ឋានស្ថាពរព្រមទាំងមានសំអាងហេតុច្បាស់លាស់ ដែលសំអាងហេតុនោះ គឺជាទឡ្ហីករណ៍ រវាងអង្គហេតុ និងអង្គច្បាប់ ដែលលើកឡើងអំពី មូលហេតុ ដែលខ្លួនត្រូវបញ្ជូនដីកាសន្និដ្ឋានស្ថាពរនោះ។ កាន់តែពិសេសជាងនេះទៅទៀត សំណុំរឿង និងដីកាសន្និដ្ឋានស្ថាពរត្រូវបញ្ជូនឲ្យចៅក្រមស៊ើបសួរជាការឆ្លើយតប ក្នុងរយៈពេល ១៥ថ្ងៃ បើជនជាប់ចោទនោះនៅក្នុងឃុំ ឬ បើជនជាប់ចោទនោះមិននៅក្នុងឃុំនាំឲ្យមានរយៈពេល១ខែ គិតចាប់ពីពេលព្រះរាជអាជ្ញាទទួលបានសំណុំរឿង។[135]

ម៉្យាងវិញទៀតព្រះរាជអាជ្ញា អាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការសម្រេចបញ្ជូនជនត្រូវចោទទៅតុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ ដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។ សូមបញ្ជាក់ផងដែរ រាល់ការប្តឹងសុំឲ្យចៅក្រមស៊ើបសួរធ្វើការបញ្ជូនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន គឺពុំមានអានុភាពគតិយុត្តចាប់បង្ខំឲ្យចៅក្រមស៊ើបសួរធ្វើតាមដីកានោះឡើយ។

## **ផ្នែកទី២៖ ដីកាដំណោះស្រាយ**

តើអ្វីហៅថាដីកាដំណោះស្រាយ? ហើយដីកានេះត្រូវធ្វើឡើងនេះពេលណា? ដីកាដំណោះស្រាយ គឺជាសេចក្តីសម្រេច កើតឡើងពីសិទ្ធិអំណាចផ្តាច់មុខរបស់ចៅក្រមស៊ើបសួរ ដែលធ្វើឡើងនៅក្រោយពេលទទួលបានដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា។ ចំពោះការសម្រេចរបស់ចៅក្រមស៊ើបសួរក្នុងដីកាខាងលើអាចមានគោលបំណងពីរ គឺការបញ្ជូនទៅជំនុំជម្រះ ឬ ការលើកលែងការចោទប្រកាន់។ នៅក្នុងការចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវធ្វើឡើងដោយមាននូវសំអាងហេតុច្បាស់លាស់ បន្ទាប់មកត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីក្រោយពីចេញដីកានេះហើយ។[136] ជាងនេះទៅទៀត ចំពោះជម្រើស ដែលចៅក្រមស៊ើបសួរត្រូវចេញក្នុងដីកាដំណោះស្រាយមានលក្ខណៈជា (**២.១**) **ការបញ្ជូនទៅជំនុំជម្រះ** ឬ (**២.២**) **ការលើកលែងការចោទប្រកាន់**។

ចំណែកឯអនីតិជនវិញម្តង ឃើញថាចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពី

---

[135] មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[136] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន មុននឹងចេញដីកាដំណោះស្រាយ។[137] ជាមួយគ្នានោះដែរ ប្រសិនបើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើបាន ដោយមិនឲ្យលើសរយៈពេល១០ ថ្ងៃនៃការធ្វើការទេ។ នៅក្នុងករណីចាំបាច់ត្រូវទាមទារឲ្យមាននូវរបាយការណ៍ទាក់ទងនឹងអនីតិជន ពីព្រោះដើម្បីឲ្យដឹងពីស្ថានភាពរបស់អនីតិជននោះថា តើមានការប្រព្រឹត្តទៅយ៉ាងណា? ក្នុងគោលបំណងធ្វើការវាយតម្លៃរកចំណុចខ្លាំង ឬចំណុចខ្សោយ ដើម្បីរកដំណោះស្រាយ។

### ២.១. ការបញ្ជូនទៅជំនុំជម្រះ

ការបញ្ជូនទៅជំនុំជម្រះ ធ្វើឡើងនៅពេលចៅក្រមស៊ើបសួរបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ដោយបានស្វែងរកនូវភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដែលបង្ហាញថាជនត្រូវចោទពិតជាបានប្រព្រឹត្តនូវបទល្មើសដូចអ្វីដែលតុលាការបានធ្វើការចោទប្រកាន់មែន ក៏ដូចជា ចៅក្រមស៊ើបសួរបានរកឃើញថាជនត្រូវចោទមានពិរុទ្ធភាពគ្រប់គ្រាន់ស៊ីសង្វាក់នឹងអង្គហេតុ ឬ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីបញ្ជូនជននោះទៅជំនុំជម្រះ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដើម្បីបញ្ជូនជនជាប់ចោទទៅកាន់តុលាការជំនុំជម្រះពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម។ ការបញ្ជូនទៅជំនុំជម្រះអាចធ្វើទៅបានប្រសិនបើមានមូលហេតុដូចខាងក្រោមនេះ (២.១.១) **មូលហេតុនាំឲ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ** (២.១.២) **នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ** និង (២.១.៣) **អានុភាពនៃដីកាបញ្ជូនទៅជំនុំជម្រះ**។

#### ២.១.១. មូលហេតុនាំឲ្យមានការចេញដីកាបញ្ជូនទៅជំនុំជម្រះ

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិនូវមូលហេតុនៃការចេញដីកាដំណោះស្រាយដែលមានដូចជា៖

- ចៅក្រមស៊ើបសួររកឃើញពិរុទ្ធភាពគ្រប់គ្រាន់អាចធ្វើការបញ្ជូនទៅជំនុំជម្រះបាន
- បុគ្គលដែលបានប្រព្រឹត្តនោះបានប្រព្រឹត្តបទល្មើសពិតមែន(បទឧក្រិដ្ឋ,បទមជ្ឈិម,បទលហុ)
- មានភស្តុតាងសមល្មមដាក់បន្ទុកទៅលើជននោះបាន
- ជនត្រូវចោទគេស្គាល់អត្តសញ្ញាណត្រឹមត្រូវ។

#### ២.១.២. នីតិវិធីក្នុងការចេញដីកាបញ្ជូនទៅជំនុំជម្រះ

ក្រោយពីការបង្វិលដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាត្រលប់មកវិញ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយ ដែលគាត់ជ្រើសរើសការបញ្ជូនទៅជំនុំជម្រះទៅកាន់តុលាការជំនុំជម្រះ ប្រសិនបើយល់

[137] មាត្រា៤២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

ឃើញថាអំពើនោះ ជាបទឧក្រិដ្ឋ បទមជ្ឈិម ឬ បទលហុ។ ការបញ្ជូនទៅជំនុំជម្រះនេះទៀតសោត ត្រូវតែបញ្ជូនទៅកាន់ប្រធានតុលាការ ដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។ ជាមួយគ្នានោះដែរ ចៅក្រមស៊ើបសួរត្រូវចេញលិខិតជូនដំណឹងពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដល់ព្រះរាជអាជ្ញា ដើមបណ្តឹង ជនត្រូវចោទ ឬមេធាវី ដើម្បីឲ្យបានដឹងពីដំណើរការនៃនីតិវិធីស៊ើបសួរ ថាសំណុំរឿងត្រូវបានចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះហើយ។[138] ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរអាចរក្សាជនជាប់ចោទឲ្យនៅជាប់ឃុំបណ្តោះអាសន្ន រហូតដល់ពេលជនជាប់ចោទចូលបង្ហាញខ្លួននៅមុខតុលាការជំនុំជម្រះផងដែរ។ ជាមួយគ្នានេះដែរ នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[139] ហើយនៅពេលដែលចេញដីកា ចៅក្រមស៊ើបសួរត្រូវចេញដោយ មានសំអាងហេតុ ព្រមទាំងត្រូវជូនដំណឹងក្នុងរយៈពេលខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី។[140] ក្នុងការចេញដីកាដំណោះស្រាយ ចៅក្រមមានឯករាជ្យភាពពេញលេញក្នុងការចេញដីកា ដោយមិនចាំបាច់ត្រូវជាប់កាតព្វកិច្ចគោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាឡើយ ។[141]

**២.១.៣. អានុភាពនៃបញ្ជូនទៅជំនុំជម្រះ**

ដីកាបញ្ជូនទៅជំនុំជម្រះមានអានុភាពបង្ហាញឲ្យឃើញថា ជនត្រូវចោទពិតជា បានប្រព្រឹត្តនូវបទល្មើស ដូចការចោទប្រកាន់របស់ព្រះរាជអាជ្ញាពិតមែន ដោយយោងតាមការស្រាវជ្រាវរបស់ខ្លួនក្នុងដំណាក់កាលស៊ើបសួរកន្លងមក។ ក្រោយពេលចៅក្រមស៊ើបសួរសម្រេចចេញដីកានេះរួចមក ជនត្រូវចោទនឹងក្លាយទៅជាជនជាប់ចោទ។ អ្វីដែលសំខាន់នោះ ដីកាបញ្ជូនទៅជំនុំជម្រះ មានអានុភាពបញ្ជូនជនជាប់ចោទទៅកាន់តុលាការជំនុំជម្រះ ដើម្បីធ្វើការផ្តន្ទាទោសចំពោះអំពើដែលជននោះបានប្រព្រឹត្ត។ ជាងនេះទៅទៀត ការបញ្ជូនទៅជំនុំជម្រះធ្វើឡើងនៅពេលចៅក្រមស៊ើបសួរបិទបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន ដោយបានស្វែងរកភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់បង្ហាញថា ជនត្រូវចោទបានប្រព្រឹត្តនូវបទល្មើសដូចការចោទប្រកាន់ ដើម្បីបញ្ជូនជននោះទៅជំនុំជម្រះ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរ ត្រូវចេញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដើម្បីបញ្ជូនជនជាប់ចោទទៅកាន់តុលាការជំនុំជម្រះពីបទឧក្រិដ្ឋ ឬ មជ្ឈិម ដោយក្នុងដីកាចៅក្រមស៊ើបសួរត្រូវរៀបរាប់អំពីអំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។[142] ប៉ុន្តែ ប្រសិនបើជននោះត្រូវបានធ្វើការចោទប្រកាន់ ក្នុងករណីនេះចៅក្រមស៊ើបសួរអាចរក្សាជនត្រូវចោទ នោះឲ្យជាប់ឃុំ

[138] ទម្រង់នៃលិខិតជូនដំណឹងពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ មានកំណត់ក្នុង ឧបសម្ព័ន្ធទី១៥។

[139] មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[140] id

[141] id

[142] id

បណ្ដោះអាសន្នរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ។ គួរបញ្ជាក់ផងដែរថា ក្នុងករណីដែលត្រូវបានបន្តឃុំខ្លួននេះ ចៅក្រមស៊ើបសួរលើកយកមូលហេតុផ្អែកតាម មាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

មួយវិញទៀត ចំពោះការសម្រេចនេះនឹងត្រូវលែងមានអានុភាពនៅរយៈពេល ៤ខែ ប្រសិនបើជនត្រូវចោទមិនបានបង្ហាញខ្លួននៅមុខតុលាការជំនុំជម្រះក្នុងរយៈពេល ៤ខែទេនោះ នាំឲ្យជននោះត្រូវបានដោះលែងឲ្យនៅក្រៅឃុំដោយឯកឯងផងដែរ។[143] នៅក្រោយពេលចេញដីកាដំណោះស្រាយស្ដីពីការបញ្ជូនរឿងទៅជំនុំជម្រះ សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរនឹងត្រូវបានបញ្ចប់ ហើយសមត្ថកិច្ចបន្ទាប់ គឺស្ថិតនៅក្រោមការដឹកនាំរបស់ចៅក្រមជំនុំជម្រះ ដែលគាត់ជាអ្នកដឹកនាំនីតិវិធីក្នុងដំណាក់កាលជំនុំជម្រះ។

### ២.២. ការលើកលែងការចោទប្រកាន់

នៅក្នុងការសម្រេចលើកលែងការចោទប្រកាន់ក្នុងដំណាក់កាលស៊ើបសួរ ចៅក្រមស៊ើបសួរមិនជាប់កាតព្វកិច្ចតាមការចោទប្រកាន់របស់ព្រះរាជអាជ្ញានោះទេ។ ប្រសិនបើចៅក្រមស៊ើបសួរមិនសម្រេចធ្វើការបញ្ជូនទៅជំនុំជម្រះទេនោះ ចៅក្រមស៊ើបសួរអាចធ្វើការលើកលែងការចោទប្រកាន់បានផងដែរ។ ក្រៅពីការបញ្ជូនជំនុំជម្រះ ចៅក្រមស៊ើបសួរក៏អាចចេញដីកាដំណោះស្រាយ ដែលជាការលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទបាន ប្រសិនបើមានមូលហេតុ ដែលនឹងធ្វើការលើកឡើងនៅក្នុងចំណុចខាងក្រោម។

#### ២.២.១. មូលហេតុនៃការលើកលែងការចោទប្រកាន់

ការលើកលែងការចោទប្រកាន់ ធ្វើឡើងតាមរយៈដីកាលើកលែងការចោទប្រកាន់ក្នុងករណីដែល៖

- អំពើរបស់ជនត្រូវចោទបានប្រព្រឹត្តមិនមែនជាបទល្មើសព្រហ្មទណ្ឌ(ឧក្រិដ្ឋ,បទមជ្ឈិម,បទលហុ)
- មិនមានភស្តុតាងគ្រប់គ្រាន់ធ្វើការដាក់បន្ទុកទៅលើជនត្រូវចោទ
- ជនដែលប្រព្រឹត្តអំពើល្មើសនោះនៅតែគេមិនស្គាល់ ឬ ជនត្រូវចោទទទួលមរណភាព។

#### ២.២.២. នីតិវិធីនៃការចេញដីកាសម្រេចលើកលែងការចោទប្រកាន់

ក្រោយពីការបង្វិលដីកាសន្និដ្ឋានស្ថាពរពីព្រះរាជអាជ្ញាមកកាន់ចៅក្រមស៊ើបសួររួចមក ចៅក្រមស៊ើបសួរមិនត្រូវបានជាប់កាតព្វកិច្ចតាមអ្វី ដែលមានកំណត់ក្នុងដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញានោះទេដែលមានន័យថា ការសម្រេចបញ្ជូនទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់ គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមស៊ើបសួរ ផ្អែកទៅលើលទ្ធផលដែលកើតចេញពីកិច្ចស៊ើបសួររបស់គាត់។[144] ក្រៅពីចៅក្រមស៊ើបសួរធ្វើការបញ្ជូនរឿងទៅជំនុំជម្រះ គឺគាត់អាចធ្វើការលើកលែងការចោទប្រកាន់ផងដែរ តាមរយៈដីកាសម្រចលើកលែង

[143] មាត្រា២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[144] មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

ការចោទប្រកាន់។[145] ក្នុងន័យនេះ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចធំធេង ដោយគាត់អាចមានសិទ្ធិក្នុងធ្វើការលើកលែងការចោទប្រកាន់ ប្រសិនបើមានមូលហេតុដូចដែលបានរៀបរាប់ខាងលើត្រូវបានបំពេញ។

### ២.២.៣. អានុភាពនៃដីកាសម្រេចលើកលែងការចោទប្រកាន់

តើដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរមានអានុភាពដូចម្តេចខ្លះ? ដីកាដំណោះស្រាយជាមូលហេតុនាំឲ្យការឃុំខ្លួន និងការដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការត្រូវបានបញ្ចប់។[146] ក្នុងន័យនេះ គឺចង់សំដៅថា ប្រសិនបើបុគ្គលណាម្នាក់ត្រូវបានជាប់ឃុំខ្លួន គឺគេអាចត្រូវបានដោះលែងឲ្យមានសេរីភាពវិញ ដោយជននោះលែងត្រូវបានឃុំខ្លួនតទៅទៀតហើយ។ ចំណែកឯការត្រួតពិនិត្យតាមផ្លូវតុលាការវិញ ក៏ត្រូវបានបញ្ចប់ផងដែរ។ មានន័យថា ជនត្រូវចោទដែលត្រូវបានតុលាការបានកំណត់ ឬ កម្រិតនូវកន្លែងមួយចំនួនដែលមិនតម្រូវឲ្យធ្វើដំណើរនៅទីកន្លែងជាក់លាក់ណាមួយ ដែលបានកំណត់ក្នុងដីកាបង្គាប់ឲ្យដាក់នៅក្រោមត្រួតពិនិត្យតាមផ្លូវតុលាការ គេនឹងមានសេរីភាពអាចដើរហើរធម្មតាវិញ។ ម៉្យាងវិញទៀត ការស៊ើបសួរមិននាំឲ្យមានអាជ្ញាអស់ជំនុំនោះទេ ដោយសំណុំអាចបើកឡើងវិញសារជាថ្មីម្តងទៀតតាមគំនិតរបស់ព្រះរាជអាជ្ញា ប្រសិនបើគាត់យល់ឃើញថា មានតម្រុយពិរុទ្ធភាពនៅឡើយ ឬ មួយប្រសិនបើមានលេចឡើងនូវបន្ទុកថ្មី។ ពិសេសជាងនេះទៅទៀត បញ្ញត្តិនៃមាត្រា១១៩ (អាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឲ្យប្រគល់វត្ថុជូនម្ចាស់ដើមវិញ) ក៏ត្រូវបានយកមកអនុវត្តផងដែរ គឺត្រូវបានប្រគល់សងទៅកាន់ម្ចាស់ដើមវិញ ប្រសិនបើវត្ថុទាំងនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ។ ម៉្យាងវិញទៀត ប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ គ្មានការជំទាស់អ្វីប្រាកដ។ ប៉ុន្តែ ជាករណីអញ្ញត្រកម្ម បើវត្ថុទាំងនោះមានការបង្កគ្រោះថ្នាក់ចំពោះមនុស្ស ឬ ចំពោះទ្រព្យសម្បត្តិ ដូចជាអាវុធ ឬ ជាតិផ្ទុះព្រមទាំងវត្ថុដែលត្រូវបានកាន់កាប់ដោយខុសច្បាប់ មិនអាចត្រូវបានប្រគល់ឲ្យម្ចាស់ដើមវិញបាននោះទេ។ ពោល គឺវត្ថុទាំងនោះត្រូវបានទុកជាសម្បត្តិរដ្ឋ ឬ ត្រូវបំផ្លាញចោល។[147] ចំណែកឯ ចំពោះអនីតិជនវិញ ដីកាដំណោះស្រាយដែលលើកលែងការចោទប្រកាន់មានអានុភាពដោះលែងអនីតិជនដែលជាប់ឃុំខ្លួន។ ចៅក្រមត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់កំណត់។[148] ក្នុងករណីអនីតិជនត្រូវការការពារ ឬ ថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។[149]

[145] ទម្រង់នៃដីកាសម្រេចលើកលែងការចោទប្រកាន់ មានកំណត់ក្នុង ឧបសម្ព័ន្ធទី១៦។

[146] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[147] មាត្រា១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ,លេខ នស/រកម/០៧០៨/០២៤,១០ សីហា ២០០៧។

[148] មាត្រា ៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩,១៤ កក្កដា ២០១៦។

[149] id

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ចៅក្រមស៊ើបសួរ នៃមន្ទីរស៊ើបសួរដែលមានទីតាំងស្ថិតនៅសាលាដំបូងរាជធានី-ខេត្ត ដែលដើរតួនាទីយ៉ាងសំខាន់ក្នុងការបំពេញកិច្ចស៊ើបសួរ និងដឹកនាំកិច្ចស៊ើបសួររបស់ខ្លួនក្នុងដំណាក់កាលស៊ើបសួរ។ ពោល គឺក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់សិទ្ធិអំណាចដល់ចៅក្រមស៊ើបសួរក្នុងការធ្វើការស៊ើបសួរ ដើម្បីស្វែងរកការពិត ក្នុងការដាក់បន្ទុក ឬ ដោះបន្ទុកនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ជាក់ស្តែង ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរ អាចបើកកិច្ចស៊ើបសួររបស់ខ្លួនបាន ដោយមូលហេតុចំនួនពីរ គឺនៅពេលមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា និងការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ លើសពីនេះទៅទៀត បន្ទាប់ពីធ្វើការបើកការស៊ើបសួរតាមរយៈមូលហេតុខាងលើនេះហើយ ចៅក្រមស៊ើបសួរត្រូវការធ្វើស្រាវជ្រាវស្វែងរកការពិត ដើម្បីធ្វើការចោទប្រកាន់លើជនត្រូវចោទ ឬ លើកលែងការចោទប្រកាន់លើជនជាប់ចោទ។ ទាក់ទងនឹងការបំពេញកិច្ចស៊ើបសួររបស់ខ្លួនចៅក្រមស៊ើបសួរ ត្រូវបំពេញការស៊ើបសួររបស់ខ្លួន ដោយធ្វើការស្រាវជ្រាវទាក់ទងនឹងបុគ្គល និងការស្រាវជ្រាវទាក់ទងនឹងវត្ថុ។ ជាក់ស្តែង នៅក្នុងការស្រាវជ្រាវទាក់ទងនឹងមនុស្ស ចៅក្រមស៊ើបសួរត្រូវធ្វើ ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី និងការសួរតទល់។ លើសពីនេះទៅទៀត ចំពោះការស្រាវជ្រាវទាក់ទងនឹងវត្ថុ ចៅក្រមស៊ើបសួរត្រូវធ្វើឡើងតាមរយៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង ការធ្វើកោសលវិច័យ និងការស្តាប់ចម្លើយទូរស័ព្ទ។ ប្រសើរជាងនេះទៅទៀត ក្នុងករណីចៅក្រមស៊ើបសួរពុំអាចបំពេញកិច្ចស៊ើបសួររបស់ខ្លួនដោយខ្លួនឯង ដោយសារជួបប្រទះនូវឧបសគ្គណាមួយ ក្រមនីតិវិធីព្រហ្មទណ្ឌក៏បានអនុញ្ញាតឲ្យចៅក្រមស៊ើបសួរធ្វើការផ្ទេរភារកិច្ចស៊ើបសួររបស់ខ្លួន ទៅឲ្យចៅក្រមស៊ើបសួរនៅតុលាការជាមួយគ្នា ឬ នៅតុលាការផ្សេង និងមន្ត្រីនគរបាលយុត្តិធម៌បាន តាមរយៈដីកាចាត់ឲ្យការស៊ើបសួរជំនួស។ ចំពោះការបំពេញកិច្ចស្រាវជ្រាវក្នុងដំណាក់កាលស៊ើបសួរ ត្រូវធ្វើការស៊ើបសួរដោយហ្មត់ចត់ និងប្រកបដោយការសម្ងាត់ ព្រោះថាចៅក្រមស៊ើបសួរក្នុងដំណាក់កាលនេះ គឺតំណាងឲ្យស្ថាប័នតុលាការដែលមានតួនាទីសំខាន់ក្នុងការស្វែងរកយុត្តិធម៌ក្នុងរឿងក្តីឲ្យភាគី។ ដូច្នេះ ដើម្បីធ្វើការដាក់បន្ទុក ឬដោះបន្ទុកឲ្យបានត្រឹមត្រូវ ចៅក្រមស៊ើបសួរត្រូវបំពេញកិច្ចរបស់ខ្លួនប្រកបដោយស្មារតីប្រុងប្រយ័ត្ន និងច្បាស់លាស់។ ជាមួយគ្នានោះដែរ ក្នុងការស៊ើបសួររបស់ខ្លួន ដើម្បីធានាឲ្យដំណើរនៃនីតិវិធីក្នុងដំណាក់កាលស៊ើបសួរប្រព្រឹត្តទៅរលូនទៅមុខបាន ចៅក្រមស៊ើបសួរត្រូវបានទទួលនូវសិទ្ធិអំណាចមួយចំនួន តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌ។ ដោយសិទ្ធិអំណាចទាំងនោះ គឺសំដៅលើការប្រើនូវវិធាននិរន្តរាយ និងការដាក់ឲ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។ ជាក់ស្តែង ការប្រើវិធានការនិរន្តរាយ សំដៅលើសិទ្ធិអំណាចក្នុងការចេញដីកាចំនួនបួន ដែលមានដូចជា ដីកាបង្គាប់ឲ្យចូលខ្លួន ដីកាបង្គាប់ឲ្យនាំខ្លួន ដីកាបង្គាប់ឲ្យចាប់ខ្លួន និងដីកា

សម្រេចឃុំខ្លួនបណ្តោះអាសន្ន ភ្ជាប់ជាមួយនឹងដីកាបង្គាប់ឲ្យឃុំខ្លួនផងដែរ។ តាមរយៈសិទ្ធិអំណាចទាំងនេះ គឺផ្តល់នូវសិទ្ធិអំណាចមួយ ដែលធ្វើឲ្យចៅក្រមស៊ើបសួរអាចប្រើវាដើម្បីដឹកនាំនីតិវិធីខ្លួនបានរលូន និងទទួលលទ្ធផលល្អ។ ប៉ុន្តែ ទោះបីជាចៅក្រមស៊ើបសួរទទួលបាននូវសិទ្ធិអំណាចក្នុងការចេញដីកាខាងលើយ៉ាងណាក្តី ក៏ចៅក្រមស៊ើបសួរត្រូវប្រើនូវសិទ្ធិអំណាចនេះផ្អែកទៅលើគោលការណ៍អនាគតិ[150] និងការវិនិច្ឆ័យត្រឹមត្រូវ ព្រោះថាការប្រើនូវវិធានការនិរន្តរាយនេះ អាចនឹងប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់បុគ្គលដែលជាជនត្រូវចោទ ឬបុគ្គលដែលមានតម្រុយពិរុទ្ធភាព ដោយហេតុថា ពួកគេនៅតែជាបុគ្គលគ្មានជាប់ទោសនៅឡើយ។ មានន័យថា ជនទាំងនោះពុំទាន់ត្រូវបានតុលាការប្រកាសថាមានទោសនៅឡើយទេ។ ដូច្នេះ យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិថា ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។[151]

ពិសេសជាងនេះទៅទៀត បន្ទាប់ពីធ្វើការស្រាវជ្រាវចប់សព្វគ្រប់ហើយ ចៅក្រមស៊ើបសួរត្រូវធ្វើការបិទការស៊ើបសួរ និងចេញដីកាដំណោះស្រាយ ដោយដីកាដំណោះស្រាយនោះ អាចជាការចេញដីកាសម្រេចលើកលែងការចោទប្រកាន់ ឬ ដីកាសម្រេចបញ្ជូនទៅជំនុំជម្រះ។ ក្នុងការចេញដីកានេះដែរ ចៅក្រមស៊ើបសួរត្រូវចេញដោយផ្អែកលើសំអាងហេតុ សំអាងច្បាប់ត្រឹមត្រូវ។ មានន័យថា នៅពេលចៅក្រមស៊ើបសួរធ្វើការសម្រេចលើកលែងចោទប្រកាន់លើជនត្រូវចោទក្តី ឬ សម្រេចបញ្ជូនជនត្រូវចោទទៅជំនុំជម្រះក្តី គឺត្រូវសម្រេចប្រកបដោយអនាគតិទាំងប្រាំ ព្រមទាំងផ្អែកលើមូលដ្ឋានផ្លូវច្បាប់ដ៏ត្រឹមត្រូវ និងច្បាស់លាស់ ដើម្បីផ្តល់នូវភាពយុត្តិធម៌ដល់ប្រជាជន និងសង្គមជាតិទាំងមូល ក្នុងនាមខ្លួនជាបុគ្គលដែលបំពេញមុខងារក្នុងស្ថាប័នតុលាការ ដែលជាស្ថាប័នឯករាជ្យ។

សរុបសេចក្តីមក ដំណាក់កាលចៅក្រមស៊ើបសួរដែលមានចៅក្រមស៊ើបសួរជាអ្នកដឹកនាំនេះ គឺមានអត្ថប្រយោជន៍យ៉ាងខ្លាំងនៅក្នុងវិស័យយុត្តិធម៌ ដោយបានធានាដល់ប្រជាពលរដ្ឋ និងសង្គមទាំងមូលឲ្យទទួលបាននូវសុខសន្តិភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។ ហេតុនេះហើយ ដើម្បីចូលរួមក្នុងការរីកចម្រើនទៅលើវិស័យយុត្តិធម៌នេះ គប្បីចូលរួមគោរពច្បាប់ ដើម្បីឲ្យសង្គមទាំងមូលមានការអភិវឌ្ឍន៍។

[150] ប្រការ៧ នៃក្រមសីលធម៌ចៅក្រម,២២ កុម្ភៈ ២០០៧។

[151] មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

# អនុសាសន៍

# អនុសាសន៍

ដោយបានឆ្លងកាត់ការស្រាវជ្រាវអំពីប្រធានបទស្តីពី **"ចៅក្រមស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ"** រួចមក យើងខ្ញុំសង្កេតឃើញនូវភាពខ្វះខាតមួយចំនួន ដែលកើតមាននៅក្នុងការបំពេញកិច្ចស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរក្នុងដំណាក់កាលស៊ើបសួរ។ ដោយហេតុនេះហើយជាដំបូង យើងខ្ញុំសូមធ្វើការសំណូមពរប្រជាពលរដ្ឋទាំងអស់ឲ្យចូលរួមសហការជាមួយនឹងសមត្ថកិច្ច និងស្ថាប័នតុលាការនៅពេលមានបទល្មើស ឬ រឿងក្តីកើតឡើង ដើម្បីធ្វើឲ្យដំណើរនៃនីតិវិធីមានភាពរលូនទៅមុខ។ ជាមួយគ្នានោះដែរ ការសហការរវាងប្រជាពលរដ្ឋ និងសមត្ថកិច្ច គឺជាគោលបំណងមួយដែលច្បាប់ចង់បានព្រោះថានៅក្នុងការស្វែងរក ក៏ដូចជាស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរទាក់ទងនឹងបុគ្គលក្តី ឬ វត្ថុក្តី គឺសុទ្ធតែទាមទារឲ្យមាននូវការសហការគ្នាជាមួយប្រជាជននៅកន្លែងកើតហេតុ ក៏ដូចជាអ្នកដែលបានដឹងហេតុការណ៍ តម្រុយពិរុទ្ធភាព ឬ ភស្តុតាង ដើម្បីឲ្យសមត្ថកិច្ចធ្វើការចាប់ និងស្រាវជ្រាវបន្ទាប់។ ប្រសើរជាងនេះទៅទៀត ចំពោះស្ថាប័នតុលាការវិញ ពោល គឺសាលាដំបូងរាជធានី-ខេត្ត សូមធ្វើការរៀបចំនូវមន្ទីរស៊ើបសួរ ឲ្យបានស្របទៅតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលក្នុងនោះត្រូវមានចៅក្រមស៊ើបសួរយ៉ាងតិចបំផុតចំនួន ៣រូប ព្រមទាំងមានក្រឡាបញ្ជីអមជាមួយផងដែរ។ ពិសេសជាងនេះទៅទៀត ក្នុងការបំពេញកិច្ចស៊ើបសួររបស់ខ្លួន ចៅក្រមស៊ើបសួរត្រូវគោរពនូវគោលការណ៍អនាគតិឲ្យបានត្រឹមត្រូវ។ ទន្ទឹមនឹងនេះដែរ ចៅក្រមស៊ើបសួរ ឬ មន្ត្រីនគរបាលទាំងអស់ដែលរួមចំណែកបំពេញតួនាទីក្នុងការស៊ើបសួរ ត្រូវធ្វើបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយភាពយុត្តិធម៌ វិជ្ជាជីវៈត្រឹមត្រូវ និងច្បាស់លាស់។ មួយវិញទៀត ចៅក្រមស៊ើបសួរ សូមគោរពនូវតួនាទីរបស់ខ្លួនឲ្យបានហ្មត់ចត់ ដោយមិនត្រូវធ្វើការផ្ទេរសមត្ថកិច្ចឲ្យទៅអ្នកដទៃឲ្យបំពេញកិច្ចស៊ើបសួរជំនួសខ្លួន ដូចជា ការសួរចម្លើយជនត្រូវចោទ ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ការស្តាប់ចម្លើយសាក្សី និងកិច្ចផ្សេងទៀត ដែលច្បាប់ពុំបានអនុញ្ញាតនោះទេ។ ម៉្យាងវិញទៀត ផ្អែកតាមគោលការណ៍សេរីភាពបុគ្គល យើងខ្ញុំសូមសំណូមពរឲ្យមាននូវការគោរពសិទ្ធិសេរីភាពរបស់បុគ្គលគ្រប់រូប ទោះបីជាគេជាជនត្រូវចោទ ឬ បុគ្គលមានតម្រុយពិរុទ្ធភាពក៏ដោយ ព្រោះថាបុគ្គលគ្រប់រូបសុទ្ធតែមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។ ដូច្នេះ រាល់ការប្រើនូវវិធាននិរន្តរាយតាមរយៈការចេញដីកាមួយចំនួនត្រូវធ្វើការវិនិច្ឆ័យឲ្យបានត្រឹមត្រូវ ដើម្បីជៀសវាងការបំពាននូវសិទ្ធិសេរីភាពបុគ្គល។ ដោយឡែកចំពោះអ្នកជំនាញ ដែលមានតួនាទីក្នុងការស្វែងរកភស្តុតាង ឬ ធ្វើការធ្វើកោសលវិច័យ រួមជាមួយនឹងឧបករណ៍ក្នុងការប្រើប្រាស់ដើម្បីដំណើរការការងារនេះ គឺនូវមានកង្វះខាតនៅឡើយ។ អាស្រ័យហេតុនេះ សូមសំណូមពរឲ្យមានការបណ្តុះបណ្តាលបន្ថែមនូវអ្នកជំនាញ និងអ្នកបច្ចេកទេស ជាមួយនឹងចំណេះដឹង និងជំនាញត្រឹមត្រូវ។ ចំណែកឯ ឧបករណ៍ក្នុងការបំពេញកិច្ចការរបស់អ្នកជំនាញ សូមសំណូមពរបន្ថែម ដើម្បីបង្កើននូវប្រសិទ្ធភាពនៃការស្រាវជ្រាវឲ្យបានប្រសើរ និងទាន់ពេលវេលា។

# ឯកសារយោង

# ឯកសារយោង


## ១.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។
- បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសំរាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល, ១០ កញ្ញា ១៩៩២។
- ក្រមព្រហ្មទណ្ឌ, លេខ រស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ឆ្នាំ២០០៩។
- ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧។
- ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី, នស/រកម/០៨៩៥/០៦, ២២ សីហា ១៩៩៥។
- ក្រមសីលធម៌ចៅក្រម, ២២ កុម្ភៈ ២០០៧។
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ១៤ កក្កដា ២០១៦។
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, ១០ ធ្នូ ១៩៤៨។
- កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ២៣ មីនា ឆ្នាំ១៩៧៦។

## ២.សៀវភៅ និងស្នាដៃនិពន្ធ

- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, នីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- ទីស្តីការគណៈរដ្ឋមន្ត្រី គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់, ឆ្នាំ២០១១,សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ-អង់គ្លេស-បារាំង ផ្នែកព្រហ្មទណ្ឌ។

## ៣.ប្រភពផ្សេងៗ

- ឯកឧត្តម កើត រិទ្ធ. ២០០៨. បទសម្ភាសដោយ ពិធីការនី នៃទូរទស្សន៍ជាតិកម្ពុជា. ០៨ មករា។
- សាលាត្រាជូ. វាក្យស័ព្ទច្បាប់. ដកស្រង់ចេញពី https://salatraju.com/lexique/1551។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

| | |
|---|---|
| ឧបសម្ព័ន្ធទី១ | ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ |
| ឧបសម្ព័ន្ធទី២ | ទម្រង់នៃដីកាកោះ(ជនត្រូវចោទ) |
| ឧបសម្ព័ន្ធទី៣ | ទម្រង់នៃកំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ |
| ឧបសម្ព័ន្ធទី៤ | ទម្រង់នៃដីកាកោះ(ដើមបណ្ដឹងរដ្ឋប្បវេណី) |
| ឧបសម្ព័ន្ធទី៥ | ទម្រង់នៃកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី |
| ឧបសម្ព័ន្ធទី៦ | ទម្រង់នៃដីកាកោះហៅសាក្សី |
| ឧបសម្ព័ន្ធទី៧ | ទម្រង់នៃកំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី |
| ឧបសម្ព័ន្ធទី៨ | ទម្រង់នៃកំណត់ហេតុសួរតទល់ |
| ឧបសម្ព័ន្ធទី៩ | ទម្រង់នៃដីកាចាត់តាំងអ្នកជំនាញ |
| ឧបសម្ព័ន្ធទី១០ | ទម្រង់នៃដីកាបង្គាប់ឲ្យចូលខ្លួន |
| ឧបសម្ព័ន្ធទី១១ | ទម្រង់នៃដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន / ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន |
| ឧបសម្ព័ន្ធទី១២ | ទម្រង់នៃដីកាបង្គាប់ឲ្យដាក់នៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ |
| ឧបសម្ព័ន្ធទី១៣ | ទម្រង់នៃលិខិតជូនដំណឹងស្ដីពីការបិទបញ្ចប់ការស៊ើបសួរ |
| ឧបសម្ព័ន្ធទី១៤ | ទម្រង់នៃដីកាសន្និដ្ឋានស្ថាពរ |
| ឧបសម្ព័ន្ធទី១៥ | ទម្រង់នៃលិខិតជូនដំណឹងពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ |
| ឧបសម្ព័ន្ធទី១៦ | ទម្រង់នៃដីកាសម្រេចលើកលែងការចោទប្រកាន់ |
| ឧបសម្ព័ន្ធទី១៧ | ទម្រង់នៃកំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង |
| ឧបសម្ព័ន្ធទី១៨ | ទម្រង់នៃពាក្យបណ្ដឹង |
| ឧបសម្ព័ន្ធទី១៩ | ទម្រង់នៃលិខិតអញ្ជើញ |
| ឧបសម្ព័ន្ធទី២០ | ទម្រង់នៃពាក្យសុំចូលជាមេធាវីការពារក្ដី |
| ឧបសម្ព័ន្ធទី២១ | ទម្រង់នៃដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យ |
| ឧបសម្ព័ន្ធទី២២ | ទម្រង់នៃពាក្យសុំពឹងពាក់មេធាវី |
| ឧបសម្ព័ន្ធទី២៣ | ទម្រង់នៃកំណត់ហេតុស្ដីពីការសួរដេញដោលចំពោះមុខ |
| ឧបសម្ព័ន្ធទី២៤ | ទម្រង់នៃដីកាបញ្ជូន |
| ឧបសម្ព័ន្ធទី២៥ | ទម្រង់នៃបញ្ជីរាយនាមជនជាប់ទាក់ទិន |
| ឧបសម្ព័ន្ធទី២៦ | ទម្រង់នៃពាក្យស្នើសុំជូនពិនិត្យភស្ដុតាង |
| ឧបសម្ព័ន្ធទី២៧ | ទម្រង់នៃពាក្យសុំជូនពិនិត្យភស្ដុតាង និងបញ្ចូលសាក្សី |
| ឧបសម្ព័ន្ធទី២៨ | ទម្រង់នៃពាក្យស្នើសុំធ្វើកោសលវិច័យ |

ឧបសម្ព័ន្ធទី២៩ ទម្រង់នៃពាក្យសុំធ្វើកោសលវិច័យបន្ថែម

ឧបសម្ព័ន្ធទី៣០ ទម្រង់នៃពាក្យសុំបញ្ឈប់ការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ឧបសម្ព័ន្ធទី៣១ ទម្រង់នៃពាក្យស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ។

1

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឧបសម្ព័ន្ធទី១

**អយ្យការអម**

**សាលាដំបូងរាជធានីភ្នំពេញ**

សំណុំរឿងព្រហ្មទណ្ឌលេខ

ចុះថ្ងៃទី ខែ ឆ្នាំ

លេខៈ ................... អ.យ.គ

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

**យើង** **ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ បានប្តឹងឈ្មោះ ភេទប្រុស អាយុ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ឆ្នាំ ពីបទ រំលោភលើទំនុកចិត្ត និងឆបោកប្រាក់។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្និដ្ឋានបានថា

១-នាម-គោត្តនាម ភេទប្រុស អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

២-នាម-គោត្តនាម ភេទស្រី អាយុ ឆ្នាំ មានអាស័យដ្ឋាននៅ ឃុំ ស្រុក ខេត្ត ។ (ក្រៅឃុំ)

**បានប្រព្រឹត្តអំពើដូចតទៅៈ** កាលពីអំឡុងឆ្នាំ ឈ្មោះ និង បាន ចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយ មានឈ្មោះ ជា ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែកឯឈ្មោះ និង ទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះឈ្មោះ និង ជាអ្នកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ។ បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ឈ្មោះ និង បាន ផ្ញើប្រាក់អោយទៅ តាមរយៈធនាគារ ដែលមានឈ្មោះ , ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ដោយផ្ទាល់សរុបចំនួន ដុល្លាអាមេរិក។ ក្រោយពីទទួលប្រាក់រួចហើយឈ្មោះ បាន ធ្វើការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញមកអោយឈ្មោះ ឡើយ។ ហើយពួកគេបានគេចវេស និងគេចខ្លួនរហូត ទើបឈ្មោះ សម្រេចចិត្តដាក់ពាក្យបណ្តឹងមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញដើម្បីចាត់ការតាមនីតិវិធី។

អំពើខាងលើជាបទល្មើស ៖ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញមាត្រា ៩៩ និងមាត្រា ១២៩ ក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ៖

-ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ។ (ក្រៅឃុំ)

-ឈ្មោះ ភេទស្រី អាយុ ឆ្នាំ។ (ក្រៅឃុំ)

ពីបទ ៖ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

☑ដាក់ឲ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន៖ លើឈ្មោះខាងលើ ដើម្បីបង្ការ ឬបញ្ចប់បទល្មើសកុំឲ្យកើតឡើងជាថ្មី និងធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី។

ថ្ងៃទី សុក្រ....០១រោច.ខែ....កត្តិក..ឆ្នាំច..សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ....[illegible]..... ខែ....វិច្ឆិកា.. ឆ្នាំ២០១៨

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី២

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាកោះ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: [illegible]

ចុះថ្ងៃទី [illegible]

យើង [illegible] ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

| | | |
|---|---|---|
| បានឃើញ | : | សំណុំរឿងព្រហ្មទណ្ឌលេខ [illegible] ចុះថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible] |
| អញ្ជើញ | : | ឈ្មោះ [illegible] ភេទប្រុស អាយុ [illegible] ឆ្នាំ ជនជាតិ [illegible] ទីលំនៅបច្ចុប្បន្ន [illegible] ជាន់ទី [illegible] ផ្លូវ [illegible] សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានី [illegible] |
| ឲ្យចូលទៅកាន់ | : | **សាលាដំបូងរាជធានីភ្នំពេញ បន្ទប់ "ក១" ជាន់ទី៣** |
| កាលបរិច្ឆេទ | : | **ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០** |
| វេលាម៉ោង | : | **០៩:០០ នាទីព្រឹក** |
| ដើម្បី | : | សាកសួរបំភ្លឺ |
| ពីដំណើររឿង | : | **ប្រឆាំងនឹងអ្នករាជការសាធារណៈមានស្ថានទម្ងន់ទោស និងធ្វើឲ្យបាត់ជំនឿលើសេចក្ដីសម្រេចរបស់តុលាការ** ប្រព្រឹត្តនៅទីតាំង [illegible] ស្ថិតនៅលេខ [illegible] ផ្លូវ [illegible] សង្កាត់ [illegible] ខណ្ឌ [illegible] រាជធានី [illegible] កាលពីថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible] បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៥០៤ និងមាត្រា៥២៣ នៃក្រមព្រហ្មទណ្ឌ។ |

សាមីខ្លួនត្រូវអញ្ជើញតាមលិខិតអញ្ជើញនេះឲ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន។

ថ្ងៃសុក្រ ៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៣

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ:
ចុះថ្ងៃទី
សំណុំរឿងស៊ើបសួរ
លេខ:
ចុះថ្ងៃទី

# កំណត់ហេតុស្តាប់ចម្លើយជនត្រូវចោទ

(មាត្រា ១៤៥ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំបបួន ខែមីនា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោងប្រាំបី និងសាមសិបនាទី ព្រឹក ។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បានមកបង្ហាញខ្លួនក្នុងនាមជនត្រូវចោទនៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានសញ្ញាណដូចខាងក្រោម៖

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ឃុំ ស្រុក ខេត្ត អាសយដ្ឋានបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្ត ឪពុកឈ្មោះ ម្តាយឈ្មោះ ប្រពន្ធឈ្មោះ មានកូន នាក់ ជានីតិជន ប្រវត្តិនៃការផ្តន្ទាទោសដោយតុលាការ គ្មាន ។

☐ជននេះបានប្រកាសប្រាប់ថា ខ្លួនមានអំណាចមេបាលើក្មេងអាយុក្រោម ១០ឆ្នាំ ដែលស្ថិតនៅលំនៅបច្ចុប្បន្ន។

ជននេះ៖ ☑ចេះនិយាយ☑ ចេះអាន☑ចេះសរសេរអក្សរខ្មែរ

ជននេះ៖☐ មិនចេះនិយាយ ☐មិនចេះអាន ☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងរ៉ាវដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ ។

ជនត្រូវចោទអមដោយលោកមេធាវី ។

យើងបានសួរចម្លើយឈ្មោះនេះ ហើយឈ្មោះនេះបានឆ្លើយប្រាប់យើងដូចខាងក្រោមថា៖

**សួរ-ឆ្លើយ៖** ខ្ញុំបាទជា

ដែលបានបង្កើតឡើងប្រហែលជាឆ្នាំ ដែលមាន ភាគហ៊ុនគឺមានឈ្មោះ ,ឈ្មោះ និងឈ្មោះ ។នៅឆ្នាំ ក្រុមហ៊ុនរបស់ខ្ញុំបាទនៅសល់តែ ភាគហ៊ុនទេ គឺរូបខ្ញុំបាទ និងកូនប្រុសរបស់ខ្ញុំបាទឈ្មោះ រឺឯឈ្មោះ ជាកូនបង្កើតរបស់ខ្ញុំបាទនិងប្រពន្ធឈ្មោះ ពុំមានតួនាទីអ្វីនៅក្នុងក្រុមហ៊ុន នេះទេ គឺគាត់មានប្រពន្ធហើយបែកពីខ្ញុំបាទទៅរកស៊ីផ្សេងទៀតគឺគាត់មានមុខ

របរដើរទិញដើមកៅស៊ូចាស់ៗដឹកយកទៅលក់ប្រទេសវៀតណាម ពុំមានទាក់ទងនឹងក្រុមហ៊ុនរបស់ខ្ញុំបាទទេ ។

សួរ-ឆ្លើយៈ ក្រុមហ៊ុនរបស់ខ្ញុំបាទនេះជាសិប្បកម្មកែឆ្នៃដើមកៅស៊ូចាស់ៗដែលអស់ជ័រហើយ អារជ្រៀក ត្រាំថ្នាំ និងសម្ងួត ដើម្បីដឹកទៅក្រៅប្រទេស និងលក់ឲ្យសិប្បកម្មធ្វើសង្ហារឹមក្នុងប្រទេស។

សួរ-ឆ្លើយៈ កាលពីឆ្នាំ មានឈ្មោះ ជាជនជាតិ និងកូនរបស់ខ្ញុំបាទឈ្មោះ បានមកពឹងពាក់ឲ្យខ្ញុំឲ្យជួយទិញដើមកៅស៊ូរបស់ក្រុមហ៊ុន ចំនួន៥០ (ហាសិប)ហិកតា ដើម្បីកាប់កូនកៅស៊ូលក់ ក្រុមហ៊ុននេះក៏បានយល់ព្រមព្រោះជាមិត្តភក្តិរបស់ខ្ញុំបាទ ។

សួរ-ឆ្លើយៈ កូនរបស់ខ្ញុំបាទឈ្មោះ ក្រោយពីទិញបានឡូកៅស៊ូនេះហើយក៏បានកាប់លក់ ក៏មានឈ្មោះ ជាជនជាតិ ម្នាក់ទៀតចូលមករកស៊ីជាមួយកូនរបស់ខ្ញុំបាទក្នុងការកាប់កៅស៊ូចំនួន ហិកតា នេះដែរ ។ ក្រោយពីកាប់កូនកៅស៊ូនេះអស់កូនរបស់ខ្ញុំបាទប្រាប់ថាបានចំណេញចំនួន ដុល្លារអាមេរិក តែប្រាក់ចំណេញនេះពុំមានពាក់ពាន់និងក្រុមហ៊ុនរបស់ខ្ញុំបាទទេ គឺពួកគេចែកគ្នាខ្ញុំបាទមិនបានដឹងឡើយ ។

សួរ-ឆ្លើយៈ ចំពោះឈ្មោះ ជាជនជាតិ ខ្ញុំបាទមិនបានស្គាល់គាត់ទេ ខ្ញុំបាទគ្រាន់តែដឹងថា ឈ្មោះ បាននាំគាត់មករកស៊ីជាមួយកូនរបស់ខ្ញុំបាទឈ្មោះ ចំពោះការចូលហ៊ុនគ្នារបស់ពួកគេទាំងបីនាក់យ៉ាងណានោះខ្ញុំបាទមិនបានដឹងទេ ។

សួរ-ឆ្លើយៈ ចំពោះដើមកៅស៊ូរបស់ក្រុមហ៊ុនមេមត់ចំនួន ហិកតា ចែកចេញជា ឡូតិ៍ ក្នុងតម្លៃសរុប ដុល្លារអាមេរិក ខ្ញុំបាទបានទិញនៅចុងឆ្នាំ ដើម្បីកាប់នៅដើមឆ្នាំ តែក្រុមហ៊ុនរបស់ខ្ញុំបាទមិនទាន់បានកាប់ផង កូនរបស់ខ្ញុំបាទឈ្មោះ បានមកសុំចែកដើមកៅស៊ូចំនួន ហិកតានេះពីខ្ញុំបាទវិញ ខ្ញុំបាទក៏បានចែកឲ្យវាវិញក្នុងតម្លៃដើម ដោយតម្រូវឲ្យកក់ចំនួន ដុល្លារអាមេរិក ក្រោយពីព្រមព្រៀងគ្នាហើយ ក្នុងពេលនោះ ស្រាប់តែមានគេវេរលុយចូលមកក្នុងគណនីរបស់ខ្ញុំបាទចំនួន ដុល្លារអាមេរិក តែខ្ញុំបាទមិនដឹងថាឈ្មោះ ណាមួយវេរមកខ្ញុំដើម្បីយកទៅកក់ដើមកៅស៊ូមេមត់ទេ ខ្ញុំបាទបានទៅដកលុយនោះមកហើយបានបង្ហាញទៅឈ្មោះ ថាលុយ ដុល្លារអាមេរិកនេះខ្ញុំទទួលបានហើយៗខ្ញុំយកទៅកក់ឲ្យដើមកៅស៊ូគេហើយ ។

សួរ-ឆ្លើយៈ ក្រោយពីបានកក់លុយហើយ ឈ្មោះ , ឈ្មោះ , ឈ្មោះ និងឈ្មោះ លី អាន់មីង ក៏បានចុះកាប់កៅស៊ូ ដោយមុននិងកាប់ឡូតិ៍មួយណាត្រូវបង់ប្រាក់ឲ្យក្រុមហ៊ុនសិនទើបកាប់ដើមកៅស៊ូបាន ។ ចំពោះការបង់តម្លៃឡូតិ៍ដែលត្រូវកាប់នោះគឺកូនរបស់ខ្ញុំឈ្មោះ ជាអ្នកយកទៅបង់ ចំណែករូបខ្ញុំបាទជាអ្នកធ្វើឯកសារទូទាត់ជាមួយក្រុមហ៊ុន ហើយបើពួកគេទៅកាប់ដើមកៅស៊ូនៅក្នុងឡូតិ៍មួយណាគឺត្រូវបង់លុយដល់នោះ ហើយខ្ញុំបាទទៅធ្វើឯកសារទូទាត់ប្រាក់ជាមួយក្រុមហ៊ុនដល់នោះដែរ ។

សួរ-ឆ្លើយ៖ ក្រោយពីពួកគេកាប់បានចំនួ ហិកតា ខាងក្រុមហ៊ុនបាន ជូនដំណឹងមកខ្ញុំបាទថា ការកាប់ដើមកៅស៊ូមិនបានបង់លុយឲ្យក្រុមហ៊ុន ទេ ។ ខ្ញុំបាទបានចុះទៅមើល ក៏បាត់មិនឃើ និង ឈ្មោះ ដែលនៅមើលការខុសត្រូវក្នុងការកាប់ដើមកៅស៊ូនៅទីនោះ មិនដឹងជាទៅណាអស់ រីឯកូនរបស់ខ្ញុំបាទឈ្មោះ ក៏បាត់ដែរ សូម្បីតែទូរស័ព្ទក៏មិនចូលមិនដឹងជាទៅណាទេ ។

សួរ-ឆ្លើយ៖ នៅកំឡុងខែ៣ ឆ្នាំ ឈ្មោះ បានមកជួបខ្ញុំបាទ ហើយបានសួររកកូនរបស់ខ្ញុំបាទឈ្មោះ ទៅណា មិនឃើញវេលុយឲ្យខ្ញុំ ។ ខ្ញុំបាទប្រាប់ថា មិនបានដឹងថាវាទៅណាទេ ។ គាត់ថាក្រោយពីកាប់ដើមកៅស៊ូលក់អស់ ហិកតាហើយមិនបានវេលុយទៅឲ្យគាត់ទេ ។ ខ្ញុំបានប្រាប់គាត់ថាខ្ញុំមិនបានដឹងទេព្រោះ ក្រុមហ៊ុនមេមត់ប្រាប់ខ្ញុំបាទថា ពួកគេចុះកាប់ដើមកៅស៊ូនៅក្នុងឡូតិ៍ថ្មីមិនឃើញបង់លុយឲ្យក្រុមហ៊ុន ហើយខ្ញុំបាទក៏បានចុះទៅមើលក៏មិនបានដឹងថាពួកគេទៅណាដែរ ពេលនោះឈ្មោះ ថាគាត់មិនគួរទុកចិត្តពួកនេះទេ ហើយគាត់ក៏បានទៅវិញបាត់ទៅ ។

សួរ-ឆ្លើយ៖ ឈ្មោះ បានប្រាប់ខ្ញុំបាទថាគាត់បានវេលុយឲ្យកូនរបស់ខ្ញុំបាទឈ្មោះ ចំនួនជា )ដុល្លារអាមេរិក ហើយក្នុងនោះឈ្មោះ ថាបានវេលុយចូលក្នុងគណនីរបស់ខ្ញុំបាទចំនួន ដុល្លារអាមេរិក ផង ដែរសំរាប់កក់ដើមកៅស៊ូលើកដំបូង ដូច្នេះគាត់សុំយកលុយនេះពីខ្ញុំបាទវិញ ខ្ញុំបាទប្រាប់គាត់ថាលុយនេះបានយកទៅកក់ឲ្យក្រុមហ៊ុន ចហើយកាលពីលើកដំបូង ដូច្នេះមិនអាចដកយកបានវិញទេ ។

សួរ-ឆ្លើយ៖ ក្រោយមកស្រាប់តែឈ្មោះ បានប្ដឹងខ្ញុំបាទតែម្ដង ។

សួរ-ឆ្លើយ៖ ចំពោះការកាប់ដើមកៅស៊ូនេះគឺមានឈ្មោះ ជនជាតិចិន និងឈ្មោះ ជនជាតិ ជាអ្នកមើលការខុសត្រូវក្នុងការចុះកាប់ដើមកៅស៊ូ ហើយពួកគេយកទៅលក់ទីណានោះខ្ញុំបាទមិនបានដឹងទេ ។

សួរ-ឆ្លើយ៖ ឈ្មោះ ជាកូនប្រសាររបស់ខ្ញុំបាទដែលត្រូវជាប្រពន្ធរបស់ឈ្មោះ ។ ហើយ មានម្ដាយឈ្មោះ និងឪពុកឈ្មោះ មានស្រុកកំណើតនៅកំពង់ធំ ។

សួរ-ឆ្លើយ៖ ខ្ញុំបាទសំណូមពរសុំឲ្យតុលាការធ្វើការលើកលែងចោទប្រកាន់មកលើរូបខ្ញុំបាទ ព្រោះខ្ញុំបាទមិនបានប្រព្រឹត្តដូចការប្ដឹងទេ ។ ហើយបណ្ដឹងនេះជាបណ្ដឹងលើកទី២ហើយដែលឈ្មោះ បានប្ដឹងខ្ញុំបាទ ហើយលើកទី១នោះគឺឈ្មោះ បានប្ដឹងខ្ញុំបាទទៅព្រហ្មទណ្ឌក្រសួងមហាផ្ទៃ ហើយខាងក្រសួងមហាផ្ទៃបានបញ្ជូនសំណុំរឿងមកតុលាការ ហើយតំណាងអយ្យការបានចោទប្រកាន់តែឈ្មោះ មិនបានចោទប្រកាន់មកលើខ្ញុំបាទទេ ។

សួរ-ឆ្លើយ៖ ចំពោះការរកស៊ីរបស់កូនខ្ញុំបាទឈ្មោះ ,ឈ្មោះ ,ឈ្មោះ និងឈ្មោះ ចូលហ៊ុនគ្នារបៀបណានោះខ្ញុំបាទមិនបានដឹងទេ ។ ចំពោះប្រាក់ដែលខ្ញុំបាទ

ប្រគល់ឲ្យក្រុមហ៊ុនមេមត់ចំនួ  ដុល្លារអាមេរិកនោះ ជាប្រាក់ដែលខ្ញុំបាទបង់ឲ្យក្រុមហ៊ុនថ្លៃឡូតិ៍កៅស៊ូសំរាប់កាប់លក់ ។ ចំពោះដើមកៅស៊ូ សរុប  ឡូតិ៍ មានចំនួន  ហិកតា ហើយឈ្មោះ  បានកាប់អស់  ហិកតា ស្មើ០៨ឡូតិ៍ សរុបទឹកប្រាក់បង់ឲ្យក្រុមហ៊ុន  ចំនួន  ៥ដុល្លារអាមេរិក ។ ចំពោះលុយនេះក្រុមហ៊ុនចិន បានឲ្យឈ្មោះ  យកទៅបង់ឲ្យក្រុមហ៊ុនចំការកៅស៊ូ  ចំណែកឯខ្ញុំបាទជាអ្នកទៅធ្វើឯកសារប្រគល់ទូលប្រាក់ជាមួយក្រុមហ៊ុន  តាមក្រោយ ព្រោះខ្ញុំបាទជាម្ចាស់ចុះកិច្ចសន្យាដើមជាមួយក្រុមហ៊ុនចំការកៅស៊ូ

**សួរ-ឆ្លើយ៖** ចំពោះឯកសារផ្ទេរប្រាក់ពីឈ្មោះ  មកខ្ញុំបាទចុះថ្ងៃទី  ឆ្នាំ  ចំនួនទឹកប្រាក់  ដុល្លារអាមេរិក និងឯកសារផ្ទេរប្រាក់ចុះថ្ងៃទី  ខែ  ឆ្នាំ  ចំនួនទឹកប្រាក់ចំនួន  ដុល្លារអាមេរិក ដែលលោកចៅក្រមបានបង្ហាញខ្ញុំបាទនេះ គឺជាប្រាក់កក់សំរាប់ទិញកៅស៊ូនៅ  កាលពីមុន ពុំពាក់ព័ន្ធនឹងចំការកៅស៊ូនៅ  ទេ ។

បញ្ចប់កំណត់ហេតុនៅម៉ោង ដប់មួយនិងដប់ នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ។

☑យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☐បានអានចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
| --- | --- | --- | --- |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី៤

សាលាដំបូងរាជធានីភ្នំពេញ

**បន្ទប់ស៊ើបសួរ " ហ "**
សំណុំរឿងព្រហ្មទណ្ឌ
លេខ ចុះថ្ងៃទី
ខែ ឆ្នាំ

## ដីកាកោះ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ** : ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជាដើមបណ្តឹងរដ្ឋប្បវេណី។

**អាសយដ្ឋាន** : ផ្ទះលេខ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ
រាជធានី ។

**ឱ្យចូលទៅកាន់** : សាលាដំបូងរាជធានីភ្នំពេញ នៅជាន់ទី៥ បន្ទប់អក្សរ (ហ)
**នាថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ៣០ នាទីព្រឹក**

**ដើម្បី** : សាកសួរ

**ពីដំណើររឿង** : ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ ។

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើ មកជាមួយផងប្រសិនបើមាន។

ថ្ងៃចន្ទ ១០កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨
**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

5

ឧបសម្ព័ន្ធទី៥

សាលាដំបូងខេត្តព្រះសីហនុ
សំណុំរឿងព្រហ្មទណ្ឌលេខ
ចុះថ្ងៃទី
សំណុំរឿងស៊ើបសួរលេខ . អខ
ចុះថ្ងៃទី

# កំណត់ហេតុស្តីពីការស្តាប់ចម្លើយ

# ដើមបណ្តឹងរដ្ឋប្បវេណី

ឆ្នាំពីរពាន់ដប់ប្រាំបី ខែវិច្ឆិកា ថ្ងៃទីដប់ប្រាំ វេលាម៉ោងដប់បួន និងសាមសិបនាទី

លោក ចៅក្រមសាលាដំបូងខេត្តព្រះសីហនុ ដោយមានលោក ជាក្រឡាបញ្ជីអមផង។

បានបង្ហាញខ្លួនក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើងជនដែលមានអត្តសញ្ញាណដូចខាងក្រោមៈ

លោកស្រី អត្តលេខ ជាមេធាវីការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ... មានការិយាល័យនៅអាគារ លេខ ជាន់ទី បន្ទប់ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ស/ធ-នាងខ្ញុំសូមរក្សាអង្គហេតុដូចនៅក្នុងពាក្យបណ្តឹង ចុះថ្ងៃទី និងសុំរក្សាចម្លើយរបស់កូនក្តីនាងខ្ញុំនៅក្នុងកំណត់ហេតុ ចុះថ្ងៃទី . . របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការទាំងមូល។

ស/ធ-ចំពោះដីទំហំ ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខៈ ចុះថ្ងៃទី មានទីតាំងស្ថិតនៅភូមិ សង្កាត់លេខ ក្រុង ខេត្ត កាលដើមឡើយគឺកូនក្តីនាងខ្ញុំឈ្មោះ បានទទួលលទ្ធកម្មកម្មសិទ្ធិតាមរយៈការលក់ទិញ ដែលមានកិច្ចសន្យាទិញ-លក់ដីមិនកែប្រែ ចុះថ្ងៃទី . . ពីឈ្មោះ និងប្រពន្ធឈ្មោះ ។ម្យ៉ាងវិញទៀត ដីដែលមានទំហំដូចក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់ខាងលើគឺបាន ធ្វើរបងថ្មព័ទ្ធជុំវិញព្រំប្រទល់ដី តាំងពីម្ចាស់ដើមមកម្ល៉េះ ហើយការកសាងនូវប័ណ្ណសំគាល់សិទ្ធិនេះគឺត្រូវបានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីសុរិយោដីទៀតផង តែក្រោយមកឈ្មោះ បានមកធ្វើប័ណ្ណកម្មសិទ្ធិគ្របលើដីរបស់កូនក្តីខ្ញុំ ដោយគាត់បានឈូសរបងរបស់កូនក្តីខ្ញុំចោល។ចំណែកឯសាក្សីជាសមត្ថកិច្ចចូលរួមក្នុងការកសាងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុខាងលើនេះគឺនាងខ្ញុំនិងដាក់ជូនភស្តុតាងឲ្យតុលាការធ្វើការកោះបំភ្លឺនៅពេលក្រោយ។

ស/ធ-ចំពោះការលក់ទិញនូវអចលនវត្ថុដែលមានទំហំនិងទីតាំងដូចក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខពន ចុះថ្ងៃទី តាមរយៈកិច្ចសន្យាទិញ-លក់ដីមិនកែប្រែ ចុះថ្ងៃទី . . គឺត្រូវបានធ្វើឡើងរវាងបុគ្គលឯកជនដោយមានការបញ្ជាក់ទទួលស្គាល់ដោយមេធាវីប៉ុណ្ណោះ ដោយមិនទាន់មានការចូលរួមដឹងឮដោយអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច និងមន្ត្រីសុរិយោដីនោះទេ។ប៉ុន្តែមុនពេលដែលកូនក្តីនាងខ្ញុំសម្រេចចិត្តទិញដីដែលមានទំហំ និងទីតាំងដូចក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុខាងលើគឺកូនក្តីនាងខ្ញុំបានសាកសួរព័ត៌មានទៅអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ចរួចហើយ ដោយខាងអាជ្ញាធរបានឆ្លើយបញ្ជាក់ថាៈគឺជាប័ណ្ណកម្មសិទ្ធិរបស់ឈ្មោះ ដែលមានប័ណ្ណលេខ ចុះថ្ងៃទី ។លុះមកដល់អំឡុងខែ ឆ្នាំ កូនក្តីនាងខ្ញុំ

ក៏បានដាក់ពាក្យស្នើសុំចូល មកអង្គភាពសុរិយោដីដើម្បីរៀបចំនីតិវិធីកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់លើដីដែលមានទំហំនិងទីតាំងដូចក្នុងប័ណ្ណសំគាល់ សិទ្ធិកាន់កាប់អចលនវត្ថុខាងលើមកដាក់ឈ្មោះកូនក្តីនាងខ្ញុំជាអ្នកមានសិទ្ធិកាន់កាប់វិញ។នៅពេលនោះអាជ្ញាធរសុរិយោដីក៏បានបង្កើតគណកម្មការចុះវាស់វែងទីតាំងដី ដែលមាននៅក្នុងប័ណ្ណសំគាល់សិទ្ធិខាងលើ ដើម្បីមានមូលដ្ឋានរៀបចំឯកសារការកាត់ឈ្មោះផ្ទេរសិទ្ធិកាន់កាប់ឲ្យមកកូនក្តីរបស់នាងខ្ញុំ ពេលនោះស្រាប់តែមានជនត្រូវចោទឈ្មោះ ចូលមកជំទាស់ដោយបានអះអាងថាដីដែលកូនក្តីនាងខ្ញុំបានទិញពីឈ្មោះ និងប្រពន្ធឈ្មោះ គឺជាដីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងទៅលើវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខ ចុះថ្ងៃទី . . ប៉ុន្តែផ្ទុយទៅវិញតាមការស្រាវជ្រាវលើប្រវត្តិដីរបស់ឈ្មោះ ក្នុងការកសាងវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខ ចុះថ្ងៃទី . . គឺផ្អែកលើកំណត់ហេតុអង្កេតដីចំនួន ប៉ុណ្ណោះ គឺកំណត់ហេតុអង្កេតដី ចុះថ្ងៃទី .. . ដែលមានទំហំផ្ទៃដី អា និងគឺកំណត់ហេតុអង្កេតដី ចុះថ្ងៃទី . ដែលមានទំហំផ្ទៃដីប្រមាណ អា សង់ទីអា។ហេតុនេះទំហំផ្ទៃដីកម្មសិទ្ធិរបស់ឈ្មោះ បើផ្អែកតាមកំណត់ហេតុអង្កេតដីទាំងពីរខាងលើគឺមានទំហំប្រមាណ អា សង់ទីអា ប៉ុណ្ណោះ ផ្ទុយទៅវិញទំហំផ្ទៃដីដែលមានក្នុងវិញ្ញាបនបត្រសម្គាល់អចលវត្ថុលេខ ចុះថ្ងៃទី .. ដែលមានឈ្មោះ និងប្រពន្ធជាកម្មសិទ្ធិករ បែរជាមានទំហំដីរហូតដល់ទៅ ម៉ែត្រការ៉េទៅវិញ។ដូច្នេះ ឃើញថាឈ្មោះ បានកសាងនូវវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើបានគ្របដណ្តប់លើផ្ទៃដីទាំងមូលរបស់កូនក្តីនាងខ្ញុំ។

សំណូមពរៈសុំឲ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់។

បញ្ចប់កំណត់ហេតុនៅវេលាម៉ោងដប់ប្រាំ និងសាមសិបនាទី បានអានឲ្យសាមីខ្លួនស្តាប់នូវសេចក្តីទាំងស្រុង ឆ្លើយថាត្រឹមត្រូវ យល់ព្រមចុះហត្ថលេខាជាមួយយើង។

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី** **ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

6

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**********

តុលាការខេត្ត-ក្រុង

..............................

*********

លេខ: ...................

# ដីកាកោះ

******

យើង..........................................ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ..................................

អញ្ជើញឈ្មោះ..............................................ជា......សាក្សី......................................មានទីលំនៅបច្ចុប្បន្ននៅ

ភូមិ .................. ឃុំ-សង្កាត់ .............................. ស្រុក-ខណ្ឌ .............................. ខេត្ត-ក្រុង ....................

ឱ្យចូលទៅកាន់តុលាការខេត្ត-ក្រុង...............................................ទៅវេលាម៉ោង ...........................................

ថ្ងៃទី............ ខែ.................. ឆ្នាំ.................... ដើម្បី......សួរចម្លើយ...............................................................

ពីដំណើររឿងដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ: ............... ចុះថ្ងៃទី ............... ខែ............... ឆ្នាំ ...........

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើមកជាមួយផង ប្រសិនបើមាន ។

ធ្វើនៅ....................... ថ្ងៃទី............. ខែ.............. ឆ្នាំ...........

**ចៅក្រមស៊ើបអង្កេត**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី៧

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ

សំណុំរឿងព្រហ្មទណ្ឌ
លេខៈ
ចុះថ្ងៃទី ខែ ឆ្នាំ
លេខស៊ើបសួរៈ
ចុះថ្ងៃទី ខែ ឆ្នាំ

# កំណត់ហេតុស្តីពី
# ការស្តាប់ចម្លើយសាក្សី

(មាត្រា ១៥៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំពីរ ខែសីហា ថ្ងៃទីសាមសិប វេលាម៉ោងបី រសៀល

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ អមដោយ លោក ជាក្រឡាបញ្ជី ។

បានមកបង្ហាញខ្លួនក្នុងនាមជាសាក្សី នៅក្នុងមន្ទីរស៊ើបសួរនៅចំពោះមុខយើង ជនដែលមានអត្តសញ្ញាណដូចខាងក្រោម :

ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជាតិ ទីកន្លែងកំណើតនៅភូមិ ស្រុក ខេត្តកំពង់ធំ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ ស្រុក ខេត្ត មានប្តីឈ្មោះ មានកូន នាក់ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់)។ ជាអនីតិជន

ជននេះចេះនិយាយ ,ចេះអាន និងចេះសរសេរអក្សរខ្មែរបានទេ ។

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឱ្យដឹងយ៉ាង ច្បាស់អំពីរឿងរ៉ាវ ដែលព្រះរាជអាជ្ញាបានប្តឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខៈ ថ្ងៃទី ខែមិថុនា ឆ្នាំ ។

☑ ជននេះបានស្បថរួចហើយ

☐ ជននេះមិនព្រមស្បថ

☐ សាក្សីត្រូវបានអនុញ្ញាតឱ្យរួចពីសម្បថ

យើងបានសួរ និងស្តាប់ចម្លើយឈ្មោះនេះ ដូចខាងក្រោមថា:

**សួរ-ឆ្លើយ៖** នាងខ្ញុំអាចឆ្លើយបំភ្លឺជូនតុលាការបាន នៅពេលនេះ នាងខ្ញុំជាប្រពន្ធរបស់ឈ្មោះ ។

**សួរ-ឆ្លើយ៖** កាលពីអំឡុងឆ្នាំ និងដើមឆ្នាំ ប្តីនាងខ្ញុំឈ្មោះ បានស្គាល់ជនជាតិ មួយចំនួន (ឈ្មោះ ,ឈ្មោះ និងឈ្មោះ ) ហើយសហការគ្នារកស៊ីទិញដើមកៅស៊ូ ទៅលក់នៅប្រទេសវៀតណាម ការទិញលក់នោះគឺដើរទិញតាមចំការតូចៗហើយម្ចាស់គេលក់ឱ្យមានទំហំចាប់ពី ហិកតា, ហិកតានិង ហិកតាជាដើម ។

**សួរ-ឆ្លើយ៖** នៅពេលនោះនាងខ្ញុំបានជួយគិតប្រាក់បញ្ជីស្នាមផ្សេងៗផងដែរ(ការរកស៊ីពេលនោះមានលទ្ធផលល្អ មិនមានអ្វីបញ្ហាអ្វីកើតឡើងនោះទេ )។ តែប៉ុន្តែចាប់តាំងពីពេលដែលពួកគាត់បានមកសុំទិញដើមកៅស៊ូ ដែលឪពុកក្មេកខ្ញុំបានទិញពីក្រុមហ៊ុន ពួកគាត់ លែងឱ្យនាងខ្ញុំចូលជួយការងារនោះទៀតហើយ ( ចុងឆ្នាំ ) គឺគាត់បានយកគណនេយ្យធនាគាររបស់នាងខ្ញុំប្រើ ដើម្បីឱ្យឈ្មោះ វេរប្រាក់ចូល សម្រាប់ទូទាត់ថ្លៃដើមកៅស៊ូជូនឪពុកក្មេកនាងខ្ញុំចំនួន ផងតែប៉ុណ្ណោះ ដែលរួមមាន ៖ លើកទី នៅថ្ងៃទី ចំនួន ដុល្លាអាមេរិក ដកវិញនៅថ្ងៃដដែល និងលើកទី នៅថ្ងៃទី ដុល្លាអាមេរិក ដកវិញនៅថ្ងៃដដែល ។ ចំពោះការដកប្រាក់ទាំងពីរលើកនេះគឺនាងខ្ញុំទៅដកជាមួយប្តីនាងខ្ញុំ

ហើយប្រាក់ទាំងនោះប្តីរបស់នាងខ្ញុំជាអ្នកទុក ហើយក្រោយមកប្តីនាងខ្ញុំក៏បានបើកគណនេយ្យផ្ទាល់ខ្លួន មិនមានយករបស់នាងខ្ញុំទៅប្រើទៀតទេ ។

សួរ-ឆ្លើយ៖តាំងពីពេលនោះមកនាងខ្ញុំមិនដឹងរឿងរបស់ពួកគាត់ទេ ហេតុនេះនាងខ្ញុំសូមបដិសេធចោលទាំងស្រុងបណ្តឹងរបស់ឈ្មោះ ហៅ ដែលបានប្តឹងនាងខ្ញុំថា បានរំលោភទំនុកចិត្ត និងឆបោកប្រាក់គាត់ចំនួន ដុល្លារអាមេរិក ។

សួរ-ឆ្លើយ៖ ចំពោះគណនីធនាគាររបស់នាងខ្ញុំបានបង្កើតក្នុងថ្ងៃទី ខែ ឆ្នាំ របស់ធនាគារ ចំណែករបស់ប្តីនាងខ្ញុំឈ្មោះ នាងខ្ញុំមិនចាំនោះទេ ។

-សាក្សី អានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួនដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំនុចណាទេ ឲ្យចុះហត្ថលេខា ឬផ្តិតមេដៃលើកំណត់ហេតុនេះ។

-បានអានចប់សព្វគ្រប់ ហើយសាក្សី មិនមានបដិសេធចំនុចណាទេ និង បានចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង និងក្រឡាបញ្ជី ។

| សាក្សី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី៨

**អយ្យការអមសាលាដំបូង**
**ខេត្តព្រះសីហនុ**

# កំណត់ហេតុសួរតទល់

**សំណុំរឿងលេខៈ**
**ចុះថ្ងៃទី**

ឆ្នាំពីរពាន់ដប់ប្រាំបី ខែតុលា ថ្ងៃទីបួន វេលាម៉ោងដប់បួន និង សាមសិបនាទីរសៀល។

យើង ព្រះរាជអាជ្ញា អមសាលាដំបូងខេត្តព្រះសីហនុ

ដោយមានកញ្ញា ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ

ថ ដើមបណ្តឹងរដ្ឋប្បវេណី អមដោយលោកស្រី និងលោក និងលោក ជាមេធាវីតំណាងឲ្យឈ្មោះ ។

សួរ-ឆ្លើយៈ ខ្ញុំឈ្មោះ ភេទស្រី អាយុ៥៤ឆ្នាំ កើតឆ្នាំ១៩៦៤ ជនជាតិខ្មែរ មុខរបរពាណិជ្ជករ មានទីកន្លែងកំណើតនៅសង្កាត់ជ្រោយចង្វារ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃនៅ ផ្ទះលេខ ១០ ផ្លូវនរោត្តម ភូមិ១០ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ប្តីឈ្មោះ (ស្លាប់) មានកូន០៣នាក់។ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ (រស់)។ ប្រវត្តិផ្តន្ទាទោសពីមុន គ្មាន។

សួរ-ឆ្លើយៈ លោកស្រី ភេទស្រី អត្តលេខ ៩១៤ ជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ ។

សួរ-ឆ្លើយៈលោក ភេទប្រុស អត្តលេខ ៦៦៩ និងលោក ភេទប្រុស អត្តលេខ ៦៥៨ ជាមេធាវីតំណាងឲ្យឈ្មោះ ។

សួរ-ឆ្លើយៈ លោកមេធាវី និងលោកមេធាវី បានថ្លែងថាៈ ខ្ញុំសូមចូលឆ្លើយតទល់ជំនួសកូនក្តីរបស់ខ្ញុំនាពេលនេះតែម្តង ដោយសារតែកូនក្តីរបស់ខ្ញុំមានបញ្ហាសុខភាពត្រូវសម្រាកនៅមន្ទីរពេទ្យ។

សួរ-ឆ្លើយៈ ដើមបណ្តឹងឈ្មោះ ដោយមានលោកស្រីមេធាវី អមផង បានឲ្យដឹងថាៈ ខ្ញុំនៅតែបន្តប្តឹងលើ ឈ្មោះ ដូចមានក្នុងពាក្យបណ្តឹងរបស់ខ្ញុំ ចុះថ្ងៃទី ខែ ឆ្នាំ ដដែល និងសូមរក្សាចម្លើយរបស់ខ្ញុំដូចមានក្នុងកំណត់ហេតុស្តាប់ចម្លើយ ចុះថ្ងៃទី ខែ ឆ្នាំ ទុកជាបានការដដែល។ មូលហេតុដែលខ្ញុំប្តឹងលើឈ្មោះ និង ប្រពន្ធឈ្មោះ ដោយហេតុថាខ្ញុំបានទិញដីពីឈ្មោះ ដោយ បានចុះកិច្ចសន្យាទិញលក់ដីត្រឹមត្រូវ ចុះថ្ងៃទី ខែ ឆ្នាំ ដោយក្នុងនោះខ្ញុំបានប្រគល់ប្រាក់គ្រប់ចំនួនឲ្យឈ្មោះ រួចរាល់អស់ហើយតាមមូលប្បទានបត្រចំនួន ២ សន្លឹក ហើយនៅពេលដែលខាងខ្ញុំបានស្នើសុំចុះវាស់វែងដល់ទីតាំងដីជាក់ស្តែងទៅមន្ទីរសុរិយោដីខេត្តព្រះសីហនុ បន្ទាប់មក ខាងជំនាញសុរិយោដី និង ខ្ញុំបានចុះទៅដល់ទីតាំងដីដោយមានប្រធានមន្ទីរសុរិយោដីខេត្តព្រះសីហនុ, លោកប្រធានភូមិបាលក្រុង ព្រះសីហនុ និងខ្ញុំឈ្មោះ បានចុះទៅដល់ទីតាំងដី។ ពេលដែលខាងជំនាញសុរិយោដីចុះ ពិនិត្យ និង វាស់វែងតាមប្លង់ដែលខ្ញុំបានទិញនោះ ពេលកំពុងវាស់វែងក៏មានភាគីកូនប្រសាររបស់ឈ្មោះ

(មិនស្គាល់ឈ្មោះ) បានទៅដល់ទីតាំងដីនោះ ហើយ សួរថា "តើខ្ញុំមកទីតាំងដីនេះធ្វើអ្វី" ខ្ញុំក៏ឆ្លើយថា "ចុះមកវាស់ដី" បន្ទាប់មកឈ្មោះ ក៏បានមកដល់ហើយគាត់សួរថា "សិអាងអ្វីបានចុះមកវាស់ដីនេះ" ហើយខ្ញុំក៏ឆ្លើយថា "ខ្ញុំបានទិញដីនេះពីឈ្មោះ ហើយមានប្លង់ជាសំអាង" ហើយគាត់ឆ្លើយថា "ដីគាត់បានប្លង់ជាប្រព័ន្ធរួចហើយ ហើយដីដែលវាស់នេះជាដីរបស់ឆាយហ៊ួ (មេការ) របស់ខ្ញុំទេ" ពេលនោះខ្ញុំបានឆ្លើយថា "ខ្ញុំបានទិញពីប្រពន្ធគាត់ (ប្រពន្ធមេការ) ហើយខ្ញុំក៏បានឆ្លើយថា "បើច្រិចឯងដឹងថាដីជារបស់មេការរបស់ច្រិចឯងហើយហេតុអ្វីបានធ្វើប្លង់ប្រព័ន្ធគ្របលើដីគេ"ពេលនោះ ឈ្មោះ នៅស្ងៀម បន្ទាប់មក ខ្ញុំក៏ និយាយថា "យើងទៅរកកន្លែងជជែកគ្នាបើមានឯកសារអ្វីដាក់មករៀងខ្លួន" បន្ទាប់មក ក៏នាំគ្នាទៅមន្ទីរ សុរិយោដីខេត្តព្រះសីហនុដោយមានឈ្មោះ មកផងដែរ ពេលនោះក៏មានមនុស្សប្រុសម្នាក់ មិន ស្គាល់ឈ្មោះ ប៉ុន្តែមានមុខមកទីនេះ (ហៀង មករា ទើបតែស្គាល់នាពេលនេះ) ពេលនោះឈ្មោះ បានសួរខ្ញុំថា តើខ្ញុំមានអ្វីជាសំអាង ហើយខ្ញុំក៏បានហុចកិច្ចសន្យាទិញលក់របស់ខ្ញុំឲ្យមើល ហើយគាត់ក៏បានថាកិច្ចសន្យានេះទើបតែធ្វើនៅឆ្នាំ២០១៨ ប៉ុណ្ណោះ ហើយឈ្មោះ ឆ្លើយថាដីនេះគាត់បានទិញពីឈ្មោះ ប្រាក់ ហម ហើយក៏បែកគ្នាទៅ លុះស្អែកឡើងមានមនុស្សម្នាក់ប្រាប់ថាជាកូនរបស់ឈ្មោះ គឺឈ្មោះ បានមកជួបគ្នានៅមន្ទីរសុរិយោដីខេត្តរួចបានប្រគល់ឯកសារជូនទៅប្រធានមន្ទីរសុរិយោដីខេត្ត បន្ទាប់មក ក៏នាំគ្នាចុះទៅទីតាំងដីដោយមានប្រធានមន្ទីរសុរិយោដីឈ្មោះ និងមន្ត្រីសុរិយោដីផ្សេងទៀត, រូបខ្ញុំ,ឈ្មោះ ពេលចុះទៅ ដល់ទីតាំងដីបានបន្តិចមកក៏កូនប្រុសរបស់ឈ្មោះ (មិនស្គាល់ឈ្មោះ) បានទៅដល់ហើយនិយាយថា "អ៊ី អ៊ីឯងហ៊ានទិញដីមានរឿង" ពេលនោះខ្ញុំក៏បានឆ្លើយថា "ប្រទេសមានច្បាប់ អ្វីក៏ដោយគឺសំអាងលើឯកសាររៀងខ្លួន" បន្ទាប់មកកូនប្រុសរបស់ឈ្មោះ ក៏បានសុំទោសខ្ញុំ។ ពេលឈ្មោះ ទៅចង្អុលបង្ហាញនោះគឺមិនមែនចង្អុលនៅដីដែលមានទំនាស់នេះទេ គឺចង្អុលបង្ហាញទីតាំងដីដែលគាត់បានលក់ឲ្យឈ្មោះ ផ្សេងដែលមានទីតាំងនៅជាប់គ្នា។ ក្រោយពីបែកគ្នានៅទីតាំងដីខ្ញុំបានទៅមន្ទីរសុរិយោដីខេត្តដើម្បីស្នើសុំឆែកឲ្យដឹងថាតើដីដែលគាត់អះអាងថាជាដីរបស់គាត់នេះមានប្រភពមកពីណា ក្រោយពីសុរិយោដីឆែករួចបានឲ្យដឹងថាឈ្មោះ បានកសាងបណ្ណសំគាល់សិទ្ធិកាន់កាប់លេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានម្ចាស់ឈ្មោះ និងប្រពន្ធឈ្មោះ មានទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិ សង្កាត់ ខណ្ឌ ខេត្តព្រះសីហនុ ការកសាងបណ្ណនេះដោយផ្អែកលើកំណត់ហេតុចំនួន ២ សន្លឹកលេខ ចុះថ្ងៃទី ខែ ឆ្នាំ ទំហំ អា និងកំណត់ហេតុអង្កេតដីទី២ លេខ ចុះថ្ងៃទី ខែ ឆ្នាំ ទំហំ អា សង់ទីអា ដែលសរុបទាំងពីរកំណត់ហេតុនេះចូលគ្នាដីរបស់ឈ្មោះ គឺមានទំហំ អា សង់ទីអា។ ក្រោយពីស្រាវជ្រាវរួចខ្ញុំក៏បានដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។

សួរ-ឆ្លើយៈ លោក ជាមេធាវីតំណាងឲ្យឈ្មោះ បានឲ្យដឹងថាៈ ចំពោះបណ្ណសម្គាល់សិទ្ធកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ គឺជាភស្តុតាងដែលបញ្ជាក់ថាកូនក្តីរបស់ខ្ញុំជាម្ចាស់កម្មសិទ្ធិស្របច្បាប់នៅលើទីតាំងដីនេះ។ ចំពោះការចោទប្រកាន់មកលើកូនក្តីរបស់ខ្ញុំគឺភាគីខាងដើមបណ្តឹងជាអ្នកមានកាតព្វកិច្ចបង្ហាញ ហើយកូនក្តីរបស់ខ្ញុំក៏គ្មាន

សមត្ថកិច្ចធ្វើបណ្ណកម្មសិទ្ធិដោយខ្លួនឯងទេ ដោយសារតែការកសាងបណ្ណគឺជាសមត្ថកិច្ចរបស់មន្ត្រីជំនាញប៉ុណ្ណោះ។ ចំពោះប្រវត្តិដីនោះយ៉ាងណាគឺខ្ញុំមិនដឹងនោះទេ ដោយសារតែការកសាងបណ្ណគឺជាភារកិច្ចរបស់មន្ត្រីជំនាញសុរិយោដី។ ហើយពាក់ព័ន្ធនឹងបណ្ណសម្គាល់សិទ្ធិកាន់កាប់នេះគឺមានមន្ទីរសុរិយោដីខេត្តជាអ្នកចេញដោយផ្ទាល់ដោយមិនមានការចេញឯកសារណាភ្ជាប់មកជាមួយបណ្ណនេះឡើយឲ្យកូនក្តី របស់ខ្ញុំ ហើយបណ្ណនេះក៏មិនតម្រូវឲ្យមានឯកសារភ្ជាប់ដែលតម្រូវឲ្យបណ្ណនេះមានសុពលភាពឡើយ ហើយប្រសិនបើ មានភាពមិនត្រឹមត្រូវ គឺមានតែអាជ្ញាធរទេដែលមានសិទ្ធិបញ្ជាក់ថាបណ្ណនេះមានភាពមិនត្រឹមត្រូវមិនមែនអ្នកប្តឹងទេដែលមកអះអាងចោទប្រកាន់មកលើកូនក្តីខ្ញុំនោះទេ។ ហើយចំពោះពាក្យបណ្តឹងដែលបានលើកឡើងនេះភាគីអ្នកប្តឹងសំអាងតែលើបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ តែប៉ុណ្ណោះ ដែលបណ្ណនេះជាប្រភេទបណ្ណភោគៈ ដែលមិនអាចសំអាងលើបណ្ណភោគៈមួយយកមកប្តឹងតតាំងជាមួយកូនក្តីរបស់ខ្ញុំដែលមានបណ្ណជាលក្ខណៈប្រព័ន្ធឡើយ ចំពោះដីនេះគឺកូនក្តីរបស់ខ្ញុំដែលជាម្ចាស់កម្មសិទ្ធិស្របច្បាប់បានគ្រប់គ្រងកាន់កាប់ជាក់ស្តែង និងបានធ្វើការកាប់ឆ្ការឈូសឆាយ និងធ្វើរបងយ៉ាងរឹងមាំ ព័ទ្ធជុំវិញទីតាំងដីជាច្រើនឆ្នាំមកហើយមិនដែលឃើញមានតតិយជនណាមួយ ឬអ្នកប្តឹងមកធ្វើការតវ៉ា ឬទាមទារសិទ្ធិណាមួយនៅលើទីតាំងដីនេះទេ។ ក្នុងនោះដែរ បើពិនិត្យលើសិទ្ធិរបស់អ្នកប្តឹងគឺគាត់ជាភាគី អ្នកទិញដែលមិនទាន់ទទួលលទ្ធកម្មកម្មសិទ្ធិនៅឡើយទេ ហេតុដូច្នេះហើយ អ្នកទិញត្រូវដោះស្រាយជាមួយភាគីអ្នកលក់តាមកិច្ចសន្យាទិញ លក់ដីមិនកែប្រែចុះថ្ងៃទី ខែ ឆ្នាំ ដោយផ្ទាល់ មិនមែនមកប្តឹងកូនក្តីខ្ញុំទាំងបំពានដូច្នេះឡើយ ចំពោះការលក់ទិញ ភាគីអ្នកទិញបានដឹងច្បាស់លាស់ថាស្ថានភាពដីនៃការលក់ទិញនេះគឺមានវិវាទ ប៉ុន្តែ អ្នកទិញនៅតែទទូចទិញយកដីនេះ ហេតុនេះគោលបំណងរបស់អ្នកទិញគាត់ចង់ទិញដី ឬ ទិញរឿងចំពោះតម្លៃនៃការលក់ទិញវិញក៏មានភាពមិនប្រក្រតីយ៉ាងខ្លាំង ដែលហេតុថានៅក្នុងកិច្ចសន្យាគូភាគីបានឯកភាព គ្នាទិញលក់ក្នុងតម្លៃ ដុល្លារ លើទំហំដី ម៉ែត្រការ៉េ ដែលស្មើនឹងតម្លៃ ដុល្លារក្នុង ម៉ែត្រការ៉េ ដែលតម្លៃនេះគឺជាតម្លៃ ដែលមិនអាចទៅរួចឡើយ ព្រោះថាតម្លៃជាក់ស្តែងនៅក្នុង តំបន់នេះមានតម្លៃចាប់ពី ៣០០ ទៅ ៤០០ ដុល្លារក្នុង ១ ម៉ែត្រការ៉េ ហេតុដូច្នេះឡើយ គ្មានអ្នកលក់ណាទៅលក់ដីក្រោយតម្លៃទីផ្សារ ១០ ទៅ ២០ ដង នោះទេ ចំពោះទីតាំងដីជាក់ស្តែងវិញ គឺអ្នកប្តឹងបានចុះទៅដល់ទីតាំងដីនោះជាច្រើនលើកមកហើយ និងបានឃើញយ៉ាងច្បាស់ថាដីនេះគឺជាដីដែលមានរបងព័ទ្ធជុំវិញត្រឹមត្រូវ (ព័ទ្ធជុំវិញមួយជុំដី) និងជាប្រភេទដីដែលបានឈូសឆាយ រាបស្មើរស្អាតដែលវាមានទំហំសុបហិចតាជាងឯណោះ ហេតុនេះអ្នកទិញដឹងច្បាស់ណាស់ ថាដីនេះមានម្ចាស់កម្មសិទ្ធិគ្រប់គ្រងយ៉ាងត្រឹមត្រូវគឺមិនមានបង្គោលព្រំ ឬចំនុចសម្គាល់ណាមួយថាជាដីរបស់ភាគីអ្នកលក់ឡើយ ហេតុដូច្នេះហើយ ហេតុអ្វីអ្នកទិញនៅតែទទូចទិញយកដីនេះទៀត ប្រសិនបើ អ្នកទិញជាអ្នកទិញដោយសុចរិតគឺអ្នកទិញមិនទៅទិញដីដែលមានរឿងឡើយ។ សរុបជារួម អ្នកប្តឹងមិនមែនជាម្ចាស់កម្មសិទ្ធិនៅលើទីតាំងដីខាងលើហើយគាត់ក៏មិនទាន់បានធ្វើលទ្ធកម្មកម្មសិទ្ធិនៅលើដីខាងលើនេះទេ ហេតុនេះហើយអ្នកទិញមិនមានសិទ្ធិនិងទំនាក់ទំនងគតិយុត្តណាមួយ និងមិនមានមូលដ្ឋានច្បាស់លាស់ពិតប្រាកដក្នុងការប្តឹងចោទប្រកាន់ មកលើកូនក្តីខ្ញុំដែលជាម្ចាស់កម្មសិទ្ធិករស្របច្បាប់នៅលើទីតាំងដីនេះ និងបានគ្រប់គ្រងកាន់កាប់ ជាក់ស្តែងរាប់ ឆ្នាំមកហើយ។

សួរ-ឆ្លើយៈ ដើមបណ្តឹងឈ្មោះ ដោយមានលោកស្រីមេធាវី អមផង បានឲ្យដឹងថា៖ ចំពោះការចោទប្រកាន់ខ្ញុំថាទិញលក់មិនប្រក្រតីនោះ គឺខ្ញុំសូមបញ្ជាក់ថា ខ្ញុំមានសិទ្ធិទិញនិងលក់ ដោយមានការព្រមព្រៀងគ្នារវាងអ្នកលក់ និងអ្នកទិញ ហើយខ្ញុំក៏មានសិទ្ធិប្តឹងផងដែរ ដោយសារតែខ្ញុំបានប្រគល់ប្រាក់ទិញគ្រប់ចំនួនអស់ហើយ គ្រាន់តែខ្ញុំមិនទាន់បានធ្វើការចុះបញ្ជីប៉ុណ្ណោះ។ ចំពោះការកសាងប្លង់ជាប្រព័ន្ធរបស់ខាងភាគីឈ្មោះ នោះគឺគាត់បានដីពីណាដែលឃើញទំហំរហូតដល់ជាង ២ ម៉ឺនម៉ែត្រការ៉េ ហើយខ្ញុំក៏បានស្រាវជ្រាវឃើញថាប្លង់ជាប្រព័ន្ធរបស់ភាគីខាងឈ្មោះ គឺមិនមានអ្នកជាប់ព្រំចំនួន ២ នាក់ប្តឹងមេដៃនោះទេ។

**សួរ-ឆ្លើយៈ ដើមបណ្តឹងឈ្មោះ ដោយមានលោកស្រីមេធាវី អមផង បានឲ្យ**ដឹងថា៖ ខ្ញុំសូមឲ្យភាគីខាងឈ្មោះ បង្ហាញភស្តុតាងឯកសារនៃការកសាងបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ១៨០១០២០២-០៣៨៩ នេះមកហើយប្រសិនបើឯកសារភស្តុតាងមកបង្ហាញពីការកសាងបណ្ណនោះមិនត្រឹមត្រូវទេ គឺសូមឲ្យតុលាការចោទប្រកាន់លើឈ្មោះ និង ប្រពន្ធ ឈ្មោះ ដូចក្នុងពាក្យបណ្តឹង។

សួរ-ឆ្លើយៈ លោក ជាមេធាវីតំណាងឲ្យឈ្មោះ បានឲ្យដឹងថា៖ ខ្ញុំសូមបដិសេធការលើកឡើងរបស់អ្នកប្តឹងទាំងស្រុង ពីព្រោះថាកាតព្វកិច្ចក្នុងការស្វែងរកភស្តុតាង ក្នុងការដាក់បន្ទុកមកលើកូនក្តីរបស់ខ្ញុំគឺជាកាតព្វកិច្ចរបស់អ្នកប្តឹងមិនមែនជារបស់កូនក្តីខ្ញុំឡើយ ហើយអ្នកប្តឹង ក៏មិនមានមូលដ្ឋានត្រឹមត្រូវក្នុងការប្តឹងចោទប្រកាន់កូនក្តីខ្ញុំនោះទេ ចំពោះកូនក្តីខ្ញុំបានបង្ហាញនូវភាព ត្រឹមត្រូវក្នុងនាមជាម្ចាស់កម្មសិទ្ធិករក្នុងការគ្រប់គ្រងកាន់កាប់ អភិវឌ្ឍន៍ ជាក់ស្តែងនៅលើទីតាំងដីហើយសិទ្ធិលើកម្មសិទ្ធិរបស់កូនក្តីខ្ញុំគឺត្រូវបានទទួលស្គាល់តាមរយៈវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ចុះថ្ងៃទី ខែ ឆ្នាំ ដែលសិទ្ធិលើកម្មសិទ្ធិនេះត្រូវបានការពារ ដោយច្បាប់ភូមិបាលនៃព្រះរាជាណាចក្រកម្ពុជាផងដែរ។ ហេតុដូច្នេះហើយ កូនក្តីខ្ញុំសូមសំណូមពរឲ្យអ្នកប្តឹងធ្វើការដកពាក្យបណ្តឹងចុះថ្ងៃទី ខែ ឆ្នាំ ក្នុងពេលនេះតែម្តង។ ប្រសិនបើ អ្នកប្តឹងមិនធ្វើការដកបណ្តឹងនេះទេកូនក្តីខ្ញុំនឹងរក្សាសិទ្ធិក្នុងការប្តឹងត្រឡប់ទៅវិញ និង ទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តចំពោះការប្តឹងដែលគ្មានមូលដ្ឋាន និងគ្មានភាពត្រឹមត្រូវនេះ ហើយសំណូមពរឲ្យតុលាការធ្វើការពិនិត្យ និង សម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះសំណុំរឿងនេះតាមផ្លូវច្បាប់ដើម្បីផ្តល់ភាពត្រឹមត្រូវ និងយុត្តិធម៌ជូនកូនក្តីខ្ញុំដែលជាជនរងគ្រោះ។

សួរ-ឆ្លើយៈ ដើមបណ្តឹងឈ្មោះ ដោយមានលោកស្រីមេធាវី អមផង បានឲ្យដឹងថា៖ ខ្ញុំសូមរក្សាការប្តឹងដូចក្នុងពាក្យបណ្តឹងរបស់ខ្ញុំដដែល។

ចំណាំខ្ញុំអស់តែប៉ុណ្ណោះ ។

បញ្ឈប់កំណត់ហេតុត្រឹមវេលាម៉ោងដប់ប្រាំមួយ និងសែសិប នាទីរសៀល នាថ្ងៃខែឆ្នាំដដែល។

ឈប់សួរ បានអានឲ្យស្តាប់ សាមីខ្លួនឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬផ្តិតមេដៃជាមួយយើង ។

**ដើមបណ្តឹង**

**រដ្ឋប្បវេណី** មេធាវី ក្រឡាបញ្ជី ព្រះរាជអាជ្ញា



៩

ឧបសម្ព័ន្ធទី៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
********

តុលាការខេត្ត-ក្រុង
..........................
********

# ដីកាចាត់តាំងអ្នកជំនាញ [១]

********

លេខ ....................

យើង ................................... ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង ........................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខៈ ............... ចុះថ្ងៃទី ............ ខែ .................. ឆ្នាំ ...................... របស់អយ្យការអមតុលាការខេត្ត-ក្រុង ........................................។

បានឃើញនីតិវិធីចោទប្រកាន់លើឈ្មោះ ............................................ ភេទ .......... អាយុ ...........ឆ្នាំ ជាតិ....................... របររកស៊ី .......................... កើតនៅភូមិ ......................... ឃុំ-សង្កាត់....................... .... ស្រុក-ខណ្ឌ...........................ខេត្ត-ក្រុង.....................................ទីលំនៅបច្ចុប្បន្ននៅភូមិ............................... ឃុំ-សង្កាត់..............................ស្រុក-ខណ្ឌ ..........................ខេត្ត-ក្រុង ....................... ទោសពីមុន .........។ ឪពុកឈ្មោះ .........................................................ម្ដាយឈ្មោះ................................................................ ប្រពន្ធឬប្ដីឈ្មោះ .........................................មានកូន ..........នាក់ ឬនៅលីវ.......................................។ ពិរុទ្ធ............................................................................................................................................... ប្រព្រឹត្តនៅភូមិ ............................ ឃុំ-សង្កាត់ ............................. ស្រុក-ខណ្ឌ..................................... ខេត្ត-ក្រុង .................................................កាលពីថ្ងៃទី............... ខែ...................... ឆ្នាំ ..................... ដែលត្រូវផ្ដន្ទាទោសតាមមាត្រា .............. នៃច្បាប់............................................................................ ។

បានឃើញ [២] ............................................................................................................................................................................................

យល់ឃើញថា [៣] ............................................................................................................................................................................................

## ហេតុដូច្នេះ សម្រេច

១- ចាត់តាំងលោក ................................................................................................ ជាអ្នកជំនាញដែលមានឈ្មោះក្នុងបញ្ជីនៃអ្នកជំនាញតាមអំណាចមាត្រា ៨៨ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវពិនិត្យសន្និដ្ឋានវាយតម្លៃលើវត្ថុតាងតាមចំណុចដូចខាងក្រោម [៤] :-

ក- ................................................................................................

ខ- ................................................................................................

គ- ................................................................................................

ឃ- ................................................................................................

២- អ្នកជំនាញមានភារកិច្ចកត់ត្រាបន្ថែមលើការសំគាល់ឃើញដទៃទៀតដែលមានប្រយោជន៍ ។ របាយការណ៍នៃកិច្ច ប្រតិបត្តិការនេះ នឹងត្រូវប្រគល់អោយតុលាការក្នុងរយៈពេល ..........................គិតចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅ.............................. ថ្ងៃទី......... ខែ............... ឆ្នាំ.............

ចៅក្រមស៊ើបអង្កេត

10

# ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**បន្ទប់ស៊ើបសួរ " ហ "**

លេខៈ "ហ" ព្រ.ទ

## ដីកាបង្គាប់ឲ្យចូលខ្លួន

**យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ.យ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ចោទប្រកាន់លើឈ្មោះ ភេទស្រី អាយុ ២៥ឆ្នាំ ពីបទ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា **៣៧៧** និងមាត្រា **៣៧៨** នៃក្រមព្រហ្មទណ្ឌ។

<u>បង្គាប់មក៖</u> ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន នៅភូមិ ឃុំ ស្រុក ខេត្ត ។

ឲ្យចូលកាន់សាលាដំបូងរាជធានីភ្នំពេញ **នៅបន្ទប់ស៊ើបសួរ " ហ " ជាន់ទី៥ នាថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង១៤ និង ៣០ នាទីរសៀល ។**

**ដើម្បី៖ បង្ហាញខ្លួនលើកដំបូង, ពិភាក្សាដេញដោលចំពោះមុខ និងសួរចម្លើយ។**

ពីដំណើររឿង **ឆបោក** ប្រព្រឹត្តនៅ កាលពីថ្ងៃទីឆ្នាំ ។

សាមីខ្លួនត្រូវយកលិខិតផ្សេងៗ ដែលទាក់ទងនឹងរឿងខាងលើនេះមកជាមួយផងប្រសិនបើមាន។

ក្នុងករណីមិនចូលខ្លួនតាមការកំណត់ខាងលើនេះទេ **<u>យើងនឹងចេញដីកាបង្គាប់ឲ្យនាំខ្លួន</u>**។

ថ្ងៃពុធ ១១រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមករា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

ឧបសម្ព័ន្ធទី១១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

តុលាការខេត្ត-ក្រុង

..............................

********

# ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្ន

********

លេខ:......................

យើង..............................................ចៅក្រមស៊ើបអង្កេតនៃតុលាការខេត្ត-ក្រុង............................................។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ.............................. ចុះថ្ងៃទី.......... ខែ......................... ឆ្នាំ......................

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបអង្កេតលេខ ............... ចុះថ្ងៃទី ............ ខែ ............ ឆ្នាំ .....................

របស់ព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង ........................................................... ។

បានឃើញដីកាសម្រេចឱ្យឃុំខ្លួនលេខ ......................... ចុះថ្ងៃទី ............ ខែ .......... ឆ្នាំ ...................................

របស់តុលាការខេត្ត-ក្រុង.............................................................. ។

ដើម្បីតាមការស៊ើបអង្កេតឱ្យបានល្អ:-

បង្គាប់ឱ្យឃុំខ្លួនឈ្មោះ.............................................................. អាយុ............ឆ្នាំ ភេទ.......... ជាតិ...................................

របររកស៊ី.................................... កើតនៅភូមិ ..........................................ឃុំ-សង្កាត់.............................................

ស្រុក-ខណ្ឌ................................ ខេត្ត-ក្រុង.............................. ។ ទីលំនៅបច្ចុប្បន្នភូមិ.......................................

ឃុំ-សង្កាត់......................... ស្រុក-ខណ្ឌ.......................... ខេត្ត-ក្រុង............................... ទោសពីមុន..................។

ឪពុកឈ្មោះ............................................... រ-ស ម្ដាយឈ្មោះ............................................................. រ-ស

ប្ដី ឬប្រពន្ធឈ្មោះ............................................. រ-ស មានកូន ឬនៅលីវ.............................................................។

ត្រូវចាប់ខ្លួនពីថ្ងៃទី............ខែ..................... ឆ្នាំ............ ពីបទ...........................................................................

ប្រព្រឹត្តនៅភូមិ.............................. ឃុំ-សង្កាត់ ...................... ស្រុក-ខណ្ឌ ...................ខេត្ត-ក្រុង ........................

កាលពីថ្ងៃទី.......... ខែ.......... ឆ្នាំ......... បទល្មើសដែលមាន ចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ...................................

នៃច្បាប់.........................................................................................................................................។

បង្គាប់ឱ្យប្រធានមន្ទីរឃុំឃាំងខេត្ត-ក្រុង........................................ឃុំខ្លួនឈ្មោះនេះបណ្ដោះអាសន្នឱ្យបានសម្រេចតាមដីកានេះ ។

ធ្វើនៅ..................... ថ្ងៃទី........ ខែ........ ឆ្នាំ ២០០....

**ចៅក្រមស៊ើបអង្កេត**

បានទទួលដំណឹងរួចហើយ

នៅថ្ងៃទី........... ខែ........... ឆ្នាំ ២០០.......

**ព្រះរាជអាជ្ញា**

21

ឧបសម្ព័ន្ធទី១១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ: "ហ"ដពស

# ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ
អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ ។

បានឃើញមាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ក្រោយពីបានពិនិត្យលើសំណុំរឿងចប់សព្វគ្រប់ឃើញថា:

នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ ៦៦ឆ្នាំ ជនជាតិខ្មែរ មុខរបរ កែច្នៃដើមកៅស៊ូ ទីកន្លែងកំណើត ភូមិមេមត់ ឃុំមេមត់កណ្ដាល ស្រុកមេមត់ ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ន ភូមិជីប៉េះ ឃុំមេមត់ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ប្រពន្ធឈ្មោះ មានកូន នាក់ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "ស្លាប់" ជានីតិជន ទោសពីមុន គ្មាន ។

ត្រូវបានដាក់ក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

## សំអាងហេតុ

-ជនត្រូវចោទចូលមកបង្ហាញខ្លួនដោយស្ម័គ្រចិត្ត ហើយជននេះមានមុខរបរ និងទីលំនៅច្បាស់លាស់។

-វិធានការនៃការដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មានលក្ខណ:គ្រប់គ្រាន់ហើយ។

-ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព តាមមាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ហេតុដូច្នេះសម្រេច

មិនឃុំខ្លួនឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ ដែលមានសាវតារជាតិ ខាងលើ។

ថ្ងៃចន្ទ ៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩
ចៅក្រមស៊ើបសួរ

បានទទួលដំណឹង
ថ្ងៃចន្ទ ៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
រាជធានីភ្នំពេញ,ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩
ឋ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១២

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចដាក់ជនត្រូវចោទ ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

លេខ:...............''ហ''ដពស យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញ មាត្រា ២២៣ និងមាត្រាពាក់ព័ន្ធ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌស៊ើបសួរលេខ ៤២៦៥ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**យល់ឃើញថា**

ជនត្រូវចោទត្រូវបានចោទប្រកាន់ពីទោសព្រហ្មទណ្ឌ ត្រូវបានសម្រេចមិនឃុំខ្លួនជាបណ្តោះអាសន្ន គប្បីសម្រេចដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**សម្រេច**

១.ដាក់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្ត ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្ត ប្រពន្ធឈ្មោះ មានកូន នាក់ ឪពុកឈ្មោះ "ស្លាប់" ម្តាយឈ្មោះ "ស្លាប់" ជានីតិជន ទោសពីមុន គ្មាន ត្រូវចោទពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីឆ្នាំ២០១៧ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការដោយត្រូវឱ្យគោរពនូវកាតព្វកិច្ចដូចខាងក្រោម៖

ក-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

ខ-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

គ-ត្រូវបង្ហាញខ្លួននៅសប្តាហ៍ទី១ ជារៀងរាល់ខែនៅប៉ុស្តិ៍នគរបាលរដ្ឋបាលមេមត់។

២.ក្នុងករណីដែលជនត្រូវចោទគេចវេះដោយចេតនា មិនអនុវត្តតាមចំណុចណាមួយខាងលើនេះចៅក្រមស៊ើបសួរអាចនឹងចាប់ឃុំខ្លួនជនត្រូវចោទឡើងវិញ ដោយអនុវត្តតាមមាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.បង្គាប់មក នាយប៉ុស្តិ៍នគរបាលរដ្ឋបាលមេមត់ ចាត់វិធានការអនុវត្តតាមដីកានេះ និងជូនដំណឹងមកយើងដោយមិនបង្អង់នូវរាល់ឧប្បត្តិហេតុដែលកើតមានទាក់ទងនឹងការអនុវត្តដីកានេះ។

ថ្ងៃចន្ទ ៥រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩

ក្រឡាបញ្ជី

ចៅក្រមស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រឡាបញ្ជី
បន្ទប់អក្សរ "ហ" ជាន់ទី៥

ឧបសម្ព័ន្ធទី១៣

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

លេខ.........ហ.ព្រទ

## លិខិតជូនដំណឹង
## ស្តីពីការបិទបញ្ចប់ការស៊ើបសួរ

**យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ: នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

ជម្រាបមក **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ជ្រាបថា:

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ នោះយើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់ហើយ ។

ហេតុដូច្នេះសូម **តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ** ជ្រាបជាដំណឹង ។

ថ្ងៃអង្គារ ០៧រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

**យោបល់របស់តំណាងអយ្យការ**

..........................................................

..........................................................

ថ្ងៃ.........ខែ.........ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ......ឆ្នាំ២០១៩
**ជ.ព្រះរាជអាជ្ញា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី១៤

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខៈ
ចុះថ្ងៃទី ខែ ឆ្នាំ
លេខៈ..........អ.យ.ឌ

3012

# ដីកាសន្និដ្ឋានស្ថាពរ

យើង តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ សំណុំរឿងស៊ើបសួរលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ លិខិតជូនដំណឹងដល់តំណាងអយ្យការលេខ ហ.ព្រ.ទ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញៈ ដីកាបញ្ជូនសំណុំរឿងឲ្យពិនិត្យលេខ ហ.ព្រ.ទ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ ឃើញថាៈ**

១-នាមត្រកូល -នាមខ្លួន ភេទប្រុស អាយុ ឆ្នាំ ជនជាតិ ទីកន្លែងកំណើតភូមិ ឃុំ ស្រុក ខេត្ត សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្ត មុខរបរ ប្រពន្ធឈ្មោះ (រស់) មានកូន នាក់ ឪពុកឈ្មោះ (ស្លាប់) ម្តាយឈ្មោះ (រស់) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)។

២-នាមត្រកូល -នាមខ្លួន ភេទស្រី អាយុ ឆ្នាំ ជនជាតិ ទីកន្លែងកំណើតភូមិ ឃុំ ស្រុក ខេត្ត សាសនាព្រះពុទ្ធ ទីលំនៅបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្តត្បូង មុខរបរ ប្តីឈ្មោះ (រស់)មានកូន នាក់ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (រស់) ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅ កាលពីអំឡុងឆ្នាំ តាមបញ្ញត្តិមាត្រា៣៧៧និងមាត្រា៣៧៨ នៃ ក្រមព្រហ្មទណ្ឌ ។

**ឃើញថា[១]:**

-កាលពីអំឡុងឆ្នាំ ឈ្មោះ និងឪពុក បានចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយក្រុមហ៊ុន ដែលមានឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន ហើយបានព្រមព្រៀងគ្នាដោយកាតីឈ្មោះ ទទួលបាន % ចំណែកឯឈ្មោះ និងឪពុកទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះឈ្មោះ និងឪពុកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ។បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ឈ្មោះ និងឪពុកបានផ្ញើប្រាក់ឲ្យទៅក្រុមហ៊ុន តាមរយៈធនាគារ ដែលឈ្មោះ ,ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ ដោយផ្ទាល់សរុបចំនួន ដុល្លាអាមេរិក។ក្រោយពីទទួលបានប្រាក់រួចហើយឈ្មោះ បានធ្វើការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញ មកឲ្យឈ្មោះ ឡើយ។ហើយពួកគេបានគេចវេស និងគេចខ្លួនបាត់។

**បានឃើញ**

-ពាក្យបណ្តឹងផ្ទាល់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ ឈ្មោះ ។

-កំណត់ហេតុចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅចំពោះមុខតំណាងអយ្យការនិងចៅក្រមស៊ើបសួរ មានភាពប្រហាក់ប្រហែលគ្នាឆ្លើយថា:កាលពីឆ្នាំ មានមិត្តភ័ក្ត្ររបស់ខ្លួនជាជនជាតិ បានណែនាំខ្លួនឲ្យស្គាល់ឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន ដោយឈ្មោះ ជាកូនបង្កើតរបស់ឈ្មោះ រីឯឈ្មោះ ជាប្រពន្ធរបស់ឈ្មោះ ដើម្បីចាប់ដៃគ្នាក្នុងការរកស៊ីទិញនិងលក់ដើមកៅស៊ូនៅខេត្ត ។ក្នុងការពិភាក្សារកស៊ីនោះខ្លួននិងមិត្តភ័ក្ត្ររបស់ខ្លួន ជាអ្នកចេញប្រាក់ក្នុងការរកស៊ី រីឯអ្នកទាំងបីមានក្រុមហ៊ុនគ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ ហើយប្រាក់ចំណូលបានមកគឺខាងក្រុមហ៊ុន % រីឯខ្លួននិងមិត្តភ័ក្ត្ររបស់ខ្លួនទទួលបាន %។ក្រោយមកខ្លួនបានដាក់ប្រាក់ចំនួន ដុល្លាអាមេរិក ទៅឲ្យក្រុមហ៊ុន ដោយមានឈ្មោះ ,ឈ្មោះ និងឈ្មោះ ជាអ្នកទទួល។ នៅពេលដែលក្រុមហ៊ុនទិញចំការកៅស៊ូខាងគាត់បានហៅខ្លួនឲ្យចុះទៅមើលនិងទិញពីចំការពេលដែលទិញរួចខាងក្រុមហ៊ុនជាអ្នកចាត់ចែងទាំងអស់ ហើយពេលដែលកាប់ដើមកៅស៊ូលក់ចេញវិញគាត់គ្រាន់តែទូរស័ព្ទមកប្រាប់។នៅថ្ងៃទី ខែ ឆ្នាំ ក្រុមហ៊ុនបានទិញចំការកៅស៊ូរបស់ឈ្មោះ ទំហំ ហិកតា។ពេលលក់បានដំបូងពួកគាត់បានចែកប្រាក់ចំណេញចំនួន ដុល្លាអាមេរិក។ក្រោយមកក្រុមហ៊ុនមិនបានឲ្យដំណឹងពីការលក់ដើមកៅស៊ូទៀតទេ។ដោយបាត់ដំណឹងយូរខ្លួនបានស៊ើបសួរទើបដឹងថា ក្រុមហ៊ុនលក់ដើមកៅស៊ូលើកទី បានទំហំ ហិកតា តែពួកគាត់មិនបានឲ្យដំណឹងនិង

[១] រៀបរាប់អង្គហេតុ និងរាល់ចំណាត់ការនៃនីតិវិធីតាមលំដាប់(ឧទាហរណ៍ អង្គហេតុដែលបានកើតឡើង ចំណាត់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងចៅក្រមស៊ើបសួរ)

ចែកប្រាក់ចំណេញមកខ្លួនទេ បន្ទាប់មកខ្លួនបានទៅសួរតែពួកគាត់ឆ្លើយដាក់គ្នាទៅវិញទៅមក ក្រោយមកខ្លួនបានទាក់ទងទៅឈ្មោះ និងឈ្មោះ ជាច្រើនលើកច្រើនសារតែអ្នកទាំងពីរគេចវេសនិងបានគេចខ្លួនរហូតមកដល់ពេលនេះ។

-កំណត់ហេតុចំលើយរបស់សាក្សីឈ្មោះ នៅចំពោះមុខចៅក្រមស៊ើបសួរ ឆ្លើយថាៈកាលពីឆ្នាំ ខ្លួនបានរកស៊ីទិញដើមកៅស៊ូចាស់ៗកាប់យកទៅលក់នៅប្រទេសវៀតណាម ក្រោយមកខ្លួនបានស្គាល់ឈ្មោះ គាត់បានសុំខ្លួនចូលហ៊ុនគ្នារកស៊ី ពេលដែលទៅទិញដើមកៅស៊ូត្រូវចេញលុយម្នាក់ពាក់កណ្តាល ពេលកាប់លក់អស់ទើបចែកគ្នាម្នាក់ពាក់កណ្តាលវិញៗចំពោះការរកស៊ីរបស់ខ្លួនជាមួយឈ្មោះ ពុំមានលុយទេ គឺឈ្មោះ ជាអ្នកចំណាយលុយចូលហ៊ុន ហើយពួកខ្លួនមិនបានបើកជាក្រុមហ៊ុនរឺចុះកិច្ចសន្យាក្នុងការរកស៊ីទេៗ ពេលដែលទៅម៉ៅចំការកៅស៊ូទើបដាក់លុយចូលពាក់កណ្តាលម្នាក់ៗចំពោះឈ្មោះ យូរៗទើបគាត់មកមើលម្តង គឺគាត់ឲ្យឈ្មោះ ចុះជាប់ជាមួយខ្លួន ប្រាក់ចំណូលដែលបានមកខ្លួនបានប្រគល់ឲ្យទៅឈ្មោះ តាមរយៈឈ្មោះ ហើយពេលខ្លះខ្លួនបានមកភ្នំពេញប្រគល់ឲ្យគាត់ផ្ទាល់តែម្តង ។ក្រោយមកនៅដើមឆ្នាំ ឪពុកខ្លួនបានទិញចំការកៅស៊ូនៅបឹងកេត ខ្លួនក៏បានសុំចែកគាត់ គាត់ក៏ព្រមចែកឲ្យ ពេលនោះឈ្មោះ បាននាំឈ្មោះ មករកស៊ី ដោយខ្លួនមានលុយតិចដាក់ % រីឯឈ្មោះ ដាក់ ពេលនោះឈ្មោះ និងឈ្មោះ បានចុះទៅកាប់កៅស៊ូជាមួយខ្លួនផ្ទាល់ៗបន្ទាប់ពីកាប់អស់បានប្រាក់ចំណេញ ដុល្លាអាមេរិក ខ្លួនបាន ដុល្លាអាមេរិក ឯខាងគាត់បាន ដុល្លាអាមេរិក ហើយប្រាក់ខ្លួនប្រគល់ទៅឲ្យឈ្មោះ តាមរយៈឈ្មោះ ។នៅចុងឆ្នាំ ឪពុកខ្លួនទិញបានចំការកៅស៊ូនៅមេមត់របស់ក្រុមហ៊ុន ខ្លួនបានទៅសុំចែកពីឪពុកខ្លួន គាត់ព្រមចែកឲ្យ តែឲ្យខ្លួនយកលុយកក់ក្រុមហ៊ុនចំនួន ដុល្លាអាមេរិក ។ក្រោយមកឈ្មោះ បានវេលុយចំនួន ដុល្លាអាមេរិក ចូលគណនីរបស់ឪពុកខ្លួនយកលុយទៅកក់ឲ្យក្រុមហ៊ុននោះ ព្រោះឪពុកខ្លួនជាអ្នកធ្វើកិច្ចសន្យាជាមួយក្រុមហ៊ុនៗ ហើយខ្លួនបានឲ្យឈ្មោះ ផ្ញើលុយចំនួន ដុល្លាអាមេរិកដើម្បីបង់ តែដោយខ្លួនពុំមានគណនីធនាគារ ខ្លួនបានឲ្យគាត់វេចូលគណនីធនាគាររបស់ប្រពន្ធខ្លួនឈ្មោះ ពេលដែលវេចូលហើយខ្លួនបានឲ្យប្រពន្ធខ្លួនបើកមកទាំងអស់យកទៅបង់ឲ្យក្រុមហ៊ុននិងសល់ចំណាយទៅលើកម្មករនិងថ្លៃហូបចុកឈ្មោះ និងឈ្មោះ ។ដោយខ្វះលុយដើម្បីបង់ឡូត៍ខ្លួនបានឲ្យឈ្មោះ ផ្ញើលុយមកទៀតៗពេលនោះខ្លួនបានទៅបើកគណនីផ្ទាល់ខ្លួននៅធនាគារ ដើម្បីឲ្យគាត់វេលុយចូលមកគណនីរបស់ខ្លួនតែម្តងៗដោយខ្វះខាតលុយខ្លួនបានឲ្យគាត់វេមកឲ្យខ្លួនជាបន្តបន្ទាប់ តែមិនដឹងថាប៉ុន្មានដងទេ គ្រាន់តែដឹងថាគាត់ឲ្យលុយសរុបចំនួន ដុល្លាអាមេរិក តែខ្លួនបានវេលុយដើមឲ្យគាត់វិញចំនួន ដុល្លាអាមេរិក ហើយខ្លួននៅខ្វះគាត់ចំនួន ដុល្លាអាមេរិកៗចំពោះប្រាក់ដែលគេទិញកៅស៊ូបានខ្លួនមិនបានវេឲ្យឈ្មោះ ទេ ខ្លួនបានយកលុយនោះនាំឈ្មោះ និងឈ្មោះ ដើរស៊ីចាយនិងលេងល្បែងចាញ់អស់ ខ្លួនក៏បិទទូរស័ព្ទនិងគេចពីឈ្មោះ ។ចំពោះប្រពន្ធនិងឪពុកខ្លួនមិនបានដឹង

ពីការរកស៊ីរបស់ខ្លួនទេ ហើយការរកស៊ីនេះមិនពាក់ព័ន្ធនិងក្រុមហ៊ុនឪពុករបស់ខ្លួនទេ ពេលបានលុយមកខ្លួនមិនបានចែកនិងដាក់ចូលក្រុមហ៊ុនទេ គឺខ្លួនយកមកចាយផ្ទាល់ខ្លួន។

-កំណត់ហេតុចំលើយរបស់ជនត្រូវចោទឈ្មោះ   នៅចំពោះមុខចៅក្រមស៊ើបសួរ ឆ្លើយថាៈខ្លួនជាអគ្គនាយកក្រុមហ៊ុន   ខូអិលធីឌី ចំពោះឈ្មោះ   ជាកូនប្រុសរបស់ខ្លួននិងប្រពន្ធឈ្មោះ   ពុំមានតួនាទី អ្វីនៅក្នុងក្រុមហ៊ុនទេ គេបានទៅរកស៊ីផ្សេងរបរដើរទិញដើមកៅស៊ូចាស់ៗយកទៅលក់នៅប្រទេសវៀតណាម ពុំទាក់ទងនឹងក្រុមហ៊ុនខ្លួនទេ ក្រុមហ៊ុនខ្លួនជាសិប្បកម្មកែច្នៃដើមកៅស៊ូចាស់ៗដែលអស់ជ័រហើយអារជ្រៀក ត្រាំថ្នាំ និងសម្ងួត ដើម្បីដឹកទៅក្រៅប្រទេសនិងលក់ឲ្យសិប្បកម្មធ្វើគ្រឿងសង្ហារឹមក្នុងប្រទេស។កាលពីឆ្នាំ   កូនរបស់ខ្លួននិងឈ្មោះថាន់បានមកពិងឲ្យខ្លួនជួយទិញដើមកៅស៊ូរបស់ក្រុមហ៊ុន   ចំនួន   ហិកតា ដើម្បីកាប់កូនកៅស៊ូលក់ក្រុមហ៊ុននេះក៏បានយល់ព្រមព្រោះជាមិត្តភក្តិរបស់ខ្លួន ។ក្រោយពីទិញបានកូនរបស់ខ្លួនក៏កាប់លក់ក៏មានឈ្មោះឈិនម្នាក់ទៀតចូលមករកស៊ី ជាមួយកូនរបស់ខ្លួនក្នុងការកាប់  ,ហិកតាដែរ។ក្រោយពីកាប់អស់កូនខ្លួនប្រាប់ថាចំណេញបានប្រាក់ចំនួន   ដុល្លាអាមេរិក តែប្រាក់ចំណេញនេះមិនពាក់ព័ន្ធនិងក្រុមហ៊ុនខ្លួនទេ គឺពួកគេចែកគ្នាខ្លួនមិនដឹងទេ។ខ្លួនមិនស្គាល់ឈ្មោះ   ទេ គ្រាន់តែដឹងថាពួកគេចូលហ៊ុនគ្នា ចំណែកដើមកៅស៊ូរបស់ក្រុមហ៊ុនមេមត់ កូនរបស់ខ្លួនបានមកសុំចែក ខ្លួនក៏ព្រមចែកឲ្យក្នុងតម្លៃដើម ដោយតម្រូវឲ្យកក់ ចំនួន   ដុល្លាអាមេរិក បន្ទាប់មកស្រាប់តែមានគេវេលុយចូលគណនីរបស់ខ្លួនចំនួន  ,ដុល្លាអាមេរិក ក្រោយពីកក់លុយរួចពួកគេក៏បានចុះកាប់កៅស៊ូដោយមុនកាប់ឡូត៍មួយណាត្រូវបង់លុយឲ្យក្រុមហ៊ុនសិនទើបកាប់ដើមកៅស៊ូបាន។ចំពោះការបង់តម្លៃឡូត៍ដែលត្រូវកាប់គឺកូនរបស់ខ្លួនជាអ្នកយកទៅបង់ ចំណែកខ្លួនជាអ្នកធ្វើឯកសារទូទាត់ជាមួយក្រុមហ៊ុន។ក្រោយពីពួកគេកប់បានចំនួន   ហិកតា ខាងក្រុមហ៊ុនបានប្រាប់ខ្លួនថា ការកាប់ដើមកៅស៊ូមិនបានបង់លុយឲ្យក្រុមហ៊ុន   ទេ ពេលនោះខ្លួនបានចុះទៅមើលក៏បាត់មិនឃើញពួកគេ នៅមើលការខុសត្រូវនៅទីនោះមិនដឹងទៅណាអស់ រីឯកូនរបស់ខ្លួនក៏បាត់។ ក្រោយមកឈ្មោះ   បានប្រាប់ខ្លួនថាគាត់បានវេលុយឲ្យកូនរបស់ខ្លួនចំនួន  ,ដុល្លាអាមេរិកហើយគាត់ថាបានវេចូលគណនីរបស់ខ្លួនចំនួន   ដុល្លាអាមេរិក សម្រាប់កក់ដើមកៅស៊ូលើកដំបូង គាត់សុំយកលុយពីខ្លួនវិញ តែខ្លួនប្រាប់គាត់ថាលុយនេះបានយកទៅកក់ឲ្យក្រុមហ៊ុន.   អស់ហើយ កាលពីលើកដំបូង មិនអាចដកវិញបានទេ។

-កំណត់ហេតុចំលើយរបស់ជនត្រូវចោទឈ្មោះ   នៅចំពោះមុខចៅក្រមស៊ើបសួរ ឆ្លើយថាៈប្តីរបស់ខ្លួនមិនមានក្រុមហ៊ុនទេ គឺគាត់រកស៊ីទិញដើមកៅស៊ូ ពីចំការកៅស៊ូនៅមេមត់យកទៅលក់នៅវៀតណាម ។ចំពោះក្រុមហ៊ុន   ខូអិលធីឌី ដែលមានឪពុកក្មេកខ្លួនជាអគ្គនាយកក្រុមហ៊ុននោះ ប្តីរបស់ខ្លួនពុំពាក់ព័ន្ធអ្វីក្នុងក្រុមហ៊ុននេះទេ។នៅឆ្នាំ២០១៧ក្រោយមកមានឈ្មោះថាន់,ឈ្មោះឈិននិងឈ្មោះលី អាន់មីង បានមកសុំប្តីរបស់ខ្លួនចូលហ៊ុនរកស៊ីដែល តែការចូលហ៊ុនដោយរបៀបណានោះគឺខ្លួនមិនបានដឹងទេ ដោយសារគាត់មានគ្នារកស៊ីហើយខ្លួនក៏ឈប់ជួយគាត់ គឺខ្លួនទៅរកស៊ីលក់គ្រឿងក្រអូបនិងផ្លែឈើនៅផ្សារមេមត់វិញ។នៅឆ្នាំមិនចាំប្តីរបស់ខ្លួននិងគ្នារបស់គាត់បានទៅសុំចែក

ដើមកៅស៊ូរបស់ក្រុមហ៊ុន ចំនួន ហិកតា ពីឪពុកក្មេករបស់ខ្លួន ខ្លួនមិនដឹងតម្លៃប៉ុន្មាន ហើយកក់ប៉ុន្មានទេ ។កាលពីខែ ឆ្នាំ ប្តីរបស់ខ្លួនបានយកលេខគណនីរបស់ខ្លួនដោយគាត់ប្រាប់ថាដើម្បីឲ្យឈ្មោះ វេរលុយឲ្យថ្លៃដើមកៅស៊ូគេ ព្រោះពេលនោះប្តីរបស់ខ្លួនមិនទាន់មានលេខគណនីនៅធនាគារទេ។បន្ទាប់មកឈ្មោះ បានវេរលុយចូលក្នុងគណនីរបស់ខ្លួនចំនួនពីរដងសរុបចំនួន ដុល្លាអាមេរិកតែប៉ុណ្ណោះ លុយផ្សេងទៀតខ្លួនមិនបានដឹងឡើយ។ក្នុងការរកស៊ីរបស់ប្តីខ្លួន ខ្លួនមិនដឹងចំណេញរឺខាតយ៉ាងណានោះប្តីខ្លួនមិនបានប្រាប់មកខ្លួនទេ ។ក្រោយឪពុកក្មេកមកសួររកប្តីរបស់ខ្លួនដោយគាត់ប្រាប់ថា គាត់មានពាក់ព័ន្ធលុយក្នុងការរកស៊ីជាមួយចិន ឲ្យគាត់មកទូទាត់លុយឲ្យគេ ហើយខ្លួនបានប្រាប់គាត់ថាប្តីរបស់ខ្លួនបានប្រាប់ខ្លួនថាទៅភ្នំពេញដើម្បីទំនាក់ទំនងរកស៊ី គាត់ទៅរយៈពេលប្រហែលជាកន្លះខែហើយមិនបានឲ្យដំណឹងមកខ្លួនទេ។ក្រោយមកទើបខ្លួនដឹងថាប្តីរបស់ខ្លួនត្រូវបានសាលាដំបូងរាជធានីភ្នំពេញឃុំខ្លួន។

-ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ: (ហ) ដ.ព.ស ចុះថ្ងៃទី ខែ ឆ្នាំ លើឈ្មោះ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យលេខ: (ហ) ដ.ព.ស ចុះថ្ងៃទី ខែ ឆ្នាំ លើឈ្មោះ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ: (ហ) ដ.ព.ស ចុះថ្ងៃទី ខែ ឆ្នាំ លើឈ្មោះ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ដីកាសម្រេចដាក់ជនត្រូវចោទឲ្យស្ថិតក្រោមការត្រួតពិនិត្យលេខ: (ហ) ដ.ព.ស ចុះថ្ងៃទី ខែ ឆ្នាំ លើឈ្មោះ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

-ឯកសារពាក់ព័ន្ធនានានៅក្នុងសំណុំរឿង។

**យល់ឃើញថា**[២] :

-កាលពីអំឡុងឆ្នាំ ឈ្មោះ បានចូលហ៊ុនរកស៊ីទិញលក់ដីកៅស៊ូនៅខេត្ត ជាមួយក្រុមហ៊ុន ដែលមានឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែកឯឈ្មោះ ទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះឈ្មោះ ចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះ ។បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ឈ្មោះ បានផ្ញើប្រាក់ឲ្យទៅក្រុមហ៊ុន តាមរយៈធនាគារ ដែលឈ្មោះ ,ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ ដោយផ្ទាល់សរុបចំនួន ដុល្លាអាមេរិក។ក្រោយពីទទួលបានប្រាក់រួចហើយឈ្មោះ បានធ្វើការ

---

[២] សំអាងហេតុ និងសំអាងច្បាប់

កាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញ មក ឲ្យឈ្មោះ ឡើយ។ហើយពួកគេបានគេចវេស និងគេចខ្លួនបាត់។

-តាមចំលើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ,សាក្សី ,ជនត្រូវចោទ និងភស្តុតាងផ្សេងៗ ដែលមានភាពស៊ីសង្វាក់ បង្ហាញឲ្យឃើញថា ជនត្រូវចោទឈ្មោះ និងឈ្មោះ ពិតជាបានប្រព្រឹត្តបទល្មើសដូចតាមការប្តឹងចោទប្រកាន់របស់ដើមបណ្តឹងប្រាកដមែន។

-អំពើប្រព្រឹត្តខាងលើរបស់ជនត្រូវចោទឈ្មោះ និងឈ្មោះ គឺជាបទល្មើសឆបោក ត្រូវផ្តន្ទាទោសតាមបញ្ញាត្តិមាត្រា ៣៧៧ និង៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-ជនត្រូវចោទឈ្មោះ និងឈ្មោះ ជានីតិជនដែលមានស្មារតីយល់ដឹងគ្រប់គ្រាន់ទៅលើអំពើប្រព្រឹត្តរបស់ខ្លួនកាលពីអំឡុងឆ្នាំ ដែលអំពើនេះធ្វើឲ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិជនរងគ្រោះនិងជាបទល្មើសព្រហ្មទណ្ឌទៀតផង ។

-មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ និងឈ្មោះ ពីបទ: ឆបោក ប្រព្រឹត្តនៅ , កាលពីអំឡុងឆ្នាំ តាមបញ្ញត្តិមាត្រា៣៧៧និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

**<u>ហេតុដូច្នេះ</u>**

ប្តឹងសុំចៅក្រមស៊ើបសួរសម្រេចៈ

-បញ្ជូនជនត្រូវចោទ

១.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ ។(ក្រៅឃុំ)

២.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិ ។(ក្រៅឃុំ)

*ទៅជំនុំជម្រះ ពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ តាមបញ្ញត្តិមាត្រា៣៧៧និងមាត្រា៣៧៨ នៃក្រមព្រហ្មទណ្ឌ។*

ថ្ងៃព្រហស្បតិ៍ ៨ កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែវិច្ឆិកា ឆ្នាំ ២០១៩

ព្រះរាជអាជ្ញារង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គំរូទី
(បន្ទប់អក្សរ "ហ" ជាន់ទី៥)

ឧបសម្ព័ន្ធទី១៥

សាលាដំបូងរាជធានីភ្នំពេញ
បន្ទប់ស៊ើបសួរ "ហ"
លេខ. ......"ហ" ព្រទ

## លិខិតជូនដំណឹង
## ពីដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខៈ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ អ.យ.ផ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

**<u>សូមជម្រាបមកៈ</u>** លោក ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ និងឈ្មោះ មានការិយាល័យស្ថិតផ្ទះលេខ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

ត្បិតសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ ដែលបានប្តឹងចោទប្រកាន់ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ ឆ្នាំ ពីបទៈ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ២០១៧ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

នោះយើងបានចាត់ការស៊ើបសួរចប់សព្វគ្រប់អស់ហើយ និងបានបញ្ជូនសំណុំរឿងទៅជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខៈ ... ... "ហ" ដដ ចុះថ្ងៃទី.......ខែកញ្ញា ឆ្នាំ២០១៩ រួចហើយ ។

អាស្រ័យហេតុនេះ សូមជ្រាបជាព័ត៌មាន ។

ថ្ងៃ..........ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី..........ខែកញ្ញា ឆ្នាំ២០១៩
**ចៅក្រមស៊ើបសួរ**

16

38/4

ឧបសម្ព័ន្ធទី១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តព្រះសីហនុ
មន្ទីរស៊ើបសួរ (ញ)
លេខ: ✓

## ដីកាសម្រេចលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ អមដោយលោក ជាក្រឡាបញ្ជី។

-បានឃើញ មាត្រា២៤៧ថ្មី ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: អក/១៨ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ: អខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តព្រះសីហនុ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: អយក/១៩ ចុះថ្ងៃទី ខែ ឆ្នាំ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។

### ក្រោយពីបានធ្វើការស៊ើបសួរចប់សព្វគ្រប់៖

-ឈ្មោះ ភេទប្រុស កើតឆ្នាំ ជនជាតិ មុខរបរ មានទីកន្លែង[illegible]នៅសង្កាត់ ក្រុង មានទីលំនៅបច្ចុប្បន្ននៅ សង្កាត់ ក្រុង ខេត្ត ។ ប្រពន្ធឈ្មោះ ។ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (ស)។

[illegible]ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ៖ បំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ប្រព្រឹត្តនៅភូមិ ស[illegible] ក្រុង ខេត្ត កាលពីឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទា[illegible]មាត្រា២៤៨ និងមាត្រា២៥២ នៃច្បាប់ភូមិបាល។

ឃើញថា៖កាលពីថ្ងៃទី ឈ្មោះ បានទិញដីមួយកន្លែងនៅភូមិ សង្កាត់ [illegible]ឈ្មោះ ។ក្រោយពីទិញដីរួចហើយឈ្មោះ បានស្នើសុំឲ្យមន្ត្រីជំនាញចុះវាស់វែងដី[illegible]ទិញស្រាប់តែឈ្មោះ បានចេញមកអះអាងថាដីដែលខ្លួនស្នើសុំវាស់វែងនេះគឺជា[illegible]ដោយសំអាងលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ។

ឃើញថា៖តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ បានបញ្ជាក់ថា:ចំពោះដីរបស់ខ្លួនទំហំ [illegible]ការ៉េ មានទីតាំងស្ថិតនៅភូមិ សង្កាត់ ក្រុង ខេត្ត ដូចមានក្នុង[illegible]សម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់[illegible]ចំផែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ដែលដើមបណ្តឹងប្តឹងថាខ្លួន[illegible]មន្ត្រីសុរិយោដីក្នុងការចុះបញ្ជីដីនោះ គឺពុំត្រឹមត្រូវឡើយ ពីព្រោះដីនេះខ្លួនបានស្នើសុំចុះបញ្ជីកម្មសិទ្ធិ[illegible]នីតិវិធី ដោយមានមន្ត្រីសុរិយោដីចុះទៅអង្កេតដល់ទីតាំងដីជាក់ស្តែង និងបានពិនិត្យរាល់ឯកសារ ≠

|

ពាក់ព័ន្ធ ព្រមទាំងបានផ្សាយជាសាធារណៈរំពីព័ត៌មានដែលបេប្រមូលបានពីការវាស់វែង ហើយគ្មានភាគីណាមកប្តឹងតវ៉ាឡើយ។ បន្ទាប់ពីឃើញថាគ្រប់គ្រាន់អស់ហើយទើបមន្ត្រីសុរិយោដីចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ឲ្យខ្លួន។ ឯកសារដែលខ្លួនស្នើសុំចេញប័ណ្ណគឺសំអាងលើកំណត់ហេតុអង្កេតដីលេខ និងកំណត់ហេតុអង្កេតដីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានទំហំដី អា និង សង់ទីអា ព្រមទាំងដីដែលខ្លួនទិញពីឈ្មោះ ទំហំ ម៉ែត្រការ៉េ តាមកិច្ចសន្យាព្រមព្រៀងទិញលក់ដី ចុះថ្ងៃទី ។ក្រោយពីខ្លួនទទួលបណ្ណកម្មសិទ្ធិរួចហើយ គឺខ្លួនបានធ្វើរបងថ្មរឹងមាំព័ទ្ធជុំវិញដី ហើយបានកាន់កាប់និងអាស្រ័យផលរហូតដល់សព្វថ្ងៃនេះ។ ដូច្នេះ សូមតុលាការធ្វើការលើកលែងចោទប្រកាន់ដល់ខ្លួនផង។

-ឃើញថា៖តាមចម្លើយរបស់មេធាវីតំណាងនិងការពារសិទ្ធិឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ លោកស្រី បានបញ្ជាក់ថា៖កាលពីថ្ងៃទី ខែ ឆ្នាំ កូនក្តីខ្លួនបានទិញដីពីឈ្មោះ និងប្រពន្ធឈ្មោះ ដោយបានធ្វើកិច្ចសន្យាទិញ-លក់ដីមិនកែប្រែ ចុះថ្ងៃទី ខែ ឆ្នាំ ។ ប៉ុន្តែការលក់ទិញដីនេះកូនក្តីខ្លួនមិនបានឲ្យអាជ្ញាធរដឹងឮទេ គឺគ្រាន់តែឲ្យមេធាវីបញ្ជាក់ទទួលស្គាល់តែប៉ុណ្ណោះ។ ចំពោះដីដែលកូនក្តីខ្លួនទិញនេះមានទីតាំងស្ថិតនៅភូមិ សង្កាត់ ក្រុង ខេត្ត មានទំហំ ម៉ែត្រការ៉េ ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ។ម្យ៉ាងវិញទៀត ដីនេះគឺមានធ្វើរបងថ្មព័ទ្ធជុំវិញព្រំប្រទល់ដីតាំងពីម្ចាស់ដើមមកម្ល៉េះ ហើយការកសាងប័ណ្ណសំគាល់សិទ្ធិនេះត្រូវបានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីសុរិយោដី តែក្រោយមកត្រូវបានឈ្មោះ មកឈូសឆាយរបងថ្មដែលធ្វើព័ទ្ធជុំវិញព្រំដី ព្រមទាំងបានធ្វើបណ្ណគ្របលើដីរបស់កូនក្តីខ្លួនថែមទៀតផង។ចំពោះការកសាងវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ គឺឈ្មោះ សំអាងលើឯកសារពីរ គឺ ទី១-កំណត់ហេតុអង្កេតដីលេខ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៨ ដែលមានទំហំដី អា និងទី២-កំណត់ហេតុអង្កេតដីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលមានទំហំដី អា និង សង់ទីអា។ដូច្នេះ សរុបតាមកំណត់ហេតុអង្កេតដីទាំងពីរនោះលើគឺមានទំហំដីតែ អា និង សង់ទីអាតែប៉ុណ្ណោះ។ ផ្ទុយទៅវិញនៅក្នុងវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ គឺមាន ទំហំដី រហូតដល់ ម៉ែត្រការ៉េវិញ។ដូច្នេះឈ្មោះ គឺបានក្លែងបន្លំទំហំដីជាក់ស្តែងដើម្បីគ្របយកដីរបស់កូនក្តីខ្លួនតាមរយៈការកសាងប័ណ្ណថ្មីនេះ។

-ឃើញថា៖តាមចម្លើយរបស់សាក្សីឈ្មោះ ជាមន្ត្រីនៅក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងភូមិបាល បានឆ្លើយបញ្ជាក់ថា៖ក្នុងអំឡុងឆ្នាំ នៃការបំពេញទិន្នន័យក្បាលដីលេខ ខ្លួនមានតួនាទីជាប្រធានគ្រប់គ្រងតំបន់វិនិច្ឆ័យ នៅលើទម្រង់បែបបទនៃការបំពេញទិន្នន័យក្បាលដី ដែលមានឈ្មោះ ជាអ្នកផ្តល់ព័ត៌មានក្បាលដីដែលគាត់បានបង្ហាញព្រំប្រទល់ដីរបស់គាត់។ ចំពោះឆ្នាំកាន់កាប់គឺតាំងពីឆ្នាំ ដោយទទួលអំណោយពីរដ្ឋ ហើយដាក់ថាជាដីគ្មាន ដែលពេលនោះមានមន្ត្រីវិនិច្ឆ័យឈ្មោះ និងឈ្មោះ ប្រធាន សង្កាត់ វិនិច្ឆ័យលើក្បាលដីនេះ។ ចំពោះក្បាលដីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ពិតជាត្រូវបានកសាងឡើងត្រឹមត្រូវតាមនីតិវិធីសុរិយោដី ហើយបើតាមពិនិត្យលេខាធារិក របស់សុរិយោដី វិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ក្នុងអំឡុងពេលនៃការបិទផ្សាយព័ត៌មានពាក់ព័ន្ធនឹងក្បាលដីនេះគឺមានអ្នកដែលមានផលប្រយោជន៍

ធ្វើការប្តឹងជំទាស់ហើយទំនាស់នេះត្រូវបានដោះស្រាយតាមការព្រមព្រៀងរបស់គូភាគីកាលពីថ្ងៃទី ខែ ឆ្នាំ ទើបប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលសរសេរដាក់ឈ្មោះ និងឈ្មោះ ជាកម្មសិទ្ធិករ។

-ឃើញថា៖តាមចម្លើយរបស់សាក្សីឈ្មោះ ជាអតីតប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ បានបញ្ជាក់ថាៈចំពោះក្បាលដីលេខ ចុះថ្ងៃទី ខែ ឆ្នាំ ពេលឈ្មោះ ស្នើសុំចេញប័ណ្ណដំបូងគឺមានឈ្មោះ បានប្តឹងជំទាស់ ក្រោយមកភាគីទាំងពីរក៏បានព្រមព្រៀងបញ្ចប់វិវាទដីធ្លី ចុះថ្ងៃទី ខែ ឆ្នាំ ។ក្រៅពីឈ្មោះ ប្តឹងជំទាស់ឈ្មោះ គឺគ្មានភាគីណាប្តឹងទៀយ។ បន្ទាប់ពីបញ្ចប់វិវាទរួចហើយខាងមន្ទីរក៏បានចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលសរសេរដាក់ឈ្មោះ និងៈ ជាកម្មសិទ្ធិករ។ម្យ៉ាងវិញទៀត នៅពេលដែលកសាងប័ណ្ណកម្មសិទ្ធិនេះគឺមានការបិទផ្សាយរយៈ ថ្ងៃ ហើយពេលចុះវាស់វែងប័ណ្ណកម្មសិទ្ធិដីនីមួយៗគឺត្រូវមានម្ចាស់កម្មសិទ្ធិដីនីមួយៗចូលរួម និងចង្អុលព្រំផងដែរ។ដូច្នេះ ការកសាងបណ្ណរបស់ឈ្មោះលឹម ហ៊ុយឡេង គឺត្រូវបាលធ្វើឡើងត្រឹមត្រូវតាមនីតិវិធីសុរិយោដី។

-ឃើញថា៖តាមចម្លើយរបស់សាក្សីឈ្មោះ បានបញ្ជាក់ថាៈខ្លួនជាអ្នកម៉ៅការធ្វើរបងឲ្យឈ្មោះ ។ចំពោះដីរបស់ឈ្មោះ និងឈ្មោះ នៅសង្កាត់ ក្រុង ខេត្ត គឺខ្លួនជាអ្នកម៉ៅធ្វើរបងថ្មកំពស់ តឹក។ ការធ្វើរបងនេះគឺធ្វើតាមបឿនចាស់តែប៉ុណ្ណោះ។ខ្លួនធ្វើរបងព័ទ្ធដីនេះមានរយៈពេល ខែទើប ធ្វើរួច ក្នុងអំឡុងពេលដែលខ្លួនម៉ៅការធ្វើរបងនេះគឺមិនមានជនណាមកធ្វើការតវ៉ា ឬហាមឃាត់ខ្លួនឡើយ។

-ឃើញថា៖តាមចម្លើយរបស់សាក្សីឈ្មោះតាន់ គាត់ បានឆ្លើយបញ្ជាក់ថាៈឈ្មោះ ពិតជាមានដីដែលបានកាត់ចេញពីឈ្មោះខ្លួនទំហំតាមបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ព្រោះថាដីនេះដំបូងឡើយឈ្មោះ និងឪពុកក្មេករបស់ខ្លួនឈ្មោះ ព្រមចូលគ្នាតែដាក់ឈ្មោះខ្លួន និងប្រពន្ធខ្លួនជាអ្នកឈរឈ្មោះ តែខ្លួនមិនចាំថ្ងៃ ខែ ឆ្នាំនោះទេ ព្រោះយូរឆ្នាំហើយ។ដោយឡែកឈ្មោះ លក់ដីនេះឲ្យទៅអ្នកណានោះគឺខ្លួនមិនបានដឹងឡើយ។ ចំពោះរឿងដែលឈ្មោះ ធ្វើប័ណ្ណគ្របលើដីរបស់ឈ្មោះ យ៉ាងណាខ្លួនមិនបានដឹងទេ ហើយឈ្មោះ លក់ដីនេះទៅឲ្យឈ្មោះ ពីពេលណានោះក៏ខ្លួនមិនបានដឹងដែរ។

-ឃើញថា៖តាមពាក្យសុំជូនចម្លើយបំភ្លឺ ចុះថ្ងៃទី ខែ ឆ្នាំ របស់ឈ្មោះ និងឈ្មោះ

-ឃើញថា៖ តាមដីកាសន្និដ្ឋានស្ថាពរលេខៈ អ.យ.ក/១៩ ចុះថ្ងៃទី ខែមិថុនា ឆ្នាំ របស់ចៅក្រមស៊ើបសួរអមសាលាដំបូងខេត្តព្រះសីហនុ បានប្តឹងសុំចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ពីបទៈបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ប្រព្រឹត្តនៅភូមិ២ សង្កាត់ ក្រុង ខេត្ត កាលពីឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៤៨ និងមាត្រា២៤៩ នៃក្រមព្រហ្មទណ្ឌ។ គប្បី តុលាការពិចារណា។

**យល់ឃើញថាៈ**

-តាមចម្លើយរបស់ជនត្រូវចោទ,ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ,ចម្លើយសាក្សី និងការពិនិត្យភស្តុតាង

ជាឯកសារក្នុង សំណុំរឿងឃើញថា៖ នីតិវិធីនៃការកសាងវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលបានសរសេរដាក់ឈ្មោះកម្មសិទ្ធិករ និងនាង គឺត្រូវបានធ្វើឡើងត្រឹមត្រូវតាមនីតិវិធីសុរិយោដី ដោយគ្មានភស្តុតាងច្បាស់លាស់ណាមួយបង្ហាញឲ្យឃើញពីចេតនាទុច្ចរិតរបស់ជនត្រូវចោទក្នុងការបំភាន់អាជ្ញាធរសុរិយោដីក្នុងការចុះបញ្ជីដីនោះទេ។ ម្យ៉ាងទៀត តាមចម្លើយរបស់សាក្សីឈ្មោះ និងសាក្សីឈ្មោះ បានឆ្លើយបញ្ជាក់ថា៖ នៅមុនពេលទីតិវិធីចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ គឺបានបិទផ្សាយព័ត៌មានរយៈ ថ្ងៃ ហើយពេលចុះវាស់វែងប័ណ្ណកម្មសិទ្ធិដីនីមួយៗគឺត្រូវបានម្ចាស់កម្មសិទ្ធិនីមួយៗចូលរួម និងអង្គុលបង្ហាញព្រំ ហើយអំឡុងពេលនោះមានឈ្មោះ បានចូលមកធ្វើការប្តឹងទាស់ តែក្រោយមកគូភាគីបានព្រមព្រៀងផ្សះផ្សាបញ្ចប់វិវាទរួចអស់ហើយ ទើបខាងមន្ទីរចេញវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុលេខ ចុះថ្ងៃទី ខែ ឆ្នាំ ដែលសរសេរដាក់ឈ្មោះ និងនាង ជាកម្មសិទ្ធិករ។ជារួមមកឃើញថា៖ ជនត្រូវចោទគ្មានចេតនាទុច្ចរិតក្នុងការបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដីនោះទេ។ហេតុដូច្នេះ អំពើរបស់ជនត្រូវចោទគ្មានធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ និងគ្មានពិរុទ្ធភាពពីបទៈបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ប្រព្រឹត្តនៅភូមិ សង្កាត់ ក្រុង ខេត្ត កាលពីឆ្នាំ ។បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៤៨ និងមាត្រា២៥២ នៃច្បាប់ភូមិបាល នោះទេ។គប្បី តុលាការសម្រេចលើកលែងចោទប្រកាន់តាមមាត្រា ២៤៧ ច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ការប្តឹងសុំរបស់តំណាងអយ្យការតាមដីកាសន្និដ្ឋានស្ថាពរលេខ អ.យ.ក/១៩ ចុះថ្ងៃទី ខែ ឆ្នាំ បានប្តឹងសុំទៅក្រុមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ , ពីបទៈបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ប្រព្រឹត្តនៅភូមិ សង្កាត់ ក្រុង ខេត្ត កាលពីឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៤៨ និងមាត្រា ២៥២ នៃច្បាប់ភូមិបាល គឺមានមូលហេតុត្រឹមត្រូវ។ គប្បី សម្រេចតាមការប្តឹងសុំនេះ។

## **ហេតុដូច្នេះសម្រេច**

-លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ (មានសាវតារជាតិដូចខាងលើ) ពីបទៈបំភាន់អាជ្ញាធរក្នុងការចុះបញ្ជីដី ប្រព្រឹត្តនៅភូមិ សង្កាត់ ក្រុង ខេត្ត កាលពីឆ្នាំ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា២៤៨និងមាត្រា២៥២នៃច្បាប់ភូមិបាល។

ថ្ងៃពុធ ៣កើត ខែ ឯកស័ក ព.ស២៥៦៣

ខេត្តព្រះសីហនុ ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៩

**ក្រឡាបញ្ជី** **ក្រុមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១៧

សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុស្ដីពី

# ការបង្ហាញខ្លួនលើកដំបូង

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ

ចុះថ្ងៃទី

សំណុំរឿងស៊ើបសួរ

លេខៈ

ចុះថ្ងៃទី

(មាត្រា ១៤៣ មាត្រា ១៤៤ មាត្រា ២៤០ និងមាត្រា ២៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែមីនា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោង ដប់បួន និងដប់ប្រាំនាទី រសៀល ។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ

នាមត្រកូល នាមខ្លួន ភេទស្រី អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំបាល័ង្គ ស្រុក ខេត្ត អាសយដ្ឋានបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្ត ឪពុកឈ្មោះ ។ ម្ដាយឈ្មោះ ។ ប្ដីឈ្មោះ មានកូន ០ នាក់ ជានីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

ជននេះ ៖☑ ចេះនិយាយ ☑ចេះអាន ☑ ចេះសរសេរអក្សរខ្មែរ

ជននេះ ៖☐ មិនចេះនិយាយ☐ មិនចេះអាន☐មិនចេះសរសេរអក្សរខ្មែរ

បន្ទាប់ពីបានផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជននេះ យើងបានប្រាប់ដល់ជននេះឲ្យដឹងយ៉ាងច្បាស់អំពីរឿងក្ដីដែលព្រះរាជអាជ្ញាបានប្ដឹងមកយើង តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ ដែលជាហេតុនាំឲ្យមានការបង្ហាញជននេះនៅចំពោះមុខយើង ព្រមទាំងប្រាប់ជននេះឲ្យដឹងអំពីបទចោទប្រកាន់ចំពោះ រឿងក្ដីដូចខាងក្រោមៈ

ពីបទ ឆបោក ប្រព្រឹត្តនៅ រាជធានី កាលពីឆ្នាំ ។

យើងបានជូនដំណឹងដល់ជននេះថា យើងគ្រោងនឹងដាក់ជននេះឲ្យស្ថិតនៅក្រោមការពិនិត្យចំពោះរឿងក្ដីដែលយើងទើបនឹងរៀបរាប់ឲ្យជននេះដឹងយ៉ាងច្បាស់ ។

☐លោក ជាមេធាវី នៃជនត្រូវចោទដែលត្រូវបានកោះហៅនៅថ្ងៃទី ខែ ឆ្នាំ ហើយដើម្បីឲ្យលោកស្រីមេធាវី អាចត្រៀមរៀបចំការពារកូនក្ដីខ្លួនបាន។

☑យើងបានប្រាប់ដល់ជននេះ អំពីសិទ្ធិទទួលបានជំនួយមេធាវី ដែលជននេះអាចជ្រើសរើស ពឹងមេធាវីដោយខ្លួនឯង ឬអាចសុំឲ្យគេចាត់តាំងមេធាវីណាម្នាក់ឲ្យរូបគាត់ ។

☑យើងបានប្រាប់ផងដែរដល់ជននេះថា ប្រសិនបើមិនធ្វើការជ្រើសរើសពឹងមេធាវីដោយខ្លួនឯងទេ មេធាវីមួយរូប នឹងត្រូវចាត់តាំងដោយឯកឯង ដោយសារតែជននេះជាអនីតិជន។

+ជននេះ បានប្រកាសប្រាប់ថាៈ

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់មានសិទ្ធិអាចនៅស្ងៀមមិនផ្តល់ចម្លើយក៏បាន ឬអាចធ្វើសេចក្តីប្រកាសផ្សេងៗ ឬអាចឲ្យយើងសួរចម្លើយក៏បាន។ ៧២/២

☑ជននេះ  បានប្រកាសប្រាប់ថា  ខ្ញុំអាចឆ្លើយរឿងហេតុទាំងអស់ជូនតុលាការបាន នៅចំពោះមុខលោកមេធាវី។

☑យើងបានជូនដំណឹងដល់ជននេះថា យើងសម្រេចដាក់គាត់ឲ្យស្ថិតនៅក្រោមការពិនិត្យះ

☑ចំពោះអង្គហេតុទាំងអស់ដែលយើងបានប្រាប់ឲ្យដឹង។

☑ ចំពោះតែអង្គហេតុដែលរៀបរាប់ខាងក្រោម ដែលយើងបញ្ជាក់ប្រាប់ជននេះ អំពីឈ្មោះនៃបទល្មើសគឺបទឆបោក ។

☑យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការសុំឲ្យយើងធ្វើកិច្ចការស៊ើបសួរមួយ ឬច្រើន ឬក៏អាចធ្វើពាក្យប្តឹងសុំមោឃភាពនៃកិច្ចស៊ើបសួរ ដោយផ្អែកតាមមូលដ្ឋាននៃមាត្រា ២៥៣ ប្តឹងឧទ្ធរណ៍ តាមបញ្ញត្តិមាត្រា ២៦៧ នៅក្នុងពេលនៃដំណើរការ នៃការស៊ើបសួរ ក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទ អំពីសិទ្ធិក្នុងការជ្រើសរើសមេធាវីសម្រាប់នីតិវិធីបន្ទាប់មកទៀត ហើយប្រសិនបើមិនបានធ្វើការជ្រើសរើសមេធាវីដោយខ្លួនឯងទេ នឹងបើសិនជាមានសំណើសុំយើងនឹងចាត់តាំងមេធាវីមួយរូបជូន(សម្រាប់តែក្នុងករណីដែលជនត្រូវចោទមិនបានជ្រើសរើសពឹងពាក់មេធាវីដោយខ្លួនឯង និងមិនបានស្នើសុំឲ្យចាត់តាំងមេធាវីឲ្យ)។

+ជននេះបានប្រកាសប្រាប់ថាះ

☐ខ្ញុំជ្រើសរើសមេធាវីដោយខ្លួនឯង

☐ខ្ញុំស្នើសុំឲ្យចាត់តាំងមេធាវីមួយរូបឲ្យខ្ញុំ

☐ខ្ញុំបដិសេធជំនួយពីមេធាវី

☑យើងបានប្រាប់ដល់ជនត្រូវចោទថា គាត់អាចសុំឲ្យបិទការស៊ើបសួរបាននៅក្រោយពេលផុតរយៈពេលមួយឆ្នាំ ដោយអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចឃុំខ្លួនគាត់ជាបណ្តោះអាសន្ន។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា នៅថ្ងៃនេះយើងសម្រេចដាក់គាត់ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនិងប្រាប់គាត់អំពីកាតព្វកិច្ចទាំងឡាយដែលគាត់ត្រូវគោរព។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចមិនឃុំខ្លួន(ឲ្យនៅក្រៅឃុំ)។

☐យើងបានប្រាប់ដល់ជនត្រូវចោទថាះ

គាត់ត្រូវប្រកាសប្រាប់ពីអាសយដ្ឋានដែលអាចជាអាសយដ្ឋានផ្ទាល់ខ្លួន ឬជាអាសយដ្ឋានរបស់តតិយជនណាម្នាក់ ដែលទទួលបន្ទុកទទួលយកលិខិត ដែលបញ្ជូនទៅឲ្យគាត់ ប្រសិនបើគាត់ អាចផ្តល់ឲ្យភ្លាមនូវការព្រមព្រៀងជាលាយល័ក្ខណ៍អក្សររបស់តតិយជននោះ។

-អាសយដ្ឋានដែលត្រូវប្រកាសត្រូវមាន ។

ជនត្រូវចោទបានប្រកាសអាសយដ្ឋានដូចខាងក្រោមះ

☐អាសយដ្ឋាននេះ ជាអាសយដ្ឋានផ្ទាល់ខ្លួន។

☐អាសយដ្ឋាននេះ ។

☐យើងបានប្រកាសដល់ជនត្រូវចោទបន្ថែមះ

រហូតដល់ការបិទការស៊ើបសួរ គាត់ត្រូវប្រាប់យើងគ្រប់ការផ្លាស់ប្តូរអាសយដ្ឋាន ដែលបានប្រកាសប្រាប់ខាងលើ ដោយការប្រកាសជាថ្មី ឬដោយលិខិតអនុសិដ្ឋ។

គ្រប់ការជូនដំណឹង ឬការឲ្យដំណឹងដែលបញ្ជូនទៅអាសយដ្ឋាន ដែលបានប្រកាសប្រាប់ចុងក្រោយបង្អស់ត្រូវចាត់ទុកថាជូនដំណឹងដល់បុគ្គលជនត្រូវចោទ។

☑យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☑យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង ក្រឡាបញ្ជី និងអ្នកបកប្រែ។

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|---|

18 01/14

ឧបសម្ព័ន្ធទី១៨

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

| | |
|---|---|
| អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ | |
| ចូល | លេខ............ ថ្ងៃទី.......ខែ.........ឆ្នាំ ម៉ោង...........................នាទី |

# ពាក្យបណ្តឹង

ខ្ញុំបាទឈ្មោះ អាយុ ឆ្នាំ មានទីលំនៅផ្ទះលេខ អឺ ផ្លូវលេខ ភូមិ សង្កាត់ ខណ្ឌ រាជធានី ។

**សូមគោរពចូលមក**

**ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ**

**សូមមេត្តាជ្រាប**

**កម្មវត្ថុ:** សំណើសុំប្តឹង ១.ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ និង ២.ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិ ដែលមានទីលំនៅ ភូមិ ឃុំ ស្រុក ពីបទ **រំលោភលើទំនុកចិត្ត និងឆបោកប្រាក់** ចំនួន ។

**មូលហេតុ:** កាលពីអំឡុងឆ្នាំ ខ្ញុំបាទ រួមនិងឪពុករបស់ខ្ញុំបាទ បានចូលហ៊ុនរកស៊ីទិញលក់ដើមកៅស៊ូនៅខេត្ត ជាមួយក្រុមហ៊ុន ដែលឈ្មោះ ជាអគ្គនាយកក្រុមហ៊ុន ហើយបានព្រមព្រៀងគ្នាដោយភាគីឈ្មោះ ទទួលបាន % ចំណែករូបខ្ញុំបាទ និងឪពុកទទួលបាន % ការរកស៊ីទិញលក់ដើមកៅស៊ូខាងលើនេះ គឺរូបខ្ញុំ និងឪពុកជាអ្នកចំណាយប្រាក់ទាំងអស់ រីឯឈ្មោះ គ្រាន់តែឈរឈ្មោះតែប៉ុណ្ណោះ ។ បន្ទាប់ពីមានការព្រមព្រៀងគ្នារួចហើយ ខ្ញុំបាទ និងឪពុកបានផ្ញើប្រាក់ឲ្យទៅក្រុមហ៊ុន តាមរយ:ធនាគារ និងធនាគារ ដែលមានឈ្មោះ , ឈ្មោះ និងឈ្មោះ ជាអ្នកទទួលសាច់ប្រាក់ដោយផ្ទាល់សរុបចំនួន ។ ក្រោយពីទទួលប្រាក់រួចហើយ ឈ្មោះ បានដំណើរការកាប់ដើមកៅស៊ូយកទៅលក់ជាបន្តបន្ទាប់ ប៉ុន្តែមិនបានបង្វិលប្រាក់ដើម និងប្រាក់ចំណេញមកឲ្យខ្ញុំបាទឡើយ ដោយពួកគេមានចេតនាគេចវេស និងគេចខ្លួនរហូត ។



ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី១៩

សាលាដំបូងរាជធានីភ្នំពេញ

## លិខិតអញ្ជើញ

**បន្ទប់ស៊ើបសួរ " ហ "**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ចុះថ្ងៃទី

ខែ ឆ្នាំ

យើង ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ

**អញ្ជើញ** : លោក ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទឈ្មោះ និងឈ្មោះ ។

**អាសយដ្ឋាន** : ការិយាល័យស្ថិតនៅផ្ទះលេខ ផ្លូវលេខ សង្កាត់ផ្សារ ខណ្ឌ រាជធានី ។ ទូរស័ព្ទលេខ៖

**ឱ្យចូលមកកាន់** : សាលាដំបូងរាជធានីភ្នំពេញ **នៅជាន់ទី៥ បន្ទប់អក្សរ (ហ) ។**

**នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៩ វេលាម៉ោង ០៨ និង ០០ នាទី ព្រឹក ។**

**ដើម្បី** : ស្តាប់ការសួរចម្លើយ ។

**ពីដំណើររឿង** : **ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីឆ្នាំ ។**

សាមីខ្លួន ត្រូវអញ្ជើញតាមដីកាកោះនេះឱ្យបានទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលទាក់ទងនឹងរឿងខាងលើ មកជាមួយផងប្រសិនបើមាន ។

6.3.19

ថ្ងៃពុធ ០៨រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

20

ឧបសម្ព័ន្ធទី២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ស.សាលាដំបូងខេត្តព្រះសីហនុ
ចូល
លេខ:.......
ថ្ងៃទី.......ខែ.......ឆ្នាំ.......
ម៉ោង:.......

## ពាក្យសុំចូលជាមេធាវីការពារក្តី

ខ្ញុំបាទ មេធាវី អត្តលេខ ជាមេធាវីនៃក្រុមមេធាវី មហានគរ មានអាសយដ្ឋាននៅផ្ទះលេខ ៣៨៧បេ ផ្លូវលេខ២៧១ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ជាមេធាវីការពារក្តីឲ្យឈ្មោះ ។

**សូមគោរពជូន**
**ឯកឧត្តមប្រធាន សាលាដំបូងខេត្តព្រះសីហនុ**

**កម្មវត្ថុ:** ស្នើសុំចូលជាមេធាវីការពារក្តីឲ្យលោក ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ ៣៩៧ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាខេត្តព្រះសីហនុ ។

**យោង:**
- សំណុំរឿងព្រហ្មទណ្ឌលេខ ៣៩៧ ចុះថ្ងៃទី១៥ ខែ០៦ ឆ្នាំ២០១៨
- លិខិតពឹងពាក់មេធាវី ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៨ ។

តបតាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា: លោក បានមកពឹងពាក់ និងប្រគល់សិទ្ធិជូនយើងខ្ញុំ ដើម្បីធ្វើជាមេធាវីការពារក្តីឲ្យគាត់ ដូចមានចែងក្នុងកម្មវត្ថុខាងលើតាមច្បាប់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងបញ្ចូលបាទខ្ញុំ ទៅក្នុងសំណុំរឿងខាងលើ តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨

**ហត្ថលេខា និងត្រា**

21 ក្រឡាបញ្ជី 34

បន្ទប់អក្សរ "ហ" ជាន់ទី៥

ឧបសម្ព័ន្ធទី២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**បន្ទប់ស៊ើបសួរ "ហ"**

# ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ

លេខ: .... "ហ" ព្រទ **យើង** **ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ**

បានឃើញ មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ: អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ: ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

*ដែលទាក់ទងនឹងជនត្រូវចោទ៖*

១-ឈ្មោះ ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្ត ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្ត ប្រពន្ធឈ្មោះ មានកូនចំនួន នាក់ ឪពុកឈ្មោះ "ស្លាប់" ម្ដាយឈ្មោះ "ស្លាប់" ជានីតិជន។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

២-ឈ្មោះ ភេទស្រី អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើត ភូមិ ឃុំ ស្រុក ខេត្ត ទីលំនៅបច្ចុប្បន្ន ភូមិ ឃុំ ស្រុក ខេត្ត ប្ដីឈ្មោះ មានកូនចំនួន នាក់ ឪពុកឈ្មោះ "រស់" ម្ដាយឈ្មោះ "រស់" ជានីតិជន។

-ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ: ឆបោក ប្រព្រឹត្តនៅ កាលពីឆ្នាំ តាមបញ្ញត្តិមាត្រា ៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

បញ្ជាឱ្យបញ្ជូនសំណុំរឿងស៊ើបសួរនេះទៅព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋាន ឬផ្ដល់យោបល់ទៅតាមនីតិវិធី។

ថ្ងៃ....... ខែអាសាធ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ខែកក្កដា ឆ្នាំ២០១៩

បានទទួលអនុវត្ត **ក្រឡាបញ្ជី**

**ចៅក្រមស៊ើបសួរ**

ទទួល

31-7-2019

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី២២

## <u>ពាក្យសុំពឹងពាក់មេធាវី</u>

ខ្ញុំបាទឈ្មោះ xxx xxxxx មានអាសយដ្ឋានស្ថិតនៅ xxxxx ផ្លូវxxxxx ភូមិxx សង្កាត់ xxxx ខណ្ឌxxxxx រាជធានីភ្នំពេញ។

## <u>សូមពឹងពាក់</u>

មេធាវី xxx xxxxx ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា នៅការិយាល័យ **ក្រុមមេធាវី** xxxxxxxxxxxx មានទីតាំងស្ថិតនៅ ផ្ទះលេខxx ផ្លូវxxx សង្កាត់xxxx ខណ្ឌxxxxxx រាជធានីភ្នំពេញ។

ដើម្បីធ្វើជាមេធាវីតំណាង និងការពារក្តីឲ្យខ្ញុំបាទក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈxxxxx ចុះថ្ងៃទីxx ខែxxx ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រឹមសាលាដំបូងរាជធានីភ្នំពេញ តាមនីតិវិធីច្បាប់ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ។

ថ្ងៃxxx xxរោច ខែxxxx ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទីxx ខែxxx ឆ្នាំ២០២០

**<u>ស្នាមមេដៃស្តាំអ្នកពឹងពាក់</u>**

xxxx xxxxx

**<u>បានឃើញ និង យល់ព្រម</u>**

ធ្វើជាមេធាវីការពារសិទ្ធិឲ្យឈ្មោះខាងលើចាប់ពីថ្ងៃ
ចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទីxx ខែxxx ឆ្នាំ២០២០

**ហត្ថលេខា និង ត្រា**

23

ឧបសម្ព័ន្ធទី២៣

សាលាដំបូងរាជធានីភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុស្ដីពី

# ការពិភាក្សាដេញដោលចំពោះមុខ

(មាត្រា ២០៣ និងមាត្រាបន្តបន្ទាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)

សំណុំរឿងព្រហ្មទណ្ឌ

លេខៈ

ចុះថ្ងៃទី

សំណុំរឿងស៊ើបសួរ

លេខៈ

ចុះថ្ងៃទី

ឆ្នាំពីរពាន់ដប់ប្រាំបួន ខែមីនា ថ្ងៃទីម្ភៃប្រាំ វេលាម៉ោង ប្រាំបី និងសាមសិបនាទីព្រឹក ។

លោក ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

យោងតាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ អ.យ.គ ចុះថ្ងៃទី ខែ ឆ្នាំ

បុគ្គលដែលនៅចំពោះមុខយើង បានផ្ដល់នូវព័ត៌មានអំពីអត្តសញ្ញាណដូចខាងក្រោមៈ

នាមត្រកូល នាមខ្លួន ភេទប្រុស អាយុ ឆ្នាំ ជនជាតិ មុខរបរ ទីកន្លែងកំណើតភូមិ ឃុំ កណ្ដាល ស្រុក ខេត្ត អាសយដ្ឋានបច្ចុប្បន្នភូមិ ឃុំ ស្រុក ខេត្ត ឪពុកឈ្មោះ "ស" ម្ដាយឈ្មោះ ហៀង "ស" ប្រពន្ធឈ្មោះ មានកូន នាក់ ជាទីតិជន ប្រវត្តិនៃការផ្ដន្ទាទោសដោយតុលាការ គ្មាន ។

តើអ្នកឯងចេះអាន និងចេះសរសេរភាសាខ្មែរដែរឬទេ? ចេះនិយាយ ចេះអាននិងចេះសរសេរខ្មែរ

ជននេះត្រូវដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ឆបោក ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពី ឆ្នាំ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៣៧៧ និង ៣៧៨ នៃក្រមព្រហ្មទណ្ឌ។

☐ដោយមានលោកមេធាវី ដែលជនត្រូវចោទបានជ្រើសរើសពឹងពាក់ដោយខ្លួនឯង ឬដែលត្រូវបានចាត់តាំងដោយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានមកបង្ហាញនៅចំពោះមុខយើង បន្ទាប់ពីបានពិគ្រោះមើលសំណុំរឿង និងបានធ្វើទំនាក់ទំនងដោយសេរីជាមួយ នឹងជនត្រូវចោទនៅពេលបង្ហាញខ្លួនជាលើកដំបូង។

យើងបានប្រាប់ដល់ជនត្រូវចោទថាៈ

☐-យើងមានបំណងសម្រេចឃុំខ្លួន ជនត្រូវចោទជាបណ្ដោះអាសន្ន។

☐-ជនត្រូវចោទអាចស្នើសុំពន្យាពេល ដើម្បីរៀបចំការពារខ្លួន។

☐-យើងនឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ននៅថ្ងៃនេះ។

ជនត្រូវចោទបានប្រកាសប្រាប់ថាៈ ខ្ញុំបាទបដិសេធការចោទប្រកាន់របស់តំណាងអយ្យការ ។

ការពិភាក្សាដេញដោលចំពោះមុខទាក់ទង និងការឃុំខ្លួនបណ្ដោះអាសន្នៈ

☑ត្រូវបានធ្វើ

☐ត្រូវបានលើកទៅថ្ងៃទី........ ខែ.......ឆ្នាំ............

តាមសំណូមពររបស់តំណាងអយ្យការបានបង្ហាញនូវសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

ស្នើសុំឃុំខ្លួនជាបណ្ដោះអាសន្ន ។

ជនត្រូវចោទបង្ហាញសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

ខ្ញុំបាទសុំមិនឲ្យឃុំខ្លួនខ្ញុំបាទ ព្រោះខ្ញុំបាទមិនបានប្រព្រឹត្តិដូចការចោទប្រកាន់ទេ ។

មេធាវីការពារសិទ្ធិជនត្រូវចោទបង្ហាញសេចក្ដីសន្និដ្ឋានរបស់ខ្លួនដូចខាងក្រោមៈ

សូមកុំឃុំខ្លួនកូនក្តីរបស់ខ្ញុំបាទ ព្រោះគាត់មិនបានប្រព្រឹត្តិដូចការចោទប្រកាន់នោះទេ។

☐យើងបានប្រាប់ដល់ជនត្រូវចោទថា យើងសម្រេចចេញដីកាសម្រេចឲ្យឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្ន ដោយមានសំអាងហេតុ ហើយយើងសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួននៅថ្ងៃនេះ។

☒យើងបានឲ្យជនត្រូវចោទអានឡើងវិញនូវសេចក្តីប្រកាសទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុងកំណត់ហេតុនេះ ហើយបើមិនបដិសេធគ្រង់ចំណុចណាទេ ឲ្យចុះហត្ថលេខាលើកំណត់ហេតុនេះ។

☐យើងបានអានស្តាប់ចប់សព្វគ្រប់ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើង និងក្រឡាបញ្ជី។

☐បានអានចប់សព្វគ្រប់ដោយអ្នកបកប្រែ ហើយជនត្រូវចោទមិនមានបដិសេធចំណុចណាទេ និងបានចុះហត្ថលេខាជាមួយយើងក្រឡាបញ្ជី និងអ្នកបកប្រែ។

| ជនត្រូវចោទ | មេធាវី | ក្រឡាបញ្ជី | ចៅក្រមស៊ើបសួរ |
|---|---|---|---|

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី២៤

សាលាដំបូងរាជធានីភ្នំពេញ

លេខ:...... ...........ដ.ប/១៩

## ដីកាបញ្ជូន

**គោរពជូន:** លោកប្រធានសាលាដំបូងខេត្តត្បូងឃ្មុំ

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | -ដីកាបង្គាប់ឱ្យចូលខ្លួនឈ្មោះ លេខ "ហ" ព្រទ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់ | "ដើម្បីអនុវត្តតាមនីតិវិធី" |
| ០២ | -ដីកាបង្គាប់ឱ្យចូលខ្លួនឈ្មោះ លេខ "ហ" ព្រទ ចុះថ្ងៃទី ខែ ឆ្នាំ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។ | ០២ច្បាប់ | |
| | សរុប | ០៤ច្បាប់ | |

ថ្ងៃព្រហស្បតិ៍ ១២រោច ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៩

**ចៅក្រមស៊ើបសួរ**

25 40

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឧបសម្ព័ន្ធទី២៥

សាលាដំបូងរាជធានីភ្នំពេញ

បន្ទប់ស៊ើបសួរ "ហ"

## បញ្ជីរាយនាមជនជាប់ទាក់ទិន

ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខៈ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ។

| ល.រ | នាម និងគោត្តនាម | ត្រូវជា | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ០១ | ភេទប្រុស អាយុ ឆ្នាំ | ជនត្រូវចោទ | (ក្រៅឃុំ) |
| ០២ | ភេទស្រី អាយុ ឆ្នាំ | ជនត្រូវចោទ | (ក្រៅឃុំ) |
| ០៣ | ភេទប្រុស អាយុ ឆ្នាំ | ដើមបណ្ដឹងរដ្ឋប្បវេណី | |
| ០៤ | លោក | មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ | |

ថ្ងៃ............ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី..០៩..ខែកញ្ញា ឆ្នាំ២០១៩

ក្រឡាបញ្ជី

26

ក្រុមមេធាវី រ៉ូយ៉ាល់
ROYAL LAW GROUP

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ
ចូល ក្រឡាបញ្ជី
លេខ..........
ថ្ងៃទី....ខែ....ឆ្នាំ២០..
ម៉ោង.......និង.....នាទី

# ឧបសម្ព័ន្ធទី២៦

## ពាក្យស្នើសុំជូនពិនិត្យភស្តុតាង

មេធាវី  និង មេធាវី  ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យនៅ**ក្រុមមេធាវី រ៉ូយ៉ាល់** ( ROYAL LAW GROUP) មានទីតាំងស្ថិតនៅ ONE PARK PROJECT ផ្ទះលេខ: ០៥ SR R08 សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

**សូមគោរពជូន**

**លោកប្រធាន សាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** ស្នើសុំជូនពិនិត្យភស្តុតាងបន្ថែមក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ:  ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង៖** - សំណុំរឿងព្រហ្មទណ្ឌលេខ:  ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់សាលាដំបូងរាជធានីភ្នំពេញ
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមជម្រាប **លោកប្រធាន** មេត្តាជ្រាបថា៖ នៅអំឡុងឆ្នាំ  កូនក្តីយើងខ្ញុំបានត្រូវឈ្មោះ  , ឈ្មោះ  (កូនប្រុសឈ្មោះ  ) និងឈ្មោះ  ឆបោកយកប្រាក់ ដោយពួកគេបានលួងលោមឲ្យកូនក្តីយើងខ្ញុំវេរប្រាក់ទៅកាន់គណនីធនាគាររបស់ឈ្មោះខាងលើនេះ ដើម្បីធ្វើការបណ្តាក់ទុនលើការទិញលក់ដើមកៅស៊ូជាមួយគ្នា។ ប៉ុន្តែ នៅពេលរកស៊ីបានប្រាក់ចំណេញ ឈ្មោះខាងលើមិនបានប្រគល់ប្រាក់ដែលជាផលចំណេញមកឲ្យកូនក្តីយើងខ្ញុំតាមការព្រមព្រៀងនោះទេ។

ដូច្នេះ យើងខ្ញុំស្នើសុំតុលាការពិនិត្យភស្តុតាងបន្ថែមដែលបញ្ជាក់អំពីការបណ្តាក់ទុន និងប្រាក់ចំណេញក្នុងការលក់ដើមកៅស៊ូរបស់ឈ្មោះ  , ឈ្មោះ  (កូនប្រុសឈ្មោះ  ) និងឈ្មោះ  ដែលមានដូចខាងក្រោម៖

I. **អំពីការផ្ទេរប្រាក់បណ្តាក់ទុនជាមួយឈ្មោះ  , ឈ្មោះ  (កូនប្រុសឈ្មោះ  ) និងឈ្មោះ  ដែលកូនក្តីយើងខ្ញុំបានប្រគល់ទៅឲ្យ៖**

១. កាលពីថ្ងៃទី  ខែ  ឆ្នាំ  ឈ្មោះ  បានទទួលប្រាក់ចំនួន  ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណដាក់ប្រាក់ចូលគណនី "ដុល្លារ" ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់ធនាគារ  ។

២. កាលពីថ្ងៃទី  ខែ  ឆ្នាំ  ឈ្មោះ  បានទទួលប្រាក់ចំនួន  ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់ធនាគារ  ។

៣. កាលពីថ្ងៃទី  ខែ  ឆ្នាំ  ឈ្មោះ  បានទទួលប្រាក់ចំនួន  ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់ធនាគារ  ។

៤. កាលពីថ្ងៃទី  ខែ  ឆ្នាំ  ក្រុមហ៊ុន  ដែលមានឈ្មោះ  បានទទួលប្រាក់ចំនួន  ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី  ខែ  ឆ្នាំ  របស់ធនាគារ  ។

៥. កាលពីថ្ងៃទី ខែ ឆ្នាំ ឈ្មោះ បានទទួលប្រាក់ចំនួន ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី ខែ ឆ្នាំ របស់ធនាគារ ។

៦. កាលពីថ្ងៃទី ខែ ឆ្នាំ ឈ្មោះ បានទទួលប្រាក់ចំនួន ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី ខែ ឆ្នាំ របស់ធនាគារ ។

៧. កាលពីថ្ងៃទី ខែ ឆ្នាំ ឈ្មោះ បានទទួលប្រាក់ចំនួន ដុល្លារអាមេរិក ពីកូនក្តីយើងខ្ញុំតាមរយៈប័ណ្ណផ្ទេរប្រាក់គណនី "ដុល្លារ" ចុះថ្ងៃទី ខែ ឆ្នាំ របស់ធនាគារ ។

## II. អំពីប្រាក់ចំណេញដែលឈ្មោះ , ឈ្មោះ (កូនប្រុសឈ្មោះ ) និងឈ្មោះ មិនបានប្រគល់មកឲ្យកូនក្តីយើងខ្ញុំ ដែលចំណេញពីការលក់ដើមកៅស៊ូបានពីអ្នកទិញ

១. កាលពីថ្ងៃទី ខែ ឆ្នាំ គណនីក្រុមហ៊ុន បានទទួលប្រាក់ចំនួន ( )ដុល្លារអាមេរិក ពីឈ្មោះ តាមរយៈប័ណ្ណទទួលប្រាក់ ចុះថ្ងៃទី ខែ ឆ្នាំ របស់ធនាគារ ។

២. លិខិតលក់ដើមកៅស៊ូ ចុះថ្ងៃទី ខែ ឆ្នាំ រវាងអ្នកលក់ឈ្មោះ និងអ្នកទិញឈ្មោះ ដោយមានសាក្សីរបស់ភាគីអ្នកលក់ឈ្មោះ ។

៣. មូលប្បទានបត្រ ធនាគារ លេខ ចុះថ្ងៃទី ខែ ឆ្នាំ មានទឹកប្រាក់ចំនួន ( )ដុល្លារអាមេរិក ចេញដោយក្រុមហ៊ុន .CO.,LTD។

៤. មូលប្បទានបត្រ ធនាគារ ចុះថ្ងៃទី ខែ ឆ្នាំ មានទឹកប្រាក់ចំនួន ( )ដុល្លារអាមេរិក ចេញដោយក្រុមហ៊ុន

៥. លិខិតទទួលប្រាក់ ចុះថ្ងៃទី របស់ឈ្មោះ ដែលបានទទួលប្រាក់ចំនួន ថ្លៃឈើកៅស៊ូពីរោងចក្រសួង។

៦. មូលប្បទានបត្រ ចុះថ្ងៃទី របស់ឈ្មោះ ដែលបានទទួលប្រាក់ចំនួន ថ្លៃឈើកៅស៊ូ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូម **លោកប្រធាន** មេត្តាពិនិត្យកស្តុតាងដែលយើងខ្ញុំបាទបានដាក់ជូនពិនិត្យដូចបានរៀបរាប់ត្រង់ចំណុច I និង II ខាងលើដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ថ្ងៃពុធ ៦កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២០

**មេធាវី.** មេធាវី.

27

ឧបសម្ព័ន្ធទី២៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * * * * *

សាលាដំបូងខេត្តព្រះសីហនុ
ចូល
លេខ:......
ថ្ងៃទី......ខែ......
ម៉ោង:......

## ពាក្យសុំជូនពិនិត្យភស្តុតាង និងបញ្ចូលសាក្សី

មេធាវី ជាសមាជិកក្រុមមេធាវី មានអាសយដ្ឋានអគារ លេខ ជាន់ទី បន្ទប់លេខ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ ជាមេធាវីតំណាងដោយអាណត្តិឲ្យ ។

### សូមគោរពចូលមក
### លោកចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុ

សូមមានជ្រាប ។

**កម្មវត្ថុ:** សំណើសុំជូនពិនិត្យភស្តុតាង និងបញ្ចូលសាក្សីដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងខេត្តព្រះសីហនុ ។

សេចក្តីដូចបានជំរាបជូនក្នុងកម្មវត្ថុខាងលើនាងខ្ញុំសូមជំរាបជូនលោកចៅក្រមមេត្តាទទួលយកភស្តុតាង និងកោះហៅសាក្សីរបស់កូនក្តីនាងខ្ញុំគឺះ

I.ភស្តុតាងជារូបថត

១.រូបថតទីតាំងដីទំនាស់ចំនួន សន្លឹក

II.សាក្សី

១.ឈ្មោះ ភេទប្រុស មានទីលំនៅផ្ទះលេខ..........ភូមិ............សង្កាត់.........ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ទូរស័ព្ទលេខ ។

២.ឈ្មោះ ភេទប្រុស កើតឆ្នាំ មានទីលំនៅភូមិ សង្កាត់ ក្រុង ខេត្ត ទូរស័ព្ទលេខ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមលោកចៅក្រមមេត្តាទទួលយកភស្តុតាង និងកោះហៅសាក្សីរបស់កូនក្តីខ្ញុំខាងលើដោយក្តីអនុគ្រោះ ។

សូមលោកចៅក្រមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៨

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី

ការិយាល័យមេធាវី...........
លេខ:.................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឧបសម្ព័ន្ធទី២៨

## ពាក្យសុំធ្វើកោសលវិច័យ

ខ្ញុំមេធាវី............. អត្តលេខ:...............សមាជិកគណ:មេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ.................................ត្រូវជា.......................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ..................ចុះថ្ងៃទី......ខែ.........ឆ្នាំ..............របស់សាលាដំបូង.............................................។

## សូមគោរពជូន

..................................................

**កម្មវត្ថុ:** សំណើសុំធ្វើកោសលវិច័យលើ...................................

**យោង:-** មាត្រា១៦២ និងមាត្រា២៤៥ ក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី១០/០៨/២០០៧

-សំណុំរឿងព្រហ្មទណ្ឌលេខ......ចុះថ្ងៃទី......ខែ......ឆ្នាំ........របស់.....................

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូន...........................................មេត្តាជ្រាបថា: ដោយហេតុ
ថា.................................................................................................................
........................................................................................................................
.............................................។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក........................មេត្តាអនុញ្ញាតតាមនីតិវិធីនៃច្បាប់។

សូមលោក...............................ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

ធ្វើនៅ................,ថ្ងៃទី.....ខែ........ឆ្នាំ...........

ហត្ថលេខា និងត្រា

ការិយាល័យមេធាវី.............
លេខ:.............

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឧបសម្ព័ន្ធទី២៩

## ពាក្យសុំធ្វើកោសលវិច័យបន្ថែម

ខ្ញុំមេធាវី................អត្តលេខ:សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា.............. .................ជាមេធាវីការពារឲ្យឈ្មោះ ...........ត្រូវជា....................ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ......ចុះថ្ងៃទី.................ខែ.........ឆ្នាំ......របស់...សាលាដំបូង។............................

## សូមគោរពជូន

……………………………………………………………………….

**កម្មវត្ថុ:**សុំធ្វើកោសលវិច័យបន្ថែមលើ........................................................................។

**យោង:**សំណុំរឿងព្រហ្មទណ្ឌលេខ........ចុះថ្ងៃទី......ខែ.........ឆ្នាំ.........របស់សាលាដំបូង..................

- មាត្រា ១៦២, ១៦៧, ១៦៨ និងមាត្រា ១៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧
- ពាក្យពឹងពាក់មេធាវីចុះថ្ងៃទី.........ខែ............ឆ្នាំ...............

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំជាមេធាវីសូមជម្រាបជូន........................... មេត្តាជ្រាបថា៖ដោយ.......................................................................................................មានសារៈសំខាន់សំរាប់រឿងក្តីនេះមិនអាចខ្វះបាន ហើយរយៈកន្លងមកលទ្ធផលនៃការធ្វើកោសលវិច័យ នៅមិនទាន់បានឆ្លើយបញ្ជាក់ត្រូវចំណុចសំខាន់នៅឡើយ។

ករណីនេះរូបខ្ញុំជាមេធាវីស្នើសុំលោក.....................................មេត្តាមានវិធានការធ្វើកោសលវិច័យបន្ថែមលើ............................................និងសុំបញ្ជាក់លើកោសលវិច័យពី ចំណុច.......................................................................................................................។

អាស្រ័យហេតុនេះសូមលោក............................................មេត្តាចាត់វិធានការលើសំណើរសុំធ្វើកោសលវិច័យបន្ថែមដោយក្តីអនុគ្រោះ។

សូម.......................................................ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីរូបខ្ញុំ។

ធ្វើនៅ..............ថ្ងៃទី.......ខែ.......ឆ្នាំ.........
ហត្ថលេខា និងត្រា

**ភ្ជាប់ជូនមកជាមួយ**

- ឯកសារស្នើសុំកោសលវិច័យបន្ថែម

អាសយដ្ឋានផ្ទះលេខ..............ផ្លូវ....................ភូមិ.................ឃុំ/សង្កាត់....................ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី..............
ទូរស័ព្ទ: ....................ទូរសារ:......................អ៊ីម៉ែល: ................................

ឧបសម្ព័ន្ធទី៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការិយាល័យមេធាវី............
លេខ:.............

## ពាក្យសុំបញ្ឈប់ការដាក់ក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ខ្ញុំមេធាវី.............................. អត្តលេខ......... សមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ.......................... ត្រូវជា.......................... ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ .......................... ចុះថ្ងៃទី...... ខែ.........ឆ្នាំ......... របស់សាលាដំបូង................................។

### សូមគោរពជូន

..................................................................

<u>កម្មវត្ថុ:</u>សុំបញ្ឈប់ការដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលើកូនក្តីឈ្មោះ..........................
ភេទ..............អាយុ............ឆ្នាំ មានទីលំនៅ............................................។

<u>យោង:</u>សំណុំរឿងព្រហ្មទណ្ឌលេខ.........ចុះថ្ងៃទី.........ខែ.........ឆ្នាំ......... របស់សាលាដំបូង...............

- មាត្រា ២២៩, ២៤៩, ២៦៧ និងមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចុះថ្ងៃទី១០/០៨/២០០៧
- ពាក្យការពារក្តីចុះថ្ងៃទី...........ខែ..............ឆ្នាំ.................
- ដីកាសម្រេចលេខ...............ចុះថ្ងៃទី......ខែ............ឆ្នាំ.............របស់ចៅក្រម ស៊ើបសួរនៃ សាលាដំបូង.........................................ដែលសម្រេចដាក់ឲ្យកូនក្តី ឈ្មោះ......................................ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើនេះ ខ្ញុំជាមេធាវីទទួលសិទ្ធិពីកូនក្តីឈ្មោះ................................ជាជនជាប់ចោទនៃរឿងក្តីនេះដែលត្រូវបានចៅក្រមស៊ើបសួរចេញដីកាដាក់ស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការតាមដីកាខាងលើ។ក្នុងករណីនេះ ដោយឆ្លងតាមសំណុំរឿងការចោទប្រកាន់ ការស៊ើបអង្កេតរយៈកន្លងមក កូនក្តីខ្ញុំនៅមិនទាន់មានពិរុទ្ធភាពច្បាស់លាស់ ការស៊ើបអង្កេតក៏នៅមានភាពវិមតិសង្ស័យជាមូលដ្ឋានលើកូនក្តីខ្ញុំនៅឡើយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ដើម្បីការពារសិទ្ធិសេរីភាពផ្លូវច្បាប់ឲ្យកូនក្តី ខ្ញុំស្នើសុំឲ្យលោកចៅក្រម មេត្តាចេញដីកាបញ្ឈប់ការដាក់ឲ្យកូនក្តីខ្ញុំស្ថិតក្រោមកាត្រួតពិនិត្យតាមផ្លូវតុលាការដោយក្តីអនុគ្រោះ ។

សូមលោក......................................ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ..............ថ្ងៃទី.......ខែ.......ឆ្នាំ.........
ហត្ថលេខា និងត្រា

អាសយដ្ឋានផ្ទះលេខ...........ផ្លូវ.................ភូមិ...................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ...................ខេត្ត/រាជធានី..............
ទូរស័ព្ទ: ......................ទូរសារ:.......................អ៊ីម៉ែល: .................................

ការិយាល័យមេធាវី.............
លេខៈ.............

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ឧបសម្ព័ន្ធទី៣១

## ពាក្យស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ

ខ្ញុំមេធាវី.................... អត្តលេខៈ...............សមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជាមេធាវីការពារឲ្យឈ្មោះ................................ត្រូវជា......................ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ........................ចុះថ្ងៃទី......ខែ.........ឆ្នាំ...............របស់សាលាដំបូង...................................។

**សូមគោរពជូន**

**លោកចៅក្រមស៊ើបសួរ**..........................................

កម្មវត្ថុ: សុំបំពេញកិច្ចស៊ើបសួរលើសំណុំរឿងព្រហ្មទណ្ឌ។

យោង: -សំណុំរឿងព្រហ្មទណ្ឌលេខ............ចុះថ្ងៃទី......ខែ.........ឆ្នាំ........របស់សាលាដំបូង.....................

- ពាក្យការពារចុះថ្ងៃទី............ខែ............ឆ្នាំ.....................
- មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌចុះថ្ងៃទី ១០/០៨/២០០៧។

សេចក្តីដូចបានជម្រាបតាមកម្មវត្ថុ និងយោងខាងលើ ដោយរឿងក្តីនេះមានចំណុចសំខាន់ត្រូវស្នើសុំឲ្យលោកចៅក្រមស៊ើបបំពេញកិច្ចស៊ើបសួរពីករណី ..................................................................................
......................................................................................................
......................................................................................................ដែលចម្លើយឯកសារកំណត់ហេតុនានាជាមូលដ្ឋានមានសារៈសំខាន់ក្នុងសំណុំរឿងក្តី។

អាស្រ័យហេតុនេះ សូមលោកចៅក្រមស៊ើបសួរ មេត្តាអនុញ្ញាតដំណើរការបំពេញកិច្ចស៊ើបសួរតាមពាក្យស្នើសុំខាងលើដោយក្តីអនុគ្រោះ។

សូមលោកចៅក្រមស៊ើបសួរទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ធ្វើនៅ.............ថ្ងៃទី.......ខែ..........ឆ្នាំ.........
ហត្ថលេខា និងត្រា

អាសយដ្ឋានផ្ទះលេខ............ផ្លូវ..................ភូមិ....................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ....................ខេត្ត/រាជធានី..............
ទូរស័ព្ទ: ......................ទូរសារ:........................អ៊ីមែល: ..................................